ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៨ លេខ ៥ ខែឧសភា ព.ស. ២៤៩៩ គ.ស. ១៩៥៦

N°
ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង


*ផ្នែកសាសនា* — ទំព័រ

- រឿងប្រៀបធៀបរកសេចក្ដីពិត ...... យុនអគ្គកោវិទ ជា-យូរ ....... ៤០៣
- ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា .... លោក ទៀង-តៃឈុន ប្រែ ..... ៤១២
- ឥទ្ធិបាទធម៌ ................ ព្រះមហា អ៊ុម-ផេង ......... ៤១៨
- ជាតកថារឿងពុទ្ធរូបបុរាណ (តមក) ... យុនអគ្គកោវិទ ជា-យូរ ប្រែ ..... ៤២៧

*ផ្នែកអក្សរសាស្ត្រ*

- ចិត្តល្ងង់ខ្លៅនឹងចិត្តចេះដឹង ....... យុនបណ្ណានុរក្ស ប៊ូ-ប៉ូ ......៤៣៣
- រឿងព្រះបាទរុសភ៏នសាជ និងព្រះនាង សេហេរិស្តានី (ត-ចប់) ....... អ្នកស្រី សារិះយ៉ាន ប្រែ ......៤៣៨
- សុភាសិតរាជនីតិ ពាក្យកាព្យ (ត-ចប់).. អ្នកឧកញ៉ា នៅ .......... ៤៤៧
- ពេជ្រព្រះរាជា (តមក) ....... លោក ស៊ិន-ហ៊ាន ប្រែ ..... ៤៥៦
- រឿងសាមកុក (តមក) ....... ឧកញ៉ា នូ-កន ......... ៤៦៣
- រឿងបល្ល័ង្កទិព្យ (តមក) ...... លោក វ៉ាយ-ប៊ុក ប្រែ ...... ៤៧០

*កំណត់និងប្រវត្តិការណ៍*

- ពិធីសម្ពោធសាលាបាលីជាន់ខ្ពស់ នៅ ខេត្តសៀមរាប .......... ពុទ្ធសាសនបណ្ឌិត្យ ........ ៤៧៥
- ពិធីបុណ្យទក្ខិណានុប្បទាន ....... ព្រះអាចារ្យ នូ-កិញ ........ ៤៨៥
- ពិធីសម្ពោធក្លូងមន្ទីរពេទ្យព្រះសង្ឃ (តចប់) ពុទ្ធសាសនបណ្ឌិត្យ ........ ៤៩១


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២៣០រ,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*

**PARTIE RELIGIEUSE:** *Page*


— Sur la vérité . . . . . . . . *M. CHEA-YOU . . . . . . 403*

— Le Bouddhisme au Cambodge.. *Traduit par M. TIANG-TAY-CHHUN . . . . . . 412*

— Iddhipadadharma . . . . . . *Vénérable OUM-PHENG. . . . 418*

— Les statues Bouddhiques primitives (suite) . . . . . . . *Traduit par M. CHEA-YOU.. 427*


**PARTIE LITTÉRAIRE:**


— La pensée juste et la pensée fausse . . . . . . . . . . . *M. BOU-PO . . . . . . . 433*

— Le Roi RUZVANSCHAD et la Princesse CHEHERISTANI (suite et fin) . . . . . . . . *Traduit par Mme PICH-SAL née SRIN-SARIS-YANN . . . . 438*

— Subhasitarajaniti (suite et fin) *Oknha NEOU . . . . . . 447*

— Conte "Le Diamant du Raja" (suite) . . . . . . . . . . *Traduit par M. SIN-HEAN . 456*

— Histoire de SAMKOK (suite). . *Oknha NOU-KAN . . . . . 463*

— Les trente deux récits du TRONE (suite) . . . . . . . *Traduit par M. RAY-BUC . 470*


**NOTES ET CHRONIQUES:**


— Inauguration de l'Ecole Supérieure de Pali de la Province de Siemreap . . . . . . . . *Institut Bouddhique . . . . . 475*

— Cérémonie "dakkhinanuppadana" . . . . . . . . . . . . *Vénérable NOU-KENH . . . . 485*

— Inauguration de l'Hôpital des Bonzes (suite et fin) . . *Institut Bouddhique . . . . . 491*


**Prix d'abonnement annuel (comprenant 12 numéros) 230$00**

## ផ្នែកសាសនា

# រឿងប្រៀបធៀបក្នុងការរកសេចក្ដីពិត

ឃុនអគ្គកោវិទ ជា - យ៉ូវ ពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

អ្នកប្រាជ្ញទាំងឡាយពោលថា “ការពិសោធន៍ស្រាវជ្រាវរកសេចក្ដីពិតនិងសមុដ្ឋាននៃរបស់ពិត គេអាចរកឃើញបានដោយការប្រៀបធៀប” ហេតុនោះការប្រៀបធៀប ទើបជាមេរៀនដ៏សំខាន់ក្នុងការវិនិច្ឆ័យនូវសេចក្ដីសន្ទិះសង្ស័យ ចំពោះការនិយាយកុតករកុហក ឬការនិយាយពិតត្រង់ ។

រាប់តាំងពីសញ្ញាតញ្ញាណរបស់មនុស្សចេះប្រើការប្រៀបធៀបមក, ការប្រៀបធៀបក៏ទៅជាគោលពិសោធន៍រកសេចក្ដីពិត ក្នុងវត្តទាំងពួង ហើយតាំងពីសម័យនោះរហូតមកដល់សម័យឥឡូវនេះ ការប្រៀបធៀបក៏ទៅជាមេរៀនដ៏សំខាន់ ធ្លាក់នៅកណ្ដាលនៃសេចក្ដីនិយមរាប់អានដែលមិនមានទំនងនឹងផ្លាស់ប្ដូរបានឡើយ ។

សេចក្ដីនេះក៏ជាគ្រឿងបញ្ជាក់ឲ្យឃើញច្បាស់ថា គ្រប់ៗ បណ្ដាអ្នកដែលមានសេចក្ដីចេះដឹងល្អ ចូលចិត្តល្អ និងមានសមត្ថភាព អាចផ្ទេរចំណេះឲ្យអ្នកដទៃបានចេះដឹងបានចូលចិត្តផងនោះ ត្រូវជាអ្នកមានគំនិតចេះគិតប្រៀបធៀបយ៉ាងល្អបំផុត ។ សូម្បីក្នុងការប្រតិបត្តិកិច្ចការផ្សេងៗ ឬ ទឹងនិយាយទឹងធ្វើអ្វីៗ ក៏ដោយ ត្រូវតែអាស្រ័យយកការប្រៀបធៀប

មកធ្វើជាបន្ទាត់ដឹកតម្រង់មើលការប្លែក ៗ ក្នុងវិធានការដែលត្រូវធ្វើ ឬពាក្យដែលត្រូវនិយាយ ដែលនាំឲ្យដឹងខុសដឹងត្រូវ ។

អ្នកដែលមានការចេះដឹងច្រើន ក៏ព្រោះមានការគិតប្រៀបធៀបច្រើន, អ្នកដែលមានការចេះដឹងល្អ ក៏ព្រោះមានការគិតប្រៀបធៀបល្អ, អ្នកដែលមានសមត្ថភាព អាចផ្ទេរចំណេះឲ្យអ្នកដទៃបានដោយល្អ ក៏ព្រោះឈ្លាសក្នុងការប្រៀបធៀបល្អ ដែលនាំឲ្យអ្នកទទួលចំណេះបានចូលចិត្តយ៉ាងឆាប់រហ័ស ។

គោលនៃការប្រៀបធៀបមានដូច្នេះជាដើម គឺ:

១.- បើចង់ដឹងរបស់ខ្ពស់ ត្រូវយករបស់ទាបមកប្រៀបធៀបគ្នាមើល, បើចង់ដឹងរបស់ទាប ត្រូវយករបស់ខ្ពស់មកប្រៀបធៀបគ្នាមើល;

២.- បើចង់ដឹងការជ្រៅនឹងការរាក់ ត្រូវយកការរាក់នឹងការជ្រៅនៃវត្ថុនោះមកប្រៀបធៀបគ្នាមើល;

៣.- បើចង់ដឹងវត្ថុតូចឬធំ ត្រូវយកការតូចឬការធំនៃវត្ថុនោះមកប្រៀបធៀបគ្នាមើល;

៤.- បើចង់ដឹងវត្ថុស្ដើងឬក្រាស់ ត្រូវយកការស្ដើងឬក្រាស់នៃវត្ថុនោះមកប្រៀបធៀបគ្នាមើល;

៥.- បើចង់ដឹងល្អឬមិនល្អនៃវត្ថុណា ត្រូវយកការល្អឬមិនល្អនៃវត្ថុនោះមកប្រៀបធៀបគ្នាមើល ។

ការប្រៀបធៀបនេះ ជាការងាយណាស់ ស្រួលគិតណាស់ ។ តែទោះបីជាការងាយស្រួលគិតដូច្នោះក៏ដោយ ក៏នៅតែមានមនុស្សជា

ច្រើននាក់ ដែលមិនព្យាយាមរកសេចក្ដីចេះដឹងនិងសេចក្ដីចូលចិត្តដោយការប្រៀបធៀបទេ តែងធន់ទ្រាំនៅដោយការមិនចេះមិនចូលចិត្តរហូតមួយជីវិត ។

គោលសំខាន់ក្នុងការប្រៀបធៀបនោះ នៅត្រង់ការពិចារណារកសេចក្ដីចូលចិត្តក្នុងរបស់ណាមួយជាមុនសិន ថារបស់នេះមានរូបសំឡេង ក្លិន, រស, សម្ផស្ស ដូចម្ដេច? មានគុណ, ដំឡៃ, ហេតុ, ផល ដូចម្ដេច? មានអាការជាដើមថា កើត, ឋិតនៅ, រលត់ទៅ ដូចម្ដេច? ត្រឹមណា? ព្រោះថា កាលបើយើងយល់ជាក់នូវអាការរបស់វត្ថុនោះហើយ ៗ យើងយកទៅប្រៀបធៀបនឹងវត្ថុដទៃទៀត ដែលមិនទាន់ចេះដឹងឲ្យចេះដឹងឡើង ដូច្នេះឈ្មោះថា យើងមានសេចក្ដីចេះដឹង ដោយការប្រៀបធៀប ។ ពាក្យបាលីថា "តីរណបញ្ញា" ប្រែថា "សេចក្ដីចេះដឹងដោយការពិចារណាប្រៀបធៀប" ហើយមានសេចក្ដីចេះចាំយ៉ាងជាក់ច្បាស់នៅក្នុងដួងចិត្ត រហូតអស់ជីវិត មិនសូវមានការច្រឡូកច្រឡំភ្លាំងភ្លេចឡើយ ។

ហេតុនោះ ការប្រៀបធៀប ជាមេរៀនប្រចាំនៅក្នុងលោក ដែលមនុស្សគ្រប់ៗគ្នា មានបំណងចង់ឲ្យជីវិតរបស់ខ្លួនចំរើនរុងរឿងដោយប្រាជ្ញា ។ សិក្ខាកាមកុលបុត្រត្រូវព្យាយាមយកចិត្តទុកដាក់ក្នុងមេរៀននេះឲ្យយ៉ាងច្រើនជាទីបំផុត ទើបប្រាជ្ញាលូតលាស់បាន ។ មែនពិតប្រាជ្ញារបស់មនុស្សដែលនឹងចំរើនរុងរឿងបាននោះ មិនមែនទៅត្រង់រៀនសូត្រតែមួយមុខប៉ុណ្ណោះទេ ព្រោះយើងនឹងរៀនសូត្រគ្រប់វ័យមិនបាន ដោយអាជីវកម្មមិនបើកឱកាសឲ្យ សូម្បីតែក្នុងវ័យដែលកំពុងរៀន ឬក្នុងថ្ងៃ

ដែលយើងរៀន  យើងគង់មិនបានរៀនរហូតមួយរយឬពេញមួយថ្ងៃទៅបានទេ តែដែលប្រាជ្ញារបស់យើងចេះតែចំរើនទៅបាននោះ ព្រោះមានការប្រៀបធៀបជាគ្រឿងជួយជ្រោមជ្រែង  ទើបជាឱកាសនឹងជាផ្លូវឲ្យអ្នកដែលក្រីក្រមានពេលរៀនតិច  ត្រឡប់ទៅជាអ្នកប្រាជ្ញនឹងជាមនុស្សសំខាន់ក្នុងលោកបាន ។

គោលនៃការប្រៀបធៀបនេះ  មិនបានកំណត់ប្រទេស  មិនបានកំណត់ទីលំនៅ ទាំងមិនពិបាកដល់ការរៀនទេ យើងនឹងរៀនសូម្បីតែក្នុងរូងភ្នំទីវាល កណ្ដាលផ្លូវថ្នល់ រហូតទៅដល់ព្រៃភ្នំក្រំថ្មក៏បាន ត្រូវចាំទុកថា “វិជ្ជាដែលពិបាក  គេរៀនចេះដឹងឡើងបានដោយការប្រៀបធៀប” ។

ព្រោះហេតុនោះ ក្នុងការទន្ទេញក្ដី  ក្នុងការរៀនក្ដី  ក្នុងការបង្ហាត់បង្ហាញក្ដី  ក្នុងការដាស់តឿនខ្លួនឯងក្ដី  បើយើងព្យាយាមរកគោលនៃសេចក្ដីប្រៀបធៀបឲ្យបានច្រើនប៉ុន្មាន  លទ្ធផលដ៏ល្អក៏នឹងចំរើនដល់យើងបានច្រើនប៉ុណ្ណោះដែរ ។

កាលព្រះពុទ្ធអង្គទ្រង់ស្វែងរកព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ បានទ្រង់ធ្វើទុក្ករកិរិយាដោយសេចក្ដីរង្វេង  គឺទ្រង់ប្រព្រឹត្តខុសផ្លូវមជ្ឈិមាបដិបទា  ព្រះអង្គបានទទួលសេចក្ដីលំបាកស្ទើរនឹងបង់ព្រះជន្ម  តែពេលក្រោយទ្រង់ត្រឡប់ព្រះទ័យវិញ  ដោយទ្រង់ប្រើវិធីប្រៀបធៀបជាគ្រឿងដាស់តឿនព្រះអង្គឯងថា :

“ធម្មតាឈើស្រស់ដែលទទឹកជោកជាំទៅដោយជ័រ  ទាំងត្រាំនៅក្នុងទឹក  បុរសត្រូវការភ្លើងបានយកឈើនោះមកពួត  ដើម្បីឲ្យឆេះជាភ្លើង

ឡើង គេនឹងត្រូវហត់នឿយទទេ មិនអាចញ៉ាំងភ្លើងឲ្យឆេះឡើងបាន, ប្រៀបដូចបុគ្គល ដែលមានចិត្តទទឹកជោកជាំត្រាំទៅដោយកិលេស ព្រមទាំងនៅប្រឡូកប្រឡប់ដោយកាមារម្មណ៍, បុគ្គលចំពូកនេះ មិនអាចញ៉ាំងខ្លួនឲ្យដល់ទីបំផុតទុក្ខបានទេ ។

មួយទៀត ឈើស្រស់ដែលទទឹកជោកជាំទៅដោយជ័រ សូម្បីបុគ្គលលើកស្រង់ផុតពីទឹក ហើយយកទៅដាក់នៅលើគោក បុរសត្រូវការភ្លើង បានយកឈើនោះមកពួត ដើម្បីឲ្យឆេះជាភ្លើងឡើង គេមិនអាចញ៉ាំងភ្លើងឲ្យកើតឡើងបានដោយឈើនោះទេ, ប្រៀបដូចបុគ្គលមានចិត្តទទឹកជោកជាំដោយកិលេស សូម្បីចេញចាកផ្ទះគឺកាមារម្មណ៍ហើយក៏មិនអាចញ៉ាំងខ្លួនឲ្យផុតទុក្ខបាន ។

មួយវិញទៀត ឈើស្ងួតដែលដាក់នៅលើគោក បុរសត្រូវការភ្លើង បានយកឈើនោះមកពួត គេអាចពួតឲ្យឆេះជាភ្លើងឡើងបាន ព្រោះឈើនោះស្ងួតទាំងដាក់នៅលើគោក, ប្រៀបដូចបុគ្គលដែលចេញចាកកាមហើយ ទាំងបានលះតម្រេកក្នុងកាមឲ្យបានស្ងប់រម្ងាប់ដោយប្រពៃ, បុគ្គលចំពូកនេះ អាចព្យាយាមញ៉ាំងខ្លួនឲ្យផុតទុក្ខបាន" ។

កាលព្រះសម្ពុទ្ធទ្រង់ប្រៀបធៀបដាស់តឿនព្រះអង្គ ដោយព្រះអង្គឯងស្រេចហើយ ក៏ទ្រង់លើកលែងធ្វើទុក្ករកិរិយា បែរមកបំពេញព្យាយាមផ្លូវចិត្ត គឺទ្រង់ចំរើនសមថភាវនា ធ្វើចិត្តឲ្យជាសមាធិ មានអារម្មណ៍តែ១ រហូតដល់សម្រេចឈាន ៤ ញាណ ៣ អរិយសច្ច ៤ ក៏ដល់នូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ បានបរមាភិសេកជាព្រះសម្មា-

សម្តេច ព្រាកដក្នុងលោក ។ ទាំងនេះសឲ្យឃើញថា ព្រះពុទ្ធទ្រង់បានសម្រេចព្រះពោធិញ្ញាណ ក៏បានដោយការព្យាយាមរក ដែលមានការប្រៀបធៀបមកជាមុន ។

សូម្បីក្នុងសម័យដែលមុននឹងចេញទ្រង់បំពេញសត្តុបការកិច្ច គឺទ្រង់ចេញសំដែងធម៌ប្រោសសត្វ ទ្រង់ញ្ញកអស់អែកព្រះហឫទ័យ ព្រោះទ្រង់ព្រះតំរិះឃើញថា ធម៌ដែលព្រះអង្គបានត្រាស់ដឹងហើយនោះជាគុណធម៌ដ៏ល្អិតជ្រាលជ្រៅក្រៃលែង អ្នកដែលត្រេកអរក្នុងកាមគុណកម្រនឹងត្រាស់ដឹងតាមបាន តែអាស្រ័យព្រះមហាករុណាសមាយោគក្នុងពពួកសត្វដ៏ខ្ទាំងក្លាណាស់ ទើបទ្រង់ពិចារណាទៀតថា :

"បុគ្គលដែលមានកិលេសតិចតួចស្តួចស្តើងក៏មាន, មានកិលេសក្រាស់ក៏មាន, មានឥន្ទ្រិយចាស់ក្លាក៏មាន, មានឥន្ទ្រិយទន់ខ្សោយក៏មាន, ជាបុគ្គលដែលគួរប្រៀនប្រដៅឲ្យដឹងបានដោយងាយក៏មាន, ដឹងបានដោយក្រក៏មាន ប្រៀបដូចជាបទុមជាតិ (ផ្កាឈូក) ដែលកើតក្នុងទឹក បំរើនក្នុងទឹក មានទឹកចិញ្ចឹមបំរុងទុក ផ្កាខ្លះលិចនៅក្នុងទឹក ខ្លះបិតនៅត្រឹមទឹក ខ្លះបិតនៅផុតពីទឹក, បណ្តាផ្កាឈូកទាំងនោះ ផ្កាឈូកដែលបិតនៅផុតពីទឹក ត្រូវកំដៅព្រះអាទិត្យនឹងរីកក្នុងថ្ងៃនេះ ដែលបិតនៅត្រឹមទឹកនឹងរីកក្នុងថ្ងៃស្អែក ដែលបិតនៅក្នុងទឹកនឹងរីកក្នុងថ្ងៃក ។ ទៅ ផ្កាឈូកដែលនឹងរីកមានអាការផ្សេងគ្នាដូចម្តេចមិញ វេនេយ្យសត្វក៏មានឧបនិស្ស័យផ្សេងគ្នាដូច្នោះដែរ" ។

កាលទ្រង់ប្រៀបធៀបឃើញប្រច័ក្សដោយព្រះញាណដូច្នេះហើយ ក៏ទ្រង់បើកផ្លូវព្រះមហាករុណាឲ្យជាបុរេចារិកតទៅ ហើយទ្រង់សំដែងធម៌ប្រោសសត្វ រហូតដល់ស្ដេចចូលកាន់ខន្ធបរិនិព្វាន ។ សូម្បីសាសនធម៌ពាក្យប្រៀនប្រដៅ ដែលប្រជុំចុះក្នុងព្រះត្រៃបិដកទាំងអស់ ក៏មានពាក្យប្រៀបធៀបជាឧទាហរណ៍ ច្រើនហួសវិស័យពុំអាចនាំមកពណ៌នាក្នុងទីនេះឲ្យអស់ដើងបាន ទីងសាធកៈតែព្រះបច្ចិមវាចា ក្នុងអវសានកិច្ចថាៈ

"ម្នាលភិក្ខុទាំងឡាយ! តថាគតជាស់តឿនលោកទាំងឡាយថា សង្ខារទាំងឡាយមានសេចក្ដីអស់ទៅទីងសាបសូន្យទៅជាធម្មតា, លោកទាំងឡាយចូរញ៉ាំងសីល, សមាធិ, បញ្ញាឲ្យដល់ព្រមដោយសេចក្ដីមិនប្រមាទចុះ ព្រោះថាធម៌ទាំងឡាយ ដែលជាកុសលទាំងអស់មានសេចក្ដីមិនប្រមាទជាឫសគល់ មានសេចក្ដីមិនប្រមាទជាទីប្រជុំចុះ, សេចក្ដីមិនប្រមាទ បណ្ឌិតពោលថា ជាធម៌ដ៏ប្រសើរលើសលប់ជាងធម៌ទាំងអស់ ប្រៀបបីដូចស្នាមជើងនៃសត្វទាំងឡាយ ដែលដើរលើផែនដីទាំងប៉ុន្មាន ស្នាមជើងសត្វទាំងអស់នោះ តែងប្រជុំចុះក្នុងស្នាមៈជើងនៃដំរី ស្នាមជើងដំរី បណ្ឌិតពោលថា ជាធំលើសលប់ជាងស្នាមជើងសត្វទាំងអស់" ។

ដែលពោលមកទាំងនេះសំដែងឲ្យឃើញថា រឿងប្រៀបធៀបជាមេរៀនដ៏ធំសំខាន់ក្រៃលែង សូម្បីតែព្រះពុទ្ធអង្គជាអគ្គបុគ្គលដ៏ធំលើសលប់ជាងអ្នកប្រាជ្ញរាជបណ្ឌិតក្នុងលោក កាលស្ដេចជិតបរិនិព្វាន បានទ្រង់ជាស់តឿនភិក្ខុសង្ឃដោយធម៌ដែលមានពាក្យប្រៀបធៀបជាប់នៅផង ដូចបានពោលមកហើយ ព្រោះដូច្នោះយើងទើបឃើញថា ការប្រៀប

ធៀបនេះ ជាមេរៀនដែលត្រូវតែមានខានមិនបាន ទាំងផ្លូវលោកទាំងផ្លូវធម៌ សំរាប់វិនិច្ឆ័យសេចក្ដីសន្ទិះសង្ស័យ ភូតករកុហកអាក្រក់ល្អគ្រប់យ៉ាង ដូចបានពោលមកហើយពីខាងដើម ។

សមដូចបុរាណបណ្ឌិតបានឲ្យឱវាទថា:

១— កូនអើយកូនសំឡាញ់ អ្នកបូរគិតកាញ់មើលសត្វខ្លា
សូម្បីសាហាវកាចយ៉ាងណា ក៏មិនពាធាកូនប្រពន្ធ ។
២— បុណ្យអើយបុណ្យលើសលប់ គិតគ្រប់គួរកោតសត្វខ្លាញី
ស្នេហាកូនឈ្មោលពេកពេញទី ការីស៊ូបួរទាល់អស់ជន្ម ។
៣— កូនអើយកូនសុនក្ខ មើលបែបបក្សាក្នុងព្រឹក្សព្រៃ
រកភោជន៍ឲ្យគូក្នុករំពៃ បានវៃនាំមកឲ្យប្រពន្ធ ។
៤— កូនអើយកូនឱរស កូនស្រស់មើលបែបបក្សីញី
បីទុកល្អងលោមឲ្យសាមគ្គី យកស្លាបបក់វីបោសប្ដី ។

ទាំងនេះយើងឃើញបានថា ឱវាទ ១ បទ ៗ សុទ្ធតែប្រដៅដោយលើកយកនិស្ស័យសត្វមកឲ្យយើងគិតប្រៀបធៀបមើល ដើម្បីឲ្យយើងចូលចិត្តបានងាយ ៗ យើងឃើញថាជាការងាយយល់ពិតមែន គ្រាន់តែបានឃើញឬបានឮប៉ុណ្ណោះ ក៏អាចបង្អោនចិត្តយើងឲ្យទន់ទៅតាមនិស្ស័យសត្វទាំងនោះបាន ។

មួយទៀត បណ្ដាសុភាសិតដែលអ្នកប្រាជ្ញប្រៀនប្រដៅពួកនិស្សិត, សុភាសិតខ្លះ ក៏លើកយកគុណនៃវិទ្យាមកប្រៀបធៀបឲ្យសិស្សស្ដាប់ដែរ ដូច្នេះថា:

វិទ្យាគ្រឿងសួយ ហើយថែមទាំងជួយ អ្នកខ្សត់ថោកទាប ទាំងរូបអាក្រក់ ឲ្យមានសុភាព ល្អឡើងជាកប់ ក្នុងទីប្រជុំ ។

វិទ្យាជាទ្រព្យ សំកប់នៅជាប់ ខ្លួនគ្មានរលំ មានផលវិវឌ្ឍន៍ ទៀងទាត់ឧត្តម មិនលះបង់អ- ម្ចាស់វិទ្យាឡើយ ។

វិទ្យាលោកប្រៀប ដូចសោនៅទៀប ជិតដៃបង្កើយ សំកប់ចាក់យក យសស័ក្តិជាត្រើយ សម្បត្តិផងហើយ សន្តានព្រៀងលាន ។

វិទ្យាគ្រូអ្នក ប្រាជ្ញបណ្ឌិតជាក់ ករីមានញាណ មនុស្សទាំងពិភព ស្រឡាញ់រាប់អាន អស់លោកដែលមាន បំណេះវិជ្ជា ។

មួយវិញទៀតថា:

វិទ្យាប្រៀបដូចកំឡាំងកាយ សុចរិតប្រៀបប្រាយដូចគ្រោះពាំង
ការពារអាវុធដូចទាំង សំកប់ពាក់ងអ្នកនោះណា ។
បញ្ញាប្រៀបដូចគ្រឿងអាវុធ ទនថ្នាំមុះមុតក្រៃសោះសា
សតិប្រៀបដូចខែលរនែក ការពារអាវុធបច្ចាមិត្រ ។

អ្នកប្រាជ្ញដែលសរសើរកិត្តិនិយមនៃវិទ្យាគុណ ដោយមានការប្រៀបធៀបគ្រប់ៗមេបទ នេះសំដែងឲ្យឃើញថាការប្រៀបធៀបនោះជាគុណជាតិដ៏សំខាន់ក្នុងការពិសោធន៍ស្រាវជ្រាវរកសេចក្តីពិត និងសមុដ្ឋាននៃរបស់ពិត រហូតដល់ការសិក្សារៀនប្រដៅគ្រប់យ៉ាង, ព្រោះហេតុនោះ ការប្រៀបធៀប លោកទើបចាត់ជាមេរៀនដ៏សំខាន់ ប្រចាំនៅក្នុងលោកដោយខានមិនបានយ៉ាងដាច់ខាត ។

# ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា

ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ-សុម្ភាជ ធម្មារាមៈ

សាស្ត្រាចារ្យនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នៅភ្នំពេញ,
សមាជិកឆ្លើយឆ្លងនៃសាលាបារាំងសែសប៉ែកចុងបូព៌ាប្រទេស,
សមាជិកនៃគណៈកម្មការវប្បធម៌ខ្មែរ បានតែងជាភាសាបារាំង

លោក ទៀង-តៃ-ឈុន ក្រមការដើមខ្សែ ប្រែជាភាសាខ្មែរ

ប្រទេសកម្ពុជា ជាប្រទេសមួយតូច ទាំងមនុស្សក៏មានស្ដួចស្ដើង ប៉ុន្តែបើយកប្រទេសនេះទៅធៀបនឹងប្រទេស ដែលកាន់ព្រះពុទ្ធសាសនាដូចគ្នានៅក្នុងសាកលលោក ឃើញថាជនជាតិខ្មែរយើង គោរពព្រះពុទ្ធ-សាសនា ដោយស្រះស្រួលគ្នាជាងប្រជាជនក្នុងប្រទេសទាំងនោះពិតប្រាកដ, បន្ទាប់មកទៀត គេពោលដោយឥតញញើតមាត់ហើយគ្មានបំផ្លើសផង ថាខ្មែរយើង ៩៩ ភាគរយកាន់លទ្ធិព្រះពុទ្ធសាសនា ។

យើងដឹងច្បាស់ហើយថាកាលពី ៤០០ ឆ្នាំមុននេះ ស្រុកចម្បា ដែលឋិតនៅត្រង់ប្រទេសយៀកណាមកណ្ដាលសព្វថ្ងៃនេះ មានប្រជា-ជនជាតិជ្វាទឹងចាមជាកូនចៅនៃអ្នកកាន់សាសនាអ៊ីស្លាម ដែលចេញចាកស្រុកចម្បា នាំយកសាសនាអ៊ីស្លាម ចូលមកក្នុងប្រទេសកម្ពុជា, នៅពេលដដែលនេះ ប្រជាជនជាតិអឺរ៉ុបក៏បាននាំយកសាសនាគ្រិស្តចូលមកប្រទេសកម្ពុជាដែរ ។ ពួកបរិស័ទនៃសាសនាខាងលើនេះ បានសាងព្រះវិហាររបស់ខ្លួននៅជិត ៗ ព្រះវិហារខ្មែរ តែជនជាតិខ្មែរដោយ

គាប់ចិត្តនឹងសាសនាព្រះពុទ្ធ យ៉ាងស៊ប់ស្ងួន កំគ្មានបែរគំនិតទៅរកសាសនាអ៊ីស្លាមនឹងសាសនាគ្រិស្តឡើយ ។

តាមប្រវត្តិសាស្ត្រ: មហាក្សត្រនឹងមន្ត្រីធំៗ សម័យនោះ បាននាំយកសាសនាព្រាហ្មណ៍ចូលមកប្រទេសកម្ពុជាយើង គឺតាំងពីដើមសកពជនៃសាសនាគ្រិស្ត, ចំណែកឯសាសនាព្រះពុទ្ធវិញ កំបានជ្រាបចូលមកស្រុកខ្មែរក្នុងវាងឆ្នាំ ៤៥០ ក្រោយព្រះយេស៊ូគ្រិស្ត គឺជាព្រះពុទ្ធសាសនាដែលគេហៅថាថេរវាទ ឬទក្ខិណនិកាយ ។

ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ចាប់មានពន្លឺរស្មីព្រោងព្រាយឡើងតាំងពីសតវត្សទី ១៣ ក្នុងរជ្ជកាលនៃព្រះបាទជ័យវរ្ម័នទី ៧ ។ ព្រះបាទជ័យវរ្ម័នទី ៧ មិនត្រឹមតែជាមហាក្សត្រខ្លាំងពូកែខាងសឹកសង្គ្រាមប៉ុណ្ណោះទេ ទ្រង់ប្រសប់គ្រប់គ្រងផែនដីណាស់ទៀតផង ទ្រង់បានប្រារព្ធឲ្យរៀបច្បាប់គ្រប់តំណែងសំរាប់ព្រះនគរ ដែលធំទូលាយឲ្យចំរើនឡើង ហើយទ្រង់ឲ្យសាងប្រាសាទសុទ្ធតែថ្ម ដើម្បីឧទ្ទិសចំពោះព្រះសមណគោតមជាអម្ចាស់នៃយើង ។ ឯប្រាសាទដែលល្បីឈ្មោះជាងគេនោះគឺប្រាសាទបាយ័ន (បញ្ជន់) ប្រាសាទនេះល្អស្អាតមួយ ហើយដែលនាំឲ្យសាកលលោកស្ញប់ស្ញែង ។

នៅខាងមុខនេះ ខ្ញុំនឹងអធិប្បាយលាតត្រដាងអំពីស្ថាបនកម្មនៃពុទ្ធបុរសខ្មែរដោយសង្ខេប ជូនអស់លោកអ្នកអាន ៖

ប្រាសាទអង្គរ បើយើងក្រឡេកមើលក្លាមទៅឃើញជាដុំថ្មជាក់គរលើគ្នា ប៉ុន្តែបើយើងដើរចូលទៅជិតនឹងឃើញជារបៀង បរិវេណ ឬ

ប្រាសាទតូចៗ ពាសពេញទៅវិញ ហើយគ្រឹះស្ថានទាំងនេះនាំឲ្យយើងនឹកឃើញថា មហាក្សត្រប្រទេសកម្ពុជា កាលពីដើមមានភោគសម្បទនិងឫទ្ធិចេស្តា ហើយចេះគ្រប់គ្រងប្រទេសដែលធំទូលាយអស្ចារ្យ ។

កាលពីសតវត្សទី ១២-១៣-១៤ ដែនកូសាំងស៊ីនទាំងមូលនិងទ្វីបអាស៊ីភាគអាគ្នេយ៍មួយផ្នែក ក៏ជាដែនដីប្រទេសកម្ពុជាដែរ ។ តាំងពីយូរណាស់មកហើយ គេពុំសូវដឹងប្រវត្តិសាស្ត្រនៃសិល្បៈខ្មែរដោយច្បាស់លាស់ទេ គេគ្រាន់តែដឹងថាសិល្បៈនេះកើតមានឡើងជាយូរអង្វែងហើយ ។ ដោយហេតុដែលគេឃើញថាប្រាសាទអង្គរ គេសាងឧទ្ទិសថ្វាយអាទិទេពតាមទំនៀមឥណ្ឌា ហើយនិងគេឃើញមានសិលាចារឹកជាអក្សរសំស្ក្រឹតនាំឲ្យគេអាចសន្និដ្ឋានបានយ៉ាងដាច់ថា ស្ថាបនកម្មខ្មែរ ជាសំណាកចម្លងអំពីស្ថាបនកម្មឥណ្ឌា ។ ប៉ុន្តែការស្មាននេះមិនត្រូវទេ ព្រោះជនជាតិបរទេសដែលគេបានទៅបំពេញបេសកកម្ម នៅប្រទេសឥណ្ឌាបានទទួលដឹងតាមផ្លូវការថាស្ថាបនកម្មឥណ្ឌា មានចិត្តគំនិតនិងការគាក់តែងនឹងទ្រង់ទ្រាយផ្សេងស្រឡះពីស្ថាបនកម្មរបស់ខ្មែរ ។ ក្រោយពីនោះមកក្រោមឥទ្ធិពលឥណ្ឌា ទើបស្ថាបនកម្មព្រះពុទ្ធសាសនាជ្រាបចូលមកប្រទេសកម្ពុជា ។

រវាង ព. ស. ៤៥០ ក្រោយព្រះយេស៊ូគ្រិស្ត យើងសង្កេតឃើញថា ស្ថាបនកម្មបានផ្លាស់ប្រែទ្រង់ទ្រាយយ៉ាងច្បាស់លាស់ ឧទាហរណ៍ដូចជាពុទ្ធរូបដែលកើតមានឡើងក្រោយរូបចម្លាក់នៃព្រះឥសូរព្រះព្រហ្ម ហើយនិងព្រះនារាយណ៍ ។ យើងសូមរំលឹកដល់អ្នកដើរមើលប្រទេសថា ក្នុង

ចំណោមប្រាសាទអង្គរ មានតែប្រាសាទតាកែវមួយទេដែលគ្មានចម្លាក់អ្វីសោះ គ្រាន់តែមានចលនាវិលវៀន ៥ ជាន់នៅលើកំពូលប៉ុណ្ណោះ ។ ប្រាសាទបក្សីចាំក្រុងជាប្រាសាទមួយយ៉ាងតូច ឋិតនៅមុខទ្វារខាងត្បូងក្រុងអង្គរធំ ហើយមានទ្រង់ទ្រាយស័ក្តិសមអស្ចារ្យ ។ តាមគេស្មានថា: ស្ថាបនកម្មខ្មែរកើតមានឡើងខ្លះ អំពីចិត្តនឹងគំនិតមុនកសាងប្រាសាទដែលយើងបានអធិប្បាយខាងលើនេះ ។ ស្តេច 'អាឡិក្សង់ ឡឺក្រង់'' បាននាំសិល្បៈ ''ក្រិច'' ចូលទៅប្រទេសឥណ្ឌា ហើយគេស្មានថាជាង ''ក្រិច'' ឬជាងឥណ្ឌាដែលនៅរៀនសូត្រក្នុងសាលានៅប្រទេស ''ក្រិច'' បានឆ្លាក់ព្រះពុទ្ធរូបជាដំបូង ។ ហេតុនេះហើយបានជាព្រះពុទ្ធរូបដែលគេបានឆ្លាក់មុនគេ នាំឲ្យទឹកដល់ព្រះរូបនៃព្រះបាទ ''អាប៉ូលឡុង'' ។ នៅទីបំផុតនេះ គេដឹងថាក្បាច់ចម្លាក់ខ្មែរ ដែលមានកំណើតមុនគេ ហើយដែលមាននៅក្នុងរាងសតវត្សទី ៩ នឹងទី ១០ ជាចម្លាក់មានគុជារស ហើយគេអាចយកទៅផ្ទឹមបានជាមួយនឹងចម្លាក់ប្រាសាទនៅប្រទេសទិសខាងលិច ដែលសាងនៅក្នុងរាងសតវត្សទី ១៧ នឹង ១៨ ។

នៅពេលនោះ រឿងព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាមានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងកោះសេរីលង្កា ដែលជាទីកន្លែងពុទ្ធ-សាសនាខាងថេរវាទ ចំណែកខាងផ្លូវទូតវិញ ប្រទេសកម្ពុជានេះមានការទាក់ទងជាមួយនឹងប្រទេសចិន ។ ពិតមែនតែការទាក់ទងខាងលើនេះមានដំណើររាក់រអួលនៅក្នុងសម័យខ្លះ តែមិនអាចនាំឲ្យបាត់មេត្រីភាពឡើយ នៅតែមានហូរហែរហូតមកដល់សព្វថ្ងៃនេះ ។

តាំងពីសតវត្សទី ៧ ក្រោយព្រះយេស៊ូគ្រិស្ត បើគេនាំយកឯកសារខ្លះមកពិនិត្យមើលឲ្យម៉ត់ចត់ទៅឃើញថា ភាសាខ្មែរគ្មានផ្លាស់ប្តូរគោលការណ៍ណាមួយសោះ មានតែលូតលាស់ចំរើនឡើង ៗ ជួនកាលមានពាក្យពេចន៍ខ្លះចូលទៅច្នឹងមក ជាមួយនឹងប្រទេសដែលជាអាណានិគម ឬដែលជាអាណាព្យាបាលរបស់កម្ពុជរដ្ឋ ៗ ប៉ុន្តែពាក្យបរទេសទាំងនោះពុំបានធ្វើឲ្យពាក្យពេចន៍ខ្មែរប្រែប្រួលឡើយ ពាក្យពេចន៍ខ្មែរស្ថិតបិតទៅតាមភាពដើមហើយច្រើនតែជាពាក្យព្យាង្គទោល ចំពោះពីពាក្យទាំងនោះមានដើមកំណើតអំពីបរទេស ជាពាក្យពហុព្យាង្គក៏ដោយក៏ច្រើនតែប្រែមកជាពាក្យឯកព្យាង្គតាមទម្លាប់ភាសាខ្មែរវិញ ៗ

គម្ពីរខ្មែរបុរាណច្រើនតែធ្វើពីស្លឹករឹត ហើយមានភាសាសំស្ក្រឹតនឹងបាលី ៣០ ភាគរយ ៗ គម្ពីរបែបនេះនាំឲ្យជនជាតិខ្មែរ ឬ បរទេសដែលមានកំណើតនៅប្រទេសអាស៊ី និយាយគ្នាយល់ទៅវិញទៅមកបានយ៉ាងស្រួល ៗ យើងសូមបញ្ជាក់ថែមទៀតថា អត្ថបទបុរាណ ឬបច្ចុប្បន្នច្រើនតែអធិប្បាយពីរឿងព្រះពុទ្ធសាសនាដែលមានសព្វថ្ងៃនេះ ៗ

ដើមកំណើតនៃអក្សរខ្មែរ មានមកពីប្រទេសឥណ្ឌាខាងត្បូង ៗ អក្សរដែលមានតំនូសរាយ ឬពិបាកទុកដូចជាព្យាង្គមួយ ៗ ព្យញ្ជនៈនីមួយ ៗ មានស្រៈមួយ បើគ្មានស្រៈទេ ព្យញ្ជនៈនោះនឹងចេញសំឡេងពុំកើត កាលណានៅឆ្ងាយតែឯង, តែមានអក្សរខ្លះស្រៈនោះត្រូវបាត់អង្គ ៗ

ខ្មែរនិយាយភាសាខ្មែរដែលពោលសារុបខាងលើនេះ ហើយដែលប្រទេសនឹងជនជាតិខាងលិចឲ្យឈ្មោះថា ប្រជាជនកម្ពុជា ៗ

សព្វថ្ងៃ ខ្មែរមានចំនួន ៤.៥០០.០០០ នាក់ ដែលបែកញែកនៅគ្រប់កន្លែងក្នុងដែនដីខ្មែរ ។ នៅក្នុងប្រទេសខ្មែរ, គេឃើញជនជាតិយួន ៣៥០.០០០ នាក់, ជនជាតិចិន ២០០.០០០ នាក់, ជនជាតិចាមនិងជ្វា ១០០.០០០ នាក់, ជនជាតិលាវ ២០.០០០ នាក់, ជនជាតិកូឡា ២០០ នាក់ ហើយនិងជនជាតិអឺរ៉ុបច្រើនពាន់នាក់ តែកាត់គេច្រើនបាក់ង ។

នៅប្រទេសកម្ពុជាមានបព្វជិតជាគណៈថេរវាទ ២ គឺ

១— គណៈមហានិកាយ

២— គណៈធម្មយុត្តិកនិកាយ

គណៈទាំងពីរខាងលើនេះ ខុសគ្នាខ្លះតែត្រង់របៀបពោលជាភាសាបាលី និងការប្រព្រឹត្តតាមទំនៀមទម្លាប់ខ្លះៗ ប៉ុណ្ណោះ ។

ព្រះរាជអាណាចក្រកម្ពុជា មានវត្តចំនួន ២.៨០០, មានភិក្ខុសាមណេរចំនួន ៨២.០០០ អង្គ; ក្នុងព្រះវិហារនៃវត្តនីមួយ ៗ គេបានសាងព្រះពុទ្ធរូបដំកល់ទុក ដើម្បីជាទីគោរពនៃព្រះសង្ឃ-ភិក្ខុ-សាមណេរ ដែលចូលមកជ្រក ។ ព្រះសង្ឃទាំងនោះមានសមណសក្តិទីពជាគណៈទីឋានានុក្រម ដែលតាំងតាមព្រះរាជក្រឹត្យត្រឹមត្រូវ ។

ព្រះពុទ្ធសាសនាយើងបានចំរើនរុងរឿងឡើង ដោយថ្វីព្រះហស្តព្រះមហាក្សត្រិយ៍និងកម្លាំងព្រះរាជរដ្ឋាភិបាល ដែលកាន់លទ្ធិព្រះពុទ្ធសាសនាឥតមានល្អៀង ។ កាលពីឆ្នាំ ១៩១៤ ព្រះរាជានិងព្រះរាជរដ្ឋាភិបាលបានសង់សាលាបាលីជាន់ខ្ពស់នៅទីក្រុងភ្នំពេញ ។

(មានត)

# ឥទ្ធិបាទធម៌

ព្រះមហា អ៊ុម - ជើង វត្តសារាវ័ន

រៀបរៀង

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការ ចំពោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយគោរព) ។*

*វេលានេះ អាត្មាភាព សូមលើកយកឥទ្ធិបាទធម៌ គឺធម៌ជាជំហរនៃឫទ្ធិ ដែលទុកជាដើមទងសម្រាប់ធ្វើសេចក្តីប្រាថ្នាឲ្យសម្រេច មកសំដែងដើម្បីជាសណ្តាប់នៃសាធុជន តែមុននឹងសំដែង សូមអធិប្បាយជម្រាលសេចក្តីដោយសង្ខេបសិន ដូចតទៅនេះ :*

*មនុស្សក្នុងលោកសន្និវាសនេះ មានច្រើនជាតិច្រើនសាសន៍ ច្រើនភាសា, មនុស្សទាំងអស់នោះ ទោះជាតិណាក្តី ប្រភេទណាក្តី សុទ្ធតែមានសេចក្តីប្រាថ្នាមានបំណងក្នុងសន្តានជានិច្ចគ្រប់ៗ គ្នា, ប្លែកតែត្រង់មនុស្សខ្លះ ចង់បាននេះ ខ្លះចង់បាននោះ ៗ តែការចង់បាន នៃមនុស្សនោះ ជួនណាក៏បានសម្រេច ជួនណាក៏មិនបានសម្រេច, ដែលបានសម្រេចសមតាមបំណងនោះ មកពីមានអង្គនៃធម៌ជាគ្រឿងធ្វើឲ្យសម្រេចសេចក្តីប្រាថ្នាគ្រប់គ្រាន់, ដែលមិនបានសម្រេចមកពីខ្វះខាតមិនគ្រប់គ្រាន់អង្គណាមួយ ៗ ឯអង្គនៃធម៌សម្រាប់ធ្វើសេចក្តីប្រាថ្នាឲ្យសម្រេចសមតាមបំណងនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា មាន ៤ យ៉ាង គឺ*

១ — ឆន្ទៈ សេចក្ដីប្រាថ្នា, បំណងយ៉ាងមុតមាំ;

២ — វីរិយៈ សេចក្ដីព្យាយាម, ប្រឹងប្រែង, ខ្មីឃ្មាត;

៣ — ចិត្តៈ ការគិត, ការយកចិត្តទុកដាក់មិនទម្លាក់ធុរៈចោល;

៤ — វីមំសា ការពិចារណា, ការត្រិះត្រិះ ។

ធម៌ទាំង ៤ យ៉ាងនេះឈ្មោះថា ឥទ្ធិបាទ ប្រែថា "ធម៌ជាជំហាននៃឫទ្ធិ", វេលានេះ សូមអធិប្បាយធម៌នោះមួយម្ដង ៗ ដូចតទៅនេះ ៖

១ — ឆន្ទៈ "សេចក្ដីប្រាថ្នា, សេចក្ដីប៉ុនប៉ង, ការចង់បាន, ការពេញចិត្ត" បែកជាពីរផ្នែកគឺ ៖

ក) សេចក្ដីប្រាថ្នាចង់បាន នូវសម្បត្តិទ្រព្យជាសវិញ្ញាណកទ្រព្យ មានគោ, ក្របី, ដំរី, សេះជាដើម ឬជាអវិញ្ញាណកទ្រព្យ មានមាស, ប្រាក់, កែវ, កង, ផ្ទះសំបែង, ស្រែ, ចំការ, ច្បារដំណាំ, គ្រឿងអលង្ការសម្រាប់ប្រដាប់តាក់តែងកាយ ទីងសំពត់អាវជាដើម ។

ខ) សេចក្ដីប្រាថ្នា ឬការចង់បំពេញកងការកុសលណាមួយក្ដី ចង់រេះដឹងចំណេះវិជ្ជាណាមួយ ជាវិជ្ជាសម្រាប់ប្រកបកិច្ចការចិញ្ចឹមជីវិតក្នុងបច្ចុប្បន្នក្ដី ចង់រេះដឹងចំណេះវិជ្ជាក្នុងពុទ្ធសាសនា ជាច្បាប់សម្រាប់ទូន្មានខ្លួន តាមបែបក្នុងសាសនាក្ដី សុទ្ធតែហៅថា សេចក្ដីប្រាថ្នា ការចង់បានទាំងអស់ ។ សេចក្ដីប្រាថ្នា ការចង់បាន ទាំងពីរផ្នែកនេះ បើកើតមានដុះដាលពេញគ្រប់គ្រាន់ក្នុងខន្ធសន្ដាន បព្វជិត គ្រហស្ថ បុរសស្ត្រី កាន់តែច្រើនឡើងៗ រហូតដល់អត់ទ្រាំមិនបាន ហៅថា ឆន្ទិទ្ធិបាទ

"សេចក្តីប៉ុនប៉ងជាដំហរឬដំហាននៃបុគ្គ ដែលអាចឲ្យសម្រេចសេចក្តីប្រាថ្នាបាន" ។ នេះជាអង្គទី ១ ។

២.– វិរិយៈ "សេចក្តីព្យាយាម, សេចក្តីខ្មីឃ្មាត" បានដល់កិច្ចការអ្វីៗ ឬចំណេះវិជ្ជាអ្វីៗ ដែលបុគ្គលណាមួយជាគ្រហស្ថក្តី បព្វជិតក្តី មានសេចក្តីប្រាថ្នា សេចក្តីប៉ុនប៉ង ចង់ប្រកបកិច្ចការ ចង់ចេះដឹងចំណេះវិជ្ជានោះៗ ហើយផ្គងចិត្តយ៉ាងម៉ឺងម៉ាត់ប្រឹងធ្វើប្រឹងរៀន ដោយមិនបណ្តែតបណ្តោយបណ្តោះបណ្តែការធ្វើការរក ការរៀននោះ មិនឲ្យខណៈកន្លងទៅទទេៗ គឺមិនអាងថា ពេលនេះនៅព្រឹកណាស់ ចាំដល់ថ្ងៃត្រង់, ដល់ថ្ងៃត្រង់ថាចាំល្ងាច, ដល់ល្ងាចថាចាំស្អែក, ដល់ស្អែកថាចាំខានស្អែក, ដល់ខែនេះ ថាចាំខែក្រោយ, ដល់ឆ្នាំនេះ ថាចាំឆ្នាំក្រោយ, ដល់អាយុប៉ុណ្ណេះ ថាចាំអាយុប៉ុណ្ណោះ សឹមចាប់ធ្វើកិច្ចការនោះៗ សឹមរៀនវិជ្ជានោះៗ; បើមានការអាង ការបណ្តោះបណ្តែយ៉ាងនេះ មិនរាប់ថា សេចក្តីព្យាយាមឡើយ; លុះតែបុគ្គលណាមួយមានចិត្តក្លាហានមោះមុត មិនខ្លាចនឿយហត់ អត់ទ្រាំសេចក្តីងោកងុយ អត់ទ្រាំក្តៅត្រជាក់ អត់ទ្រាំសេចក្តីស្រេកឃ្លាន, មានចិត្តក្លៀវក្លា ក្នុងការរៀនសូត្រ ក្នុងការងារដែលខ្លួនត្រូវធ្វើត្រូវប្រកប មិនដំអក់ទំរន់មិនបង្អែបង្អង់ តែងតែមានចិត្តរវៀសរវៃខិតខំរៀនសូត្រ ខ្មីឃ្មាតធ្វើការគ្រាតែបានសម្រេចដូចបំណង ទើបសមតាមសុភាសិតថា ភយមេជេវ បុរិសោ យាវ អត្ថស្ស និប្ផទា "កើតមកពេញអង្គជាបុរសស្ត្រី ត្រូវតែព្យាយាម គ្រាតែសម្រេច

ប្រយោជន៍" ។ សុភាសិតនេះ បំភ្លឺឲ្យយល់ថាការណ៍ដែលនឹងសម្រេចប្រយោជន៍ទៅបានដោយសេចក្ដីព្យាយាម ។ ឯប្រយោជន៍នោះមាន ២ យ៉ាង គឺ ប្រយោជន៍ក្នុងលោកិយនិងប្រយោជន៍ក្នុងបរលោក ។

១– ប្រយោជន៍ក្នុងលោកិយ គួយ៉ាងដូចការប្រកបការងារ ឬការរៀនសូត្រវិជ្ជាណាមួយ ដរាបដល់បានសម្រេចប្រយោជន៍ល្អ តាមបំណងក៏ព្រោះតែបុរសបុគ្គលនោះមានព្យាយាមធ្វើ ព្យាយាមរៀន ឬក៏ប្រកបកិច្ចការដែលគួរប្រកប មានធ្វើស្រែ ចំការ ត្បាញរវៃ ធ្វើជាងមាស ជាងប្រាក់ជាដើម ហើយសម្រេចបានជាផលប្រយោជន៍ដល់ខ្លួន គឺបានជាអ្នកមានទ្រព្យសម្បត្តិ បានជាសេដ្ឋីគហបតីសម្បូរដោយសម្បត្តិស្តុកស្តម្ភ ក៏ព្រោះសេចក្ដីព្យាយាម ។ ប៉ែកខាងវិជ្ជាចំណេះដែលអ្នកប្រាជ្ញទាំងឡាយអំពីបុរាណក្ដី អ្នកប្រាជ្ញទាំងឡាយក្នុងបច្ចុប្បន្នក្ដី ដែលលោកបានសិក្សាត្រាតែចេះដឹងហើយបានប្រយោជន៍ផ្ទាល់ខ្លួន ទាំងបានធ្វើប្រយោជន៍របស់លោកនោះ ឲ្យជាប្រយោជន៍សាធារណៈថែមទៀត គឺបានរួបរួមតាក់តែងចងក្រងជាគម្ពីរដីកា ក្បួនច្បាប់ផ្សេងៗ សំដែងសេចក្ដីខុសត្រូវ ផ្លូវអាក្រក់ល្អឲ្យយើងសិក្សាបានចេះដឹងតាមផង ក៏កើតឡើងព្រោះសេចក្ដីព្យាយាម បើមិនមានការព្យាយាមរៀន ព្យាយាមគិត ព្យាយាមធ្វើទេ មុខជាមិនបានសម្រេចប្រយោជន៍នោះៗឡើយ ។ សមដូចពុទ្ធភាសិត ១ កន្លែងទៀត ក្នុងគម្ពីរធម្មបទថា:

យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ

«បុរសបុគ្គលណា ជាអ្នកខ្ជិលច្រអូស គ្មានសេចក្តីព្យាយាម បើទុក ជារស់នៅ ១០០ ឆ្នាំ (ក៏ឥតបានការអ្វី) ឯបុគ្គលមានជីវិតរស់នៅ សូម្បីតែ ១ ថ្ងៃ បើជាអ្នកមិនខ្ជិលច្រអូស ជាអ្នកមានសេចក្តីព្យាយាមមុតមាំ ក៏ប្រសើរជាងអ្នកដែលរស់នៅ ១០០ ឆ្នាំនោះ» ។

ហេតុដូច្នេះ បុគ្គលអ្នកប្រាថ្នាប្រយោជន៍ គួរតែមានព្យាយាម ប្រឹងប្រែងធ្វើការរកបរចិញ្ចឹមជីវិតរាល់ថ្ងៃ តាមមុខការនាទីដែលត្រូវធ្វើ, ព្យាយាមសិក្សារៀនសូត្រ តាមចំណេះវិជ្ជាដែលត្រូវរៀន ដរាបដល់ បានទ្រព្យសម្បត្តិ បានចេះដឹង ដែលជាផលកើតមកអំពីហេតុ គឺសេចក្តីខ្មីឃ្មាតប្រឹងប្រែងប្រកបការងារ និងការរៀនសូត្រនោះៗ ។ មានពុទ្ធភាសិត ១ កន្លែងទៀតថា វីរិយេន ទុក្ខមច្ចេតិ "បុរសបុគ្គលឆ្លងសេចក្តីទុក្ខបាន ដោយសារសេចក្តីព្យាយាម" គឺថា សេចក្តីទុក្ខគ្រប់ថ្នាក់គ្រប់ប្រភេទ ដែលកើតអំពីការស្រេកឃ្លានក្តី កើតអំពីការរកចិញ្ចឹមជីវិតក្តី ដែលជាហេតុធ្វើចិត្តឲ្យក្រៀមក្រំឲ្យស្លុតស្លប់សញ្ជប់សញ្ជឹង គេនឹងបំបាត់ទុក្ខនោះទៅបាន ដោយសារសេចក្តីព្យាយាមពេញបរិបូណ៌ មិនខ្វះខាត ។ ការបានទូវសេចក្តីសុខសេចក្តីចំរើនក្នុងបច្ចុប្បន្នជាតិនេះ ហៅថាប្រយោជន៍ក្នុងលោកិយ ។

២— ប្រយោជន៍ក្នុងបរលោក បានដល់បុណ្យកុសលដែលបុគ្គលត្រូវធ្វើ ត្រូវកសាង ទុកជាយាន ជាស្បៀងអាហារ ឬជាគ្រឿងអលង្ការរបស់ចិត្ត សម្រាប់ធ្វើកុំឲ្យចិត្តកំព្រើកំព្រា កុំឲ្យចិត្តគ្មានទីពឹង កុំឲ្យចិត្តគ្មានមិត្តសំឡាញ់ ក្នុងពេលដែលធ្វើដំណើរទៅកាន់គតខាងមុខ

សមដូចព្រះពុទ្ធភាសិតថា សយំ កតានិ បុញ្ញានិ តំ មិត្តំ សម្បរាយិកំ "បុណ្យទាំងឡាយដែលគេបានធ្វើហើយដោយខ្លួនឯង បុណ្យនោះជាមិត្តក្នុងលោកខាងមុខ" ។ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម ដែលសម្រេចមគ្គផល បានទៅសោយសេចក្ដីសុខដ៏សុខុមក្នុងសិវដ្ឋាន គឺព្រះនិព្វានក្ដី ជនទាំងឡាយក្រៅពីនោះ ដែលបានកើតមកជាមនុស្សឬបានទៅកើតក្នុងឋានសួគ៌ ឋានព្រហ្មសោយសេចក្ដីសុខជាទិព្វក្ដី សុទ្ធតែបានប្រកបសេចក្ដីព្យាយាមប្រឹងកសាងយ៉ាងពេញកម្លាំង ។ ការបានសេចក្ដីសុខក្នុងជាតិខាងមុខ ហៅថា បានប្រយោជន៍ក្នុងបរលោក ។

រួមសេចក្ដីថា ការបានទ្រព្យសម្បត្តិក្ដី ការបានចេះដឹងចំណេះវិជ្ជាណាមួយក្ដី សុទ្ធតែបានដោយវិរិយភាព គឺសេចក្ដីខ្មីឃ្មាតប្រឹងប្រែងយ៉ាងម៉ឺងម៉ាត់ ។ បើគ្រាន់តែមានឆន្ទៈ គឺបំណង់ថាចង់រក ចង់រៀន សូម្បី ១០០ ឆ្នាំ តែមិនរៀសរៃ មិនក្រវើនក្រតើន មិនព្យាយាមរក ព្យាយាមរៀនទេ ប្រាកដជាមិនបានសម្រេចដូចបំណងឡើយ ។ នេះជាអង្គទី ២ ហៅថា វីរិយិទ្ធិបាទ ប្រែថា "សេចក្ដីព្យាយាមជាជំហារឬជំហាននៃឫទ្ធិដែលអាចឲ្យសម្រេចសេចក្ដីប្រាថ្នាបាន" ។

៣ – ចិត្តៈ ប្រែថា "ការគិត, ការយកចិត្តទុកដាក់" ។ អធិប្បាយថា អ្វីៗទាំងអស់ ទោះការងារដែលយើងត្រូវប្រកបក្ដី ទោះចំណេះវិជ្ជាដែលយើងត្រូវសិក្សាក្ដី បើយើងគ្រាន់តែចង់រកចង់រៀន ទាំងបានរកបានរៀនតាមបំណងហើយ ដោយមានសេចក្ដីព្យាយាមពេញ

បន្ទុកក៏ដោយ, យើងត្រូវតែគិតថែមទៀត ទឹងខានពុំបាន គឺត្រូវគិតថាសេចក្តីប៉ុនប៉ង សេចក្តីប្រាថ្នារបស់អាត្មាអញនោះ សមរម្យឬមិនសម គួរឬមិនគួរ ល្អឬអាក្រក់ គុណឬទោស ត្រឹមត្រូវឬមិនត្រឹមត្រូវទេ បើគិតទៅហើយឃើញថា សេចក្តីប៉ុនប៉ងជាដើមនោះសមរម្យត្រឹមត្រូវល្អគួរដល់សេចក្តីសុខសេចក្តីចំរើន មិនប្រកបដោយទោសទេ សឹមចង់រកចង់រៀន; បើការងារឬចំណេះវិជ្ជាណា ដែលប្រកបដោយទោស យើងមិនត្រូវមានចំណង់ គឺមិនត្រូវចង់រកចង់រៀន ចំពោះការងារ ចំពោះចំណេះវិជ្ជានោះ ៗ ឡើយ ព្រោះសេចក្តីប្រាថ្នាណាមួយ ដែលពានពារទាក់ទងទៅលើហេតុដែលមិនគួរ អំពើដែលអាក្រក់, សេចក្តីប្រាថ្នានោះឯង ទឹងបណ្តាលទៅជាទោស ឲ្យកើតមានដល់ខ្លួនយើងវិញ; បើសេចក្តីប្រាថ្នាណាមួយ ដែលទាក់ទងទៅលើហេតុដែលគួរ អំពើដែលល្អ, សេចក្តីប្រាថ្នានោះទឹងនាំឲ្យទៅជាគុណ គឺនាំយកសេចក្តីសុខសេចក្តីចំរើនមកឲ្យខ្លួនយើងវិញ ។ មួយទៀតការគិត បើកើតមានពេញបរិបូណ៌ក្នុងខន្ធសន្តានជនណាហើយ ជននោះឈ្មោះថា មានគំនិត, បើមានគំនិតហើយ ទោះមានចំណង់ចង់ប្រកបការងារអ្វីក្តី ចំណង់នោះច្រើនល្អច្រើនត្រូវ, លុះព្យាយាមធ្វើ ព្យាយាមរៀន តាមគំនិតនោះទៅហើយ គង់មុខជាទឹងបានទទួលផលប្រយោជន៍ល្អពុំខាន; ព្រោះថាមនុស្សណាមានគំនិត មនុស្សនោះទុកដូចជាមានគម្រែង ឬកញ្ជើសម្រាប់ដាក់វត្ថុផ្សេង ៗ បានគ្រប់យ៉ាងតាមសេចក្តីប្រាថ្នា ដ្បិតសេចក្តីប្រាថ្នាក្តី សេចក្តីព្យាយាមក្តី បើទុកជាកើតមានរាប់រយឆ្នាំ

រាប់ពាន់ឆ្នាំក៏ដោយចុះ តែគ្មានគំនិតជាទំនប់សម្រាប់ថែរក្សាការពារទេ ក៏មុខជានឹងរលុបរលាយសាបសូន្យបាត់បង់ ពុំបានសម្រេចផលប្រយោជន៍នោះ ប្រៀបដូចទឹកត្នោតបើទុកជាស្រក់មិនស្រាកយ៉ាងណាក៏ដោយ តែបំពង់ធ្លុះហើយ កុំថាឡើយដល់ទៅបានពេញឬកន្លះបំពង់ សូម្បីតែមួយដំណក់ក៏មិនអាចតាំងនៅបានឡើយ ។ នេះជាអង្គទី ៣ ហៅថា ចិត្តិទ្ធិបាទ ប្រែថា " ការគិតជាជំហរ ឬ ជំហាននៃឫទ្ធិ ដែលអាចឲ្យសម្រេចសេចក្តីប្រាថ្នាបាន " ។

៤ — វីមំសា "ការពិចារណា ការត្រួតត្រា" នោះ បានដល់ការរិះរេលៃលកគ្នេគ្នាន់ ពិនិត្យពិច័យដោយហ្មត់ចត់ ឲ្យឃើញប្រាកដ ឲ្យជិនជាក់ ឲ្យយល់ច្បាស់ គឺថាកិច្ចការ ទាំងចំណេះវិជ្ជាគ្រប់យ៉ាង បើយើងគ្រាន់តែមានឆន្ទៈ ( ចំណង់ ) វិរិយៈ ( ព្យាយាម ) ចិត្តៈ ( គំនិត ) ដូចរៀបរាប់មកខាងដើមប៉ុណ្ណោះ ក៏មិនទាន់ធ្ងន់ល្មមនៅឡើយទេ លុះតែមានវីមំសា ការពិចារណាលៃលកត្រួតត្រាមើល ឲ្យបានច្រើនលើកច្រើនដងថែមហើយថែមទៀតរឿយៗ ទើបប្រពៃ, សមដូចពុទ្ធភាសិតថា និសម្មការណំ សេយ្យោ ហោតិ ប្រែថា "មុននឹងធ្វើការអ្វីៗ ត្រូវពិចារណាឲ្យល្អិតល្អ ទើបការនោះប្រសើរ អាចញ៉ាំងផលប្រយោជន៍ឲ្យសម្រេចដោយប្រពៃបាន" ។ ព្រោះការពិចារណាលោកប្រៀបដូចក្រដាសខាត់សម្រាប់ខាត់រំលីងសំអាតសង្ហារិមវត្ថុទាំងពួងមាន តុ ទូ តាំង កៅអីជាដើម ដែលគេធ្វើសម្រេចហើយ ឲ្យស្អាតរលីងម៉ដ្ឋហ្មត់ ទាំងតម្រែតម្រង់

ព្រឹងព្រោយ កុំឲ្យមានគ្រោតគ្រាតរដិបរដុបខ្ពស់ទាប, អាស្រ័យហេតុប៉ុណ្ណេះជាដើម ទើបវត្ថុទាំងនោះ បានឈ្មោះថា សមរម្យល្អ គួរដល់ទស្សនីយភាព គួរដល់ភ្នែកមើលបាន មានឧបមាយ៉ាងណា, មានឧបមេយ្យយ៉ាងការងារ ទាំងចំណេះវិជ្ជាគ្រប់យ៉ាងដែលបុរសបុគ្គលបានធ្វើឲ្យកើត បានរៀនឲ្យចេះដឹង ក៏គោងអាស្រ័យវិមំសាការពិចារណាឲ្យហ្មត់ចត់ ទើបកើតផលប្រយោជន៍បាន ។ នេះជាអង្គទី ៤ របស់សេចក្ដីប្រាថ្នា ហៅថា វិមំសិទ្ធិបាទ ប្រែថា "ការពិចារណាជាជំហរ ឬជំហាននៃឫទ្ធិ ដែលអាចឲ្យសម្រេចសេចក្ដីប្រាថ្នាបាន" ។

ក៏ធម៌ទាំង ៤ ប្រការគឺ ឆន្ទៈ (បំណង) វីរិយៈ (សេចក្ដីព្យាយាម) ចិត្តៈ (គំនិត) វិមំសា (ការពិចារណា) ដូចពណ៌នាមកនេះ បើកើតមានពេញបរិបូណ៌ក្នុងខន្ធសន្ដាននៃបុគ្គលណា បុគ្គលនោះនោះប្រាថ្នាយ៉ាងណា ក៏នឹងបានសម្រេចដូចបំណងពុំខាន; បើធម៌ទាំង ៤ ប្រការនេះមិនមានទេ ឬមានដែរ តែខ្វះខាតអង្គណាមួយ ក៏មិនអាចនឹងញ៉ាំងសេចក្ដីប្រាថ្នាឲ្យសម្រេចបរិបូណ៌បានឡើយ ។

សំដែងមកក្នុងឥទ្ធិបាទធម៌ ៤ ប្រការ ចប់តាមកាលវេលាតែប៉ុណ្ណេះ ឯវំ ។

---

# ទាបកថារឿងពុទ្ធរូបបុរាណ

ឃុនអត្ថកោវិទ ជា-យ៉ូវ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែចាកទស្សនាវដ្ដី ដំណឹងសាសនា ឆ្នាំទី ១ ច្បាប់ទី ៦ ភាសាថៃ

(តមក)

ទាំងនេះក៏ព្រោះមានហេតុផលដូចពោលមកហើយ គឺពួកឥណ្ឌាមានហាមមិនឲ្យសាងរូបបុគ្គល ដែលជាទីគោរពទុកធ្វើសក្ការៈបូជាទេ ។ ការណ៍ដែលសាងព្រះពុទ្ធរូបឡើងនោះ ជាគំនិតជនជាតិដទៃដែលកាប់កាន់ព្រះពុទ្ធសាសនា មានប្រាកដតាមប្រវត្តិសាស្ត្ររបស់ឥណ្ឌាថា ព្រះពុទ្ធសករាជប្រហែលជាង ២០០ ឆ្នាំ ព្រះបាទអេឡេក្សង់ដ្រ៍មហារាជនៃរដ្ឋមសិដោនទៀ ក្នុងប្រទេសក្រិក បានលើកព្យុហសេនា ទៅច្បាំងដណ្ដើមយកស្រុកតូចស្រុកធំនិគមជនបទ តាំងពីអ៊ីរ៉ុបរហូតដល់ឥណ្ឌា ទិសខាងលិចឈៀងខាងជើង ដែលហៅថា រដ្ឋបញ្ចាប ក្នុងសម័យនេះ ។ ព្រះបាទអេឡេក្សង់ដ្រ៍វាយបានស្រុកឥណ្ឌាតែត្រឹមប៉ុណ្ណោះ ហើយស្ដេចត្រឡប់ទៅវិញ តមកមិនយូរប៉ុន្មានក៏ទ្រង់ទីវង្គត ពួកមេទ័ពមេកងដែលសំខាន់ ៗ ក៏សឹងតែតាំងខ្លួនឡើងជាក្សត្រចែកគ្នាគ្រប់គ្រងរដ្ឋផ្សេង ៗ ដែលជាអាណាចក្ររបស់ព្រះបាទអេឡេក្សង់ដ្រ៍មហារាជ ។ ស្រុកគន្ធារៈ គឺប្រទេសអាហ្វឃានិស្ថានក្នុងសម័យនេះ និងរដ្ឋបញ្ចាបមានស្រុកបាក់ត្រៀជាដើម បានទៅកណ្ដាប់ដៃមេទ័ពម្នាក់ ដែលបានតាំងខ្លួនជាធំជំពូក ៗ បំណោតមកស្ដេចក្រុងបាក់ត្រៀបានធ្វើសង្គ្រាមនឹងព្រះ

ទៅចន្ទ្រគុប្ត ជាព្រះរាជអយ្យកោទួតរបស់ព្រះបាទអសោកមហារាជ (ព្រះចៅចន្ទ្រគុប្តជាព្រះរាជបិតាព្រះបាទពិន្ទុសារ, ព្រះបាទពិន្ទុសារៈជាព្រះរាជបិតារបស់ព្រះបាទអសោក) បរាជ័យចាញ់ស្នាព្រះហស្តព្រះបាទចន្ទ្រគុប្ត រដ្ឋបញ្ចាបក៏ធ្លាក់មកជារដ្ឋឥណ្ឌាវិញ ។ ក្រោយពីនោះមក ក៏ដល់មករាជ្យព្រះបាទអសោក ជារដ្ឋកាលទី ៣ នៃរាជវង្សមោរិយៈទ្រង់បានបញ្ជូនសមណទូត ឲ្យទៅផ្សាយព្រះពុទ្ធសាសនានៅស្រុកគន្ធារៈ ហើយសាងស្តូបបញ្ចុះព្រះបរមធាតុផង (នៅមានប្រាកដដល់មកឥឡូវនេះ ឈ្មោះថា "ធម្មរាជិកស្តូប") តមកគេបានជួសជុលស្តូបនេះជាច្រើនគ្រា ។ កាលសឺ-ចន-ម៉ាឡែល អធិបតីក្រុមពិនិត្យបុរាណវត្ថុនៅឥណ្ឌា បានឲ្យជីកពិនិត្យមើលក្នុង គ.ស. ១៩១៤ - ១៩១៥ បានប្រទះឃើញព្រះបរមធាតុក្នុងស្តូបបុរាណនោះ ហើយឃើញមានចារិកថា "ព្រះបាទធម្មរាជាធិរាជជាអ្នកសាង" គេសន្និដ្ឋានថា គឺព្រះបាទអសោកមហា-រាជនោះឯង, ព្រះធាតុនោះ គឺព្រះធាតុដែលរដ្ឋាភិបាលឥណ្ឌា បានប្រគល់ឲ្យគណៈទូតថៃ ដែលទៅចងសម្ពន្ធមេត្រី កាល ព.ស. ២៤៨៣ រដ្ឋាភិបាលថៃបាននាំមកបញ្ចុះទុកក្នុងព្រះស្តូបចេតិយវត្តព្រះស្រីមហាធាតុ តំបន់បាងខេន ។ ខនេះជាគោលដ៏ច្បាស់លាស់ថា ព្រះពុទ្ធសាសនាបានផ្សាយទៅដល់ស្រុកគន្ធារៈ កាលក្នុងរាជ្យព្រះបាទអសោកមហារាជ ទើបមានព្រះបរមធាតុប្រាកដនៅក្នុងព្រះចេតិយនោះ ។ កាលអស់រាជ្យព្រះបាទអសោកហើយ ស្តេចដែលទទួលរជ្ជទាយាទតមកមិនរឹងប៉ឹង, អាណាចក្ររបស់ព្រះបាទអសោកក៏ធ្លាក់ទៅក្នុងកណ្តាប់ដៃរាជវង្សសុង្គ ។

រាជវង្សសុង្គគ្រប់គ្រងមកមិនបានប៉ុន្មានឆ្នាំ ពួកក្រិកក៏លើកពលចុះមកទៀតកើតច្បាំងគ្នាឡើង ពួករាជវង្សសុង្គចាញ់ ពួកក្រិកក៏ពង្រីកអាណាចក្រចូលមកក្នុងដែនគន្ធារៈទឹកដែនបញ្ចាបដូចពីដើម ហើយតាំងដែនគន្ធារៈទឹកដែនបញ្ចាបឲ្យជាឯករាជ្យច្រើនខែត្រ មានស្តេចផែនដីក្រិកគ្រប់គ្រងតៗមករហូតដល់ពុទ្ធសករាជ ៣៦៤ ទើបដល់មករាជ្យព្រះបាទមិលិន្ទ ។ ព្រះបាទមិលិន្ទជាជាតិអឺរ៉ុបកាត់ឥណ្ឌា មិនមែនជាតិឥណ្ឌាសុទ្ធទេ ព្រះបាទមិលិន្ទពង្រីកអាណាចក្រមកខាងក្រោមរហូតដល់មគធរដ្ឋ តែទ្រង់នៅកាន់សាសនាដើម គឺសាសនាដែលជនជាតិក្រិកធ្លាប់កាន់មក ចំណែកពលរដ្ឋគន្ធារៈនៅកាន់ព្រះពុទ្ធសាសនាជាច្រើនគ្រប់ៗកន្លែង តាមដែលព្រះបាទអសោកបានផ្សាយចូលទៅ ។ ថ្ងៃមួយព្រះបាទមិលិន្ទបានជួបនឹងព្រះនាគសេន បាននិយាយធម៌នឹងព្រះនាគសេនច្រើនដងច្រើនគ្រា ព្រះនាគសេនក៏បានឆ្លើយដោះប្រស្នាទាំងថ្វាយអត្ថាធិប្បាយផ្សេងៗ ជាច្រើន ព្រះបាទមិលិន្ទទ្រង់ឃើញធម៌ ក៏ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយបានធ្វើការធំសំរាប់ពួកយើង ដែលយើងគួររលឹកដល់បុណ្យគុណរបស់ទ្រង់ គឺទ្រង់បានសាងព្រះពុទ្ធរូបឡើង ទាំងនេះក៏ព្រោះហេតុពួកក្រិកគេគ្មានហាមការសាងរូបជាទីគោរព ៖គេមានរូបសម្រាប់គោរពប្រចាំសាសនារបស់គេស្រាប់ កាលគេបែរមកកាន់ព្រះពុទ្ធសាសនា គេក៏សាងព្រះពុទ្ធរូបឡើងសម្រាប់បូជា ដោយហេតុនោះ ព្រះពុទ្ធរូបទើបកើតមានឡើង ដោយប្រការដូច្នេះ គឺមានក្នុងរវាង ព. ស. ៣៦៤ ដល់ ព. ស. ៣៨៣ ក្នុងរាជ្យនៃព្រះបាទមិលិន្ទ ។

ព្រះពុទ្ធរូបសម័យស្តេចមិលិន្ទ ហៅថាព្រះគន្ធារៈ តែតាមពិតនោះ ដែលថាយ៉ាងនេះមិនប្រាកដទេ ព្រោះមិនមានអ្នកណាដឹងជាប្រាកដថា ព្រះពុទ្ធរូបដែលកកើតឡើងក្នុងរាជ្យព្រះបាទមិលិន្ទនោះផ្សេងពីព្រះគន្ធារៈ សព្វថ្ងៃនេះដោយមានទ្រង់ទ្រាយខុសគ្នាបែបណា ៗ តែអ្នកប្រាជ្ញប៉ែកខាងបុរាណគតិបានសន្និដ្ឋានថា ព្រះពុទ្ធរូបដែលមានសាយកាយទូទៅនោះ ប្រហែលជាមិនមែនព្រះពុទ្ធរូបសម័យព្រះបាទមិលិន្ទទេ ព្រោះព្រះបាទមិលិន្ទគ្រងរាជសម្បត្តិបានត្រឹម ១៨ ឆ្នាំប៉ុណ្ណោះ ព្រះពុទ្ធរូបដែលបានផ្សាយទូទៅនោះ ប្រហែលជាកើតមានក្នុងរាជ្យព្រះបាទកនិស្កៈទេដឹង ៗ សូមនិយាយប្រវត្តិសាស្ត្រតទៅបន្តិចទៀតដូចតទៅនេះ: កាលព្រះបាទមិលិន្ទទិវង្គតទៅហើយនោះ មិនមានវង្សាយាទណា ដែលមានសមត្ថភាពក្នុងការគ្រប់គ្រងស្រុកទេស ព្រោះដូច្នោះ រាជវង្សព្រះបាទមិលិន្ទគ្រប់គ្រងរដ្ឋគន្ធារៈបានតែត្រឹម ៥០ ឆ្នាំប៉ុណ្ណោះ ក៏ចាញ់ដៃពួកសកៈ ដែលលើកទ័ពមកពីកណ្តាលទ្វីបអាស៊ី ៗ ពួកសកៈគ្រងគន្ធារៈមិនបានយូរប៉ុន្មាន ក៏ចាញ់ដៃកុសាន ដែលបានលើកទ័ពមកពីជាយដែនខាងលិចឈៀងខាងត្បូងនៃប្រទេសចិន ៗ ក្នុងពួកកុសាននោះមានមនុស្សសំខាន់ម្នាក់ គឺព្រះបាទកនិស្កៈ បានពង្រីកអាណាខេត្តចូលមកក្នុងឥណ្ឌៀរហូតដល់មគធរដ្ឋដែលជាមជ្ឈិមប្រទេស ហើយទ្រង់រាប់អានព្រះពុទ្ធសាសនា ទ្រង់បានបំពេញករណីយកិច្ចគ្រប់យ៉ាងដូចព្រះបាទអសោកធ្លាប់បំពេញមក ដូចទ្រង់ឲ្យធ្វើសង្គាយនាព្រះធម្មវិន័យ បញ្ជូនព្រះសង្ឃឲ្យទៅផ្សាយព្រះពុទ្ធសាសនាក្នុងប្រទេសផ្សេងៗ ទ្រង់ធ្វើការដែល

ព្រះបាទមិលិន្ទបានធ្វើមកហើយនោះ ឲ្យរឹងរឹតតែចំរើនឡើង គឺទ្រង់សាងព្រះពុទ្ធរូបជាការធំបំផុត ។ ព្រះពុទ្ធរូបនេះបានផ្សាយទៅតាមស្រុកទេសផ្សេង ៗ ដែលធ្លាប់រាប់អានព្រះពុទ្ធសាសនាមកហើយ គឺផ្សាយទៅខាងក្រុងមធុរ, ក្រុងអមរាវតី, កោះលង្កា ។ តែព្រះពុទ្ធរូបគន្ធារៈនោះឃើញមានក្រសែគំនិតរបស់ជាងអ៊ឺរ៉ុប ពួកអ៊ឺរ៉ុបគេឃើញថា ធ្វើដូចម្តេចជាការល្អគេក៏ធ្វើបែបនោះទៅ គេអាស្រ័យពួកឥណ្ឌៀតែត្រឹមគោលចារិកខាងប្រវត្តិសាស្ត្រប៉ុណ្ណោះ ពោលគឺព្រះពុទ្ធអង្គទ្រង់គង់ស្បង់ចីពរបែបណា, ព្រះអង្គជាជាតិក្សត្រ ធម្មតាក្សត្រត្រូវមានគ្រឿងទ្រង់ព្រះសិរគេទើបធ្វើព្រះពុទ្ធរូបឲ្យមានព្រះមោលីឡើង ព្រះពុទ្ធរូបទាំងពួងដែលមានព្រះមោលី ព្រោះមានរឿងដូចអធិប្បាយមកនេះ មិនមែនជាព្រះពុទ្ធអង្គទ្រង់មានព្រះសិរប៉ោងខ្ពស់ឡើង ដែលជារបស់ខុសធម្មតាដូច្នោះទេ ។ តាមដែលពិតរឿងព្រះមោលីនេះ ជាងដែលប្រាជ្ញធ្វើជាន់ដំបូងគេមានគំនិតល្អណាស់ ទាល់តែជាងជាន់ក្រោយមិនអាចនឹងរកឧបាយកែខៃបាន ។ រឿងព្រះមោលី ជារឿងដែលគេបានពិនិត្យពិចារណាច្រើនណាស់មកហើយ តាំងពីសម័យវឌ្ឍកាលទី ៤ តែយើងសូមលើកទុកនឹងអធិប្បាយទៅពេលក្រោយវិញ ។ បញ្ហារឿងនេះមានសាស្ត្រាចារ្យម្នាក់ ឈ្មោះហ្វូសេជាតិបារាំងសែសបានអធិប្បាយថា ព្រះពុទ្ធរូបដែលគេធ្វើឲ្យមានព្រះមោលីនោះ សម្រាប់ឲ្យដឹងថាជាព្រះពុទ្ធអង្គ ព្រោះថាបើព្រះពុទ្ធរូបមានព្រះសិរដូចព្រះសាវ័កធម្មតា ក៏នឹងប្រឡំទៅនឹងរូបព្រះសាវ័ក បើយ៉ាងនេះធ្វើម្តេចនឹងដឹងថាអង្គណាជារូបព្រះសាវ័ក អង្គ

ណា ជារូបព្រះពុទ្ធអង្គ, គេត្រូវការឱ្យព្រះពុទ្ធរូបមានលក្ខណៈផ្សេងពីរូប ព្រះសាវ័ក គេទើបធ្វើឱ្យមានព្រះមោលីសម្រាប់សំគាល់ឡើង ដោយអាស្រ័យគោលដែលថាព្រះពុទ្ធអង្គជាជាតិក្សត្រ ដោយហេតុនេះព្រះពុទ្ធរូបទើបមានព្រះមោលីឡើង តែមោលីដែលក្រិកធ្វើជាមោលីក្បួងសក់បួងឡើងមកលើ, ចីវរដែលក្រិកធ្វើជាចីវរដែលជ្រួញអង្កាញ់ៗ ព្រះសមាធិរបស់ក្រិកមានតែសមាធិពេជ្រ ១ យ៉ាង គ្មានសមាធិកបេទ ៗ ដែលអធិប្បាយមកនេះ បង្ហាញឱ្យឃើញថា ការកសាងព្រះពុទ្ធរូបជាដំបូងនោះ ជាគំនិតរបស់ក្រិក ចំណែកពួកឥណ្ឌា គេមានគម្រា ហៅថា មហាបុរិសលក្ខណសាស្ត្រ គឺគម្រាទិយាយពីមនុស្សសំខាន់ មានពាក្យអធិប្បាយលក្ខណៈមនុស្សសំខាន់ជាដើមថា សរសៃព្រះកេសាវិលជាទក្ខិណាវ័ត្ត ដូចគូថខ្យង កាលពួកឥណ្ឌាបានទទួលគំនិតក្នុងការកសាងរូបជាទីគោរពឡើង គេបានផ្លាស់ប្តូរច្រើនយ៉ាង ដូចសរសៃព្រះកេសាគេធ្វើឱ្យវិលជាទក្ខិណាវ័ត្ត តាមគម្រាមហាបុរិសលក្ខណសាស្ត្រ, ព្រះភក្ត្រពីដើមដូចមុខពួកអឺរ៉ុប គេផ្លាស់ឱ្យដូចមុខពួកឥណ្ឌាទៅវិញ ដូចព្រះពុទ្ធរូបនៅក្រុងមធុរា និងក្រុងអមរាវតីជាដើម ហើយចីពរដែលជ្រួញអង្កាញ់ៗ ខាងឥណ្ឌាឃើញថាមិនល្អ សំឡឹងមើលមិនឃើញទ្រង់ទ្រាយរូបច្បាស់លាស់ គេត្រូវការនឹងអះអាងរាងកាយថា ព្រះពុទ្ធអង្គមានព្រះសរីរកាយល្អ គេទើបធ្វើចីវរស្តើង ដើម្បីឱ្យឃើញរាងកាយយ៉ាងច្បាស់លាស់ ទេវរូបនៅឥណ្ឌាគេក៏ធ្វើដូច្នោះដែរ ៗ

(មានត)

# ផ្នែកអក្សរសាស្ត្រ

## គំនិតខុសគំនិតត្រូវ (១)

លោកបណ្ឌានុរក្ស ប៊ូ - ប៊ូ រៀបរៀង

---

គំនិតខុសនិងគំនិតត្រូវទាំង ២ យ៉ាងនេះ សុទ្ធតែជាអ្នកកសាង សង្ខារឲ្យកើតមានឡើងដូចគ្នា គ្រាន់តែមានប្រភេទប្លែកពីគ្នាប៉ុណ្ណោះ ដូចមានអត្ថាធិប្បាយតទៅនេះ ៖

គំនិតដែលមិនដឹងច្បាស់នូវសភាពនៃកាយតាមការពិត ហៅថា គំនិតខុស ។ នេះ រមែងសំគាល់ថា កាយជាខ្លួនប្រាណរបស់អាត្មាជានិច្ច ទាំងសំគាល់ថា នុះជាគេ, នុះជាយើង, នុះជាប្រុស, នុះជាស្រី ។ កាលបើសំគាល់យ៉ាងនេះហើយ ក៏គិតចង់បានរូបកាយរបស់គ្នានិងគ្នា ដែលសន្មត់តាមវោហារនិយមថា ស្វាមីភរិយា ជួយទំនុកបម្រុងគ្នានិងគ្នាខ្លះ បៀតបៀនគ្នាខ្លះ តាមតែចិត្តមានធម៌ជាកុសលឬជាអកុសល ច្រើនតិចជាងគ្នា ។ ប៉ុន្តែ ក្នុងទីបំផុតរូបកាយនោះ ត្រូវបែកធ្លាយទៅមុនចិត្ត បើមិនបែកធ្លាយកាយរបស់គេទេ ក៏បែកធ្លាយកាយរបស់ខ្លួនដែរជាមិនខាន ។ បើរូបកាយអ្នកម្ខាងត្រូវបែកធ្លាយ ( ស្លាប់ ) ទៅហើយ ចិត្តដែលជាប់នៅក្នុងរូបកាយអ្នកម្នាក់ទៀត ក៏សំគាល់ថាគូស្រករបស់ខ្លួនស្លាប់ទៅហើយ ទើបកើតសេចក្តីសោកទុក្ខទោមនស្សធ្ងន់ខ្លះ ស្រាលខ្លះ

---

១ អធិប្បាយតាមន័យក្នុងអាទិត្តបរិយាយសូត្រ ។

តាមការស្រឡាញ់ រាប់អានតិចច្រើន ព្រោះហេតុចិត្តអន្ទះអន្ទែងមិនចង់ឲ្យគូស្រករនោះស្លាប់សោះ, ចិត្តបែបនេះចាត់ជាតណ្ហា ជាចិត្តរង់ទុក្ខយំសោកអាក់អន់ចង្អៀតចង្អល់ជាដើម ។ ចិត្តជាធម្មជាតិឥតរូបកងខ្លួនប្រាណក៏ពិតមែនហើយ ប៉ុន្តែអាចអន្ទះអន្ទែងបានជាពិតប្រាកដ បើអន្ទះអន្ទែងចង់បានខ្លាំង ក៏ក្តៅក្រហាយខ្លាំង បើអន្ទះអន្ទែងចង់បានតិចក៏ក្តៅក្រហាយតិចដែរ ។ ប៉ុន្តែចិត្តឥតដឹងយល់ខ្លួនឯងថាជាអ្នកលង់ខ្លៅទេ ព្រោះមិនបានពិចារណាឲ្យល្អិតល្អោចឲ្យដុះធ្លាយទៅដល់សេចក្តីពិតរបស់ហេតុនិងផល ។ ហេតុតែចិត្តមិនយល់ហេតុនិងផលយ៉ាងនេះហើយ បានជាទទួលទុក្ខទោមនស្សក្តៅក្រហាយជានិច្ច កំណត់រាប់ពេលវេលាមិនបានអស់ ។ ចុះចិត្តកើតក្តៅក្រហាយនោះតើព្រោះមានរបស់អ្វីមកដុតកំដៅ? ព្រោះមានភ្លើងគឺតម្រេក (រាគៈ), សេចក្តីក្រោធខឹង (ទោសៈ), សេចក្តីវង្វេង (មោហៈ) នេះឆេះក្នុងចិត្ត ។

បើចិត្តខំព្យាយាមត្រិះរិះឲ្យល្អិតសុខុមជ្រាលជ្រៅទៅទៀត មុខជានឹងបានឃើញហេតុផលជាគូគ្នាមិនខាន គឺរូបកាយដែលឈឺចាប់ជាហេតុ, រូបកាយដែលត្រូវបែកធ្លាយស្លាប់ជាផល ។ ហេតុនិងផល ១ គូនេះកើតមាននៅត្រង់រូបកាយ ជារបស់ប្រព្រឹត្តទៅក្រៅអំណាចចិត្ត ។ ចិត្តជាធម្មជាតិមានអំណាចយ៉ាងខ្លាំងលើរូបកាយក៏ពិតមែនហើយ ប៉ុន្តែនឹងហាមឃាត់ហេតុផល ១ គូនេះថា កុំឲ្យកើតជាមួយនឹងរូបកាយនោះ ក៏ឃាត់ខាំងមិនបានឡើយ ដ្បិតថា នៅមានហេតុផលដ៏ស្អាតកំបាំងល្អិតសុខុម ១ គូទៀត ដែលកើតមានឡើងជាមួយនឹងចិត្ត ហើយបិតនៅក្នុង

រូបកាយនាំបណ្ដាលឲ្យចិត្តនោះវង្វេងភាន់ច្រឡំ ទៅត្រេកអរស្រឡាញ់រាប់អានរូបកាយរបស់មនុស្សម្នាក់ទៀត ប្រកាន់ថា ជាគូព្រេងរបស់ខ្លួន លុះដល់គូព្រេងនោះស្លាប់ទៅហើយ ចិត្តក៏អន្ទះអន្ទែងចង់ឲ្យតែមានជីវិតរស់នៅរួមគ្នាជានិច្ចកាលទៅ មិនចង់ឲ្យគូព្រេងស្លាប់បាត់ទៅសោះ ចិត្តបែបនេះហៅថាជាចិត្តមានតណ្ហា តណ្ហានេះជាហេតុធ្វើឲ្យចិត្តរងទុក្ខ ។ ហេតុនេះបានជាបណ្ឌិតយល់ឃើញថា ការគិតដូច្នេះខុសណាស់ ព្រោះសំគាល់ថារូបកាយជាខ្លួនប្រាណ ហើយវង្វេងស្រឡាញ់រូបកាយ ចេះតែអន្ទះអន្ទែងចង់បានរូបកាយ ទាល់តែត្រូវទទួលទុក្ខយ៉ាងធ្ងន់ ។ ការគិតខុស មិនបានដឹងហេតុរបស់ទុក្ខដ៏ស្ងាត់កំបាំងនេះឡើយ បានជាសម្ដេចព្រះបរមសាស្ដាជាបរមអ្នកប្រាជ្ញក្នុងលោក ទ្រង់ជ្រាបហេតុផលរបស់ទុក្ខនិងសុខច្បាស់ហើយទ្រង់ត្រាស់ប្រាប់ថា "តណ្ហាទាសោ បុថុជ្ជនោ មនុស្សបុថុជ្ជនជាទាសៈនៃតណ្ហា" ។ ចិត្តវង្វេងអន្ទះអន្ទែងចង់មានចង់បានកើតឡើងកាលណា ក៏ត្រូវរងទុក្ខក្នុងកាលនោះភ្លាម ។ ព្រោះហេតុនោះ គួរតែកំណត់ដឹងថា សេចក្ដីទុក្ខកប់តាំងពីសោកជាដើមទៅ សុទ្ធតែជាផលរបស់តណ្ហាទាំងអស់ ។ ចុះចិត្តបែបណា ហៅថាមានតណ្ហា? ចិត្តដែលអន្ទះអន្ទែងចង់មានចង់បានចង់កើត ចង់ឲ្យទៅជាយ៉ាងនេះជាយ៉ាងនោះ ចង់ឲ្យបានសុខស្រួល នេះហៅថាមានតណ្ហា ។ ចុះតណ្ហានុះ កើតមានមកអំពីទីណា ? តណ្ហាកើតមានមកអំពីចិត្តដែលល្ងង់ខ្លៅនោះឯង ។ ចិត្តនៅត្រង់ណា តណ្ហានៅត្រង់នោះ ។ ប្រសិនបើតណ្ហាកើតមានមកពីទីកន្លែងឯទៀតក្រៅពីចិត្តវិញ តើចិត្តអាចនឹងលះបង់តណ្ហានោះឲ្យដាច់ជ្រះ

ស្រឡះបានដែរឬទេ ? ប្រាកដជាលះបង់មិនដាច់ទេ ។ ព្រះពុទ្ធដីកា ដែលព្រះបរមសាស្ដាទ្រង់ត្រាស់ទូន្មានថា "សមុទ័យ (តណ្ហា) ជាចំណែកដែលគួរលះបង់" ដូច្នេះនោះ ក៏អាចបង្អុលឲ្យយល់បានជាក់ច្បាស់ថា តណ្ហាជាហេតុនៃទុក្ខដែលកើតមាននៅក្នុងចិត្ត តណ្ហានេះនៅក្រោមអំណាចរបស់ចិត្ត ព្រោះថាក្រៅពីចិត្តហើយ ឥតរបស់ណាមួយនឹងមានអំណាចអាចបង្គាប់បញ្ជាតណ្ហាបានឡើយ ។ ហេតុនេះ ចិត្តត្រូវតែដឹងស្គាល់ខ្លួនឯង ត្រូវតែប្រុងប្រយ័ត្នខ្លួនឯង កុំឲ្យវង្វេងភាន់ច្រឡំទៅចង់បានអារម្មណ៍ដែលគួរប្រាថ្នា ដូចរូបល្អ, សម្លេងពីរោះ, ក្លិនក្រអូប, រសឆ្ងាញ់ពិសា, របស់ប៉ះទង្គិចកាយដ៏ទន់ក្លន់ ។ ចិត្តដែលចង់បានរបស់ល្អទាំងនេះ ឈ្មោះថាកាមតណ្ហា ។ ចិត្តដែលប្រាថ្នាឲ្យរបស់ល្អទាំងនេះនៅគង់ទ្រង់ជាប់ជានិច្ចទៅ ឈ្មោះថា ភវតណ្ហា ។ ចិត្តដែលមិនចង់ឲ្យរបស់អាក្រក់កើតមាននៅជាប់រហូតទៅ ឈ្មោះថា វិភវតណ្ហា ។ ចិត្តជាអរូបធាតុ គឺជាសភាពឥតរូប ដ៏ប្លែកអស្ចារ្យជាងធម្មជាតិទាំងពួងយ៉ាងក្រៃលែង ។ ប៉ុន្តែសូម្បីចិត្តអស្ចារ្យដល់ម្ល៉េះ ក៏នៅតែមិនផុតពីសេចក្ដីល្ងង់ខ្លៅដែរ ចេះតែចង់បានសុខ ស្អប់ខ្ពើមទុក្ខណាស់ ហេតុតែមិនដឹងខ្លួនថាខ្លួនវង្វេងភាន់ច្រឡំ ទៅបង្កាត់ភ្លើងកិលេសឲ្យឆេះឡើងដុតរោលខ្លួនឯងជានិច្ចឡើយ ។ ការរងទុក្ខជាផលរបស់ចិត្តអន្ទះអន្ទែងចង់បាន ។ មនុស្សគ្រប់រូបចេះតែចំស្រែកថា "ខ្ញុំចង់បានសុខណាស់ ខ្ញុំស្អប់ខ្ពើមទុក្ខណាស់", ប៉ុន្តែតាមការពិត អ្នកទាំងនោះបែរជានាំគ្នាផ្ដើមទុក្ខសមុទ័យ (តណ្ហា) ឲ្យចម្រើនគឺឲ្យកើតឲ្យមានរឹតតែច្រើនឡើងទៅវិញ

ដូចជាអ្នកខ្ពើមលាមកណាស់ ប៉ុន្តែត្រឡប់ជាទៅដើរជាន់លាមកវិញ ។ សម្តេចព្រះបរមសាស្តា មានព្រះមហាករុណាចំពោះសព្វសត្វណាស់ បានជាទ្រង់ត្រាស់ពន្យល់អំពីការគ្រប់គ្រងជីវិតនៅនាបច្ចុប្បន្ន នឹងទ្រង់បង្ហាញប្រាប់ហេតុរបស់សុខទុក្ខយ៉ាងជាក់ស្តែងថា ផ្លូវដ៏ប្រសើរសម្រាប់រំលត់ទុក្ខមានអង្គ ៨ (អដ្ឋង្គិកមគ្គ) ជាផ្លូវអាចទាញចិត្តដែលធ្លាក់ទៅនៅក្រោមអំណាចរបស់អវិជ្ជាតណ្ហានោះឲ្យប្រតិបត្តិតាម ដើម្បីឲ្យបានសម្រេចដល់សន្តិសុខ ដ៏ជាសុខពេញបរិបូណ៌ ។

យើងទាំងឡាយ គួរណាស់តែចំរិះរិះតាមដំបូន្មានរបស់ព្រះសាស្តា ឲ្យដឹងច្បាស់ថា របស់ណាព្រះអង្គប្រាប់ឲ្យលះបង់ ត្រូវខំលះបង់របស់នោះចេញ, របស់ណាព្រះអង្គប្រាប់ឲ្យចំរើន ត្រូវខំចំរើនរបស់នោះ ឲ្យកើតមានច្រើនឡើង ទើបនឹងផុតពីទុក្ខដែលចិត្តស្អប់ខ្ពើម ហើយបានទទួលសុខដែលចិត្តប្រាថ្នាយ៉ាងបំផុតនោះ ឲ្យសមតាមពាក្យដែលពោលប្រាប់អ្នកផងថា "ខ្ញុំចង់បានសុខណាស់ ខ្ញុំស្អប់ខ្ពើមទុក្ខណាស់" ។

# រឿងព្រះបាទរុស្សកាំងសាង

នឹង

# ព្រះនាងសេហោរិស្តានី

អ្នកស្រីពេជ្រ–សល់ ហៅ សាវិះយ៉ាង ប្រែរៀបរៀង

(តបប់)

---

ព្រះបាទរុស្សកាំងសាង លុះទ្រង់យល់ឃើញថា លោកមុយអេស៊ីន ដែលធ្លាប់បំរើព្រះអង្គដោយសុទ្ធចិត្តមកជាយូរណាស់ហើយ ៗ នៅតែស្មោះត្រង់នឹងព្រះអង្គដដែល ទ្រង់ក៏មានព្រះបន្ទូលរៀបរាប់ អំពីការដែលទ្រង់បានទៅជួបនឹងព្រះនាងសេហោរិស្តានី ។ លោកមុយអេស៊ីនគ្មានកើតសេចក្តីអស្ចារ្យប៉ុន្មានទេ ព្រោះធ្លាប់បានដឹងខ្លះៗមកហើយ ។ ប៉ុន្តែពេលនោះ ពួកមុងគោលបានលើកទ័ពច្រើនជាអនេក ចូលមកលុកប្រទេសចិន ដើម្បីនឹងទន្ទ្រានយកនគរទាំងមូលតែម្តង ។

ព្រះបាទរុស្សកាំងសាង លុះទ្រង់ជ្រាបដូច្នោះ ក៏ទ្រង់បង្គាប់ឲ្យប្រមូលទ័ពជាប្រញាប់ ដើម្បីទៅតទល់នឹងទ័ពបច្ចាមិត្ត ។ ទ្រង់នាំទ័ពចេញទៅជួបនឹងទ័ពបច្ចាមិត្ត ដែលបោះជំរំនៅក្នុងទីវាលមួយធំ ទ្រង់ព្រះបញ្ជាឲ្យពួកទ័ពឈប់នៅទីមិនឆ្ងាយពីគ្នាប៉ុន្មាន ។ បន្តិចមកទ័ពដឹកស្បៀងអាហារដែលរដ្ឋមន្ត្រីវែលលីជាមេបញ្ជាការមកដល់ មានប្រដាប់បរិភោគគ្រប់យ៉ាង នំប្រអប់ ផ្លែឈើកំប៉ុង ត្រណាប់ នឹងគ្រឿងកេសជ្ជៈគ្រប់យ៉ាង ។ នៅពេលដែលទ័ពនាំអាហារទាំងនោះ រៀបនឹងចូលមក

ដល់កាលដែលព្រះបាទរុសកំនសាដបោះទ័ព ព្រះនាងសេហេរ៉ស្តាទី ហើយទីងពួកអាទិទេពជាច្រើនរូបនាំគ្នាស្កាត់ទ័ព ទាញកំប៉ុងអាហារ ផ្សេងៗ ទម្លាក់ពីលើខ្នងសត្វ ហើយនាំគ្នាជាន់បោលពេញទាំងដី គ្មានសល់អ្វីបន្តិច ។ វ៉ៃលលីកាលឃើញដូច្នោះហើយ មានសេចក្តីព្រួយណាស់ តែព្រះនាងសេហេរ៉ស្តាទីត្រាស់បង្គាប់ថា ៖

— ចូរឯងទៅទូលស្តេចថា ព្រះរាជទេពីព្រះអង្គបានបំផ្លាញអាហារសម្រាប់ទ័ពអស់ទៅហើយ ។

វ៉ៃលលីក៏នាំសេចក្តីទៅទូលព្រះមហាក្សត្រ ទ្រង់អស់សង្ឃឹមហើយ ទ្រង់ពិចារណាថា ការដែលខូចបង់កូនពីរដូចជានៅអត់ទោសបាននៅឡើយ មិនដូចអំពើក្រោយនេះទេ ។ នៅពេលដែលព្រះអង្គកំពុងតែក្រោធ ស្រាប់តែព្រះនាងយាងមកដល់ ព្រះអង្គក៏មានព្រះបន្ទូលថា ៖

— ព្រះនាង, មួងនេះខ្ញុំទីងអត់ទ្រាំទៅទៀតពុំបានទេ ព្រះនាងធ្វើឲ្យខ្ញុំទ្រាំអត់ពុំបាន ព្រះនាងបានយកកូនប្រុសខ្ញុំទៅបោះកងភ្លើង រួចឲ្យកូនស្រីខ្ញុំទៅឲ្យឆ្កែ ហើយនៅពេលនោះ ទោះជាខ្ញុំពិបាកចិត្តយ៉ាងណាក៏ខ្ញុំពុំហ៊ានហាមាត់ស្តី ឬបញ្ចេញអាកប្បកិរិយាឲ្យដឹងសោះ ប៉ុន្តែអំពើដែលព្រះនាងទើបនឹងធ្វើអំបាញ់មិញនេះ ជាអំពើមិនចំពោះរូបខ្ញុំទេ ហើយទោះជាខ្ញុំបានសន្យានឹងព្រះនាងហើយក៏ដោយ មួងនេះគឺត្រូវតែខ្ញុំមានអំណាចតក៉ ព្រោះពួកទ័ពរបស់ខ្ញុំរកអាហារអ្វីបរិភោគគ្មាន តើគិតដូចម្តេច? សូមនិយាយមក! តើរូបខ្ញុំទៅជាយ៉ាងណាទៅ? ចុះព្រះ

នាងចង់ឲ្យពួកបច្ចាមិត្ត ចាប់ខ្លួនខ្ញុំបានដោយមិនបាច់ប្រាំងឬ? នៃស្រី អកតញ្ញូ!... តើនាងនឹងយកអ្វីមកសងសេចក្ដីស្នេហារបស់ខ្ញុំបាន? ។

–ព្រះមហាក្សត្រ បើសិនជាព្រះអង្គទ្រង់នៅឲ្យស្ងៀមម្ដងនេះទៀត ជាការប្រសើ, ការអត់ទ្រាំមិនបាននេះ ជាការវិនាសដល់សេចក្ដីអត់ធ្មត់ ដែលព្រះអង្គបានកាន់មកយូរហើយ ។ ក្នុងពេលនេះ គ្រោះថ្នាក់មក ដល់ហើយរកថ្នាំអ្វីនឹងដាក់គ្មាន . តើព្រះអង្គទ្រង់ជ្រាបថា ក្មេងដែលខ្ញុំម្ចាស់បោះព្រះរាជបុត្រាទៅឲ្យនោះជាអ្វីទេ?... គឺជាអារក្សក្មេងមួយយ៉ាងជំនាញ ដែលខ្ញុំម្ចាស់ប្រគល់ព្រះរាជបុត្រាឲ្យគេបង្រៀន ឯផ្ដែញស នោះទៀត ក៏ជាទេវតាមួយអង្គដែរ ដែលចង់ឲ្យព្រះរាជបុត្រព្រះអង្គរៀន វិជ្ជាសាស្ត្រផ្សេងៗ ដែលបុត្រនៃអាទិទេពត្រូវរៀន ។ អារក្សក្មេងនឹង ទេវតានោះ គ្មានធ្វើឲ្យខ្ញុំម្ចាស់អនិច្ចតបន្តិចទេ ដោយគេបានយកចិត្តទុក ដាក់នឹងថែរក្សាកូនខ្ញុំម្ចាស់ទាំងពីររូបដោយមេត្តាចិត្តណាស់ ហើយព្រះអង្គ នឹងទ្រង់យល់ការពិតឥឡូវនេះភ្លាម ។

ថាហើយព្រះនាងក៏មានព្រះបន្ទូលហៅឆ្មាំដែលតាមដង្ហែព្រះនាងថា: ប្ដូវឯងទៅប្រាប់ឲ្យគេនាំព្រះរាជបុត្រានឹងព្រះរាជធីតាអញមកទីនេះភ្លាម ។

មួយមិនុតក្រោយមក ព្រះរាជកុមារ នឹងព្រះរាជធីតាក៏ចូលមក ដល់ដំរព្រះអង្គ ។ ទ្រង់មានសេចក្ដីត្រេកអរនឹងឃើញព្រះរាជបុត្រមាន ព្រះភក្ត្រល្អប្រិមប្រិយ ហើយស្ទុះទៅឱបព្រះរាជកុមារទាំងពីរព្រះអង្គ ដោយពេញព្រះទ័យពន់ពេក ។ តមកព្រះនាងមានបន្ទូលទៀតថា៖

– ឥឡូវនេះ សូមព្រះអង្គជ្រាបថា ហេតុអ្វីបានជាខ្ញុំម្ចាស់បំផ្លាញនូវស្បៀងអាហារទាំងឡាយហោល ? ព្រោះស្ដេចមុងគោលចង់ធ្វើគត់ព្រះអង្គហើយដាក់នគរចិនជានគរចំណុះ; ដើម្បីនឹងសំរេចគោលបំណងនោះដោយមិនបាច់ចាំច្បាំង ព្រោះការច្បាំងតែងតែមានការខូសខ្លោយ គេបានយកប្រាក់ទៅសូករដ្ឋមន្ត្រីរបស់ព្រះអង្គ ដែលត្រូវការៈខាងផ្គត់ផ្គង់ស្បៀងអាហារទ័ព ។ គេបានសូកមាសមួយរយពាន់សឹកាំង ហើយដោយអំណាចដម្លៃមាសនោះ វៃលលីបានដាក់ថ្នាំបំពុលគ្រប់កំប៉ុងអាហារទាំងអស់ ហើយថ្នាំនោះនឹងបណ្ដាលឲ្យស្លាប់ទាន់ចិត្តមួយរំពេច បើសិនជាខ្ញុំម្ចាស់មិនបំផ្លាញនូវអាហារទាំងនោះទេ ពួកសេនាទាហាននឹងនាយទាហានព្រះអង្គនឹងស្លាប់គ្មានសល់ ។ ប៉ុន្តែបើហែលជាព្រះអង្គពុំទ្រង់ជឿខ្ញុំម្ចាស់ទេ សូមព្រះអង្គទ្រង់ប្រើឲ្យវៃលលីបរិភោគអាហារមួយមាត់នៅចំពោះព្រះភក្ត្រព្រះអង្គលមើលចុះ ។

លុះមន្ត្រីទទួលការៈខាងស្បៀងអាហារមកដល់, ព្រះមហាក្សត្រទ្រង់បង្គាប់ឲ្យទៅរើសយកកំប៉ុងស្បៀងអាហារដែលនៅសល់ខ្លះ ។ បំរើម្នាក់បានយកត្រណាប់កំប៉ុងមួយនៅថ្មីសុទ្ធ ហើយមានត្រារបស់មន្ត្រីនៅលើនោះផង ។ ព្រះមហាក្សត្រទ្រង់ប្រើឲ្យបោះកំប៉ុង ហើយប្រើឲ្យវៃលលីភ្លក្សមើល ។ មន្ត្រីទូលតបវិញថា៖

– សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គព្រះរាជទានទោស ត្បិតនៅពេលនេះ ទូលព្រះបង្គំជាខ្ញុំពុំមានទឹកចង់ទេ ។

- បើឯងមិនសុខចិត្តស៊ីក្ដាមទេ ក្បាលអាក្បត់ឯងនឹងខ្ទាត់ចេញពីខ្លួនឥឡូវនេះ ។

លោកវែលលីគិតថា "ទៅខាងណាក៏ស្លាប់ បើដូច្នេះសុខចិត្តស្លាប់របៀបណាដែលមិនសូវមានឈាមហូរ" នឹកហើយមន្ត្រីអាក្រក់យកក្ដៅណាប់មកលិត ស្រាប់តែដួលស្លាប់នៅក្បែរព្រះបាទព្រះមហាក្សត្រមួយរំពេច ។

ព្រះនាងសេហេរ៉ាស្ដាទី លុះទតឃើញហើយក៏មានបន្ទូលថា៖

- មួងនេះ ព្រះអង្គជឿជាក់-អំពីការក្បត់នៃមន្ត្រីព្រះអង្គហើយ ប្រហែលជាព្រះអង្គយល់ច្បាស់ថាអាទិទេពមិនមែនធ្វើការអ្វី ដែលគ្មានប្រយោជន៍ទេ ។

- ពិតមែនហើយ ព្រះនាង! បងខុសត្រង់មិនបានការបញ្ញត្តិដែលប្អូនដាក់ឲ្យបង ឲ្យបានផុតចុងផុតដើម ប៉ុន្តែបងនៅតែពុំទាន់អស់សេចក្ដីព្រួយនៅឡើយទេ ព្រោះកងទ័ពគ្មានអាហារបរិភោគ, ការអត់ឃ្លាននឹងធ្វើឲ្យស្លាប់ដូចជាថ្នាំពុលដែរ ។

- ទេ, ទេ ព្រះអង្គ! ស្បៀងអាហារមិនខ្វះទេ ។ យប់នេះសូមព្រះអង្គចូលទៅលុកលុយទ័ពបច្ចាមិត្រ ហើយដណ្ដើមយកស្បៀងអាហារមក សឹមត្រឡប់ចូលព្រះនគរវិញ ដោយមានជ័យជំនះផង ។

នៅពាក់កណ្ដាលអធ្រាត្រ ព្រះនាងសេហេរ៉ាស្ដាទីហើយនឹងអាទិទេពទាំងអស់នាំគ្នាទៅកាន់ក្បាលទ័ពចិន ហើយចូលលុកលុយទ័ពមុងគោលពាល់តែដួលដេកដូចជាដើមស្រូវត្រូវខ្យល់ព្យុះ ។ ការប្រយុទ្ធមានដំណើរលឿនសម្បើម ទាល់តែមហាក្សត្រជាតិមុងគោលដែលទ្រង់

បេញដឹកមុខទ័ពដោយព្រះអង្គឯង រកស្មុះរត់ឲ្យរួចអាយុជីវិតដោយលំបាក ។ លុះព្រលឹមស្អែកឡើង ឃើញខ្មោចទាហានដេកស្លាប់ពេញតែវាល, ព្រះបាទរុស្ស៊ីនសាជទ្រង់សរសើរអំពីជ័យជំនះ របស់ព្រះអង្គ ដោយឃើញស្លាប់ទាហានរបស់ព្រះអង្គតិច ។

ព្រះរាជទេពីមានព្រះបន្ទូលចំពោះព្រះបាទរុស្ស៊ីនសាជថា ៖

– ពួកបច្ចាមិត្រព្រះអង្គទៅជាផង់ធូលីអស់ហើយ ការច្បាំងក៏ចប់ត្រឹមនេះ ។ ឥឡូវនេះ សូមព្រះអង្គត្រឡប់ចូលព្រះនគរគង់នៅជាសុខវិញចុះ ។ ចំណែកខ្ញុំម្ចាស់ទីងសូមលាព្រះអង្គ មួងនេះយើងត្រូវខានជួបគ្នាអស់មួយជីវិត ។ ព្រះអង្គនឹងលែងបានយល់ខ្ញុំម្ចាស់ទៀតហើយ គឺជាកំហុសរបស់ព្រះអង្គទេ ព្រោះព្រះអង្គពុំកាន់ពាក្យសច្ចៈ ។

– ថាម៉េច ! ឱព្រះគុណអើយ សូមព្រះនាងកុំនាំរឿងអតីតមង្គលនេះមកនិយាយទៀត សូមប្អូនអត់ទោសឲ្យបងចំពោះការដែលពុំបានគោរពពាក្យសច្ចៈ បងមានសេចក្តីបន្ទោសខ្លួនបងខ្លាំងណាស់ទៅហើយ ពីថ្ងៃនេះទៅបងស្បថជូននាង ថាបងលែងធ្វើអ្វីឲ្យប្អូនទាស់ចិត្តទៀតហើយ ទោះប្អូនធ្វើអ្វីក៏ដោយ សូម្បីគ្រាន់តែទឹកក្នុងចិត្តក៏បងលែងទឹកទៀត ។

– ការស្បថស្បែរបស់ព្រះអង្គជាការឥតប្រយោជន៍ទេ ត្បិតច្បាប់តម្រូវឲ្យខ្ញុំម្ចាស់ទៅឆ្ងាយពីព្រះអង្គ សូមទ្រង់កុំឃាត់ខ្ញុំម្ចាស់ . . . . . បើសិនជាត្រឹមតែខ្លួនខ្ញុំម្ចាស់មួយ ដែលត្រូវអត់ទោសចំពោះព្រះអង្គនោះខ្ញុំម្ចាស់មិនមែនជាអ្នកចិត្តរឹងរូឹងទេ . . . . បើដូច្នេះ ខ្ញុំម្ចាស់ថ្វាយបង្គំលាព្រះអង្គហើយ ឱ ! ប្តីសំឡាញ់ . . . ព្រះអង្គបាត់តាំងព្រះរាជបុត្រ

ទឹងព្រះទេពីផង . . . ហើយទោះជាព្រះអង្គបន់ស្រន់យ៉ាងណា ក៏មិនឃើញវិញដែរ ។

ថាហើយព្រះនាងព្រមទាំងព្រះរាជបុត្រទាំងពីរព្រះអង្គ ទ្រង់ព្រះកន្សែង ហើយស្រាប់តែបាត់អស់រលីងទៅ ។ ទោះបីព្រះអង្គបរាជ័យ ហើយធ្លាក់ទៅក្នុងដៃបច្ចាមិត្ត ក៏ទ្រង់ពុំសោកសង្រេងយ៉ាងនេះដែរ ។ ទ្រង់ខ្វាខ្វាំព្រះភ័ក្ត្រព្រះអង្គ ទ្រង់យកដីមកដាក់លើព្រះសិរសាហើយ ទឹងធ្វើអំពើផ្សេង ៗ ទៀត ហាក់ដូចជាទ្រង់វិកលចរិត ។

ប៉ុន្តែ ទ្រង់នាំក្បួនទ័ពទាល់តែមកដល់ក្រុងប៉ែកាំងវិញ លុះទ្រង់យាងចូលទៅដល់ព្រះបរមរាជវាំង ទ្រង់ត្រាស់ទឹងលោកមុយអេស៊ុនថា ៖

– ប្រមុខរដ្ឋ ! ខ្ញុំសូមប្រគល់ការៈការៈផ្សេង ៗ ក្នុងនគរលើអ្នក សូមអ្នកមើលការខុសត្រូវជំនួសខ្ញុំចុះ ខ្ញុំទុកពេលពីថ្ងៃនេះទៅទល់នឹងថ្ងៃស្លាប់ ដើម្បីសោកស្តាយប្រពន្ធនឹងកូនខ្ញុំ ដែលគេលែងឲ្យខ្ញុំឃើញមុខគេទៀត ដោយខ្ញុំមិនកាន់ពាក្យសច្ចៈ ។ ខ្ញុំលែងចង់ឃើញមុខអ្នកណាទៀតហើយ លើកតែលោកមួយទេ ហើយលោកមិនត្រូវនិយាយរឿងអ្វី ក្រៅអំពីរឿងប្រពន្ធកូនខ្ញុំមកប្រាប់ខ្ញុំទេ បំណែកខ្ញុំ ៗ គ្មានធ្វើអ្វីក្រៅអំពីកិច្ចព្រួយបារម្ភឡើយ ។

ក្រោយមកព្រះបាទរុស៊ាំនសាជ គង់សំងំក្នុងបន្ទប់ ដូចព្រះបន្ទូលទ្រង់មែន ហើយមានតែលោកមុយអេស៊ុនទេដែលទ្រង់អនុញ្ញាតឲ្យចូលបាន ។ រដ្ឋមន្ត្រីល្អនេះចេះតែចូលទៅសង្កេតមើលព្រះអង្គរាល់ថ្ងៃ ហើយសង្ឃឹមថាសេចក្តីទុក្ខរបស់ព្រះអង្គ នឹងរសាយទៅតាមពេលវេលា

មិនបាន ។ ប៉ុន្តែសេចក្តីទុក្ខរបស់ព្រះអង្គបែរជារឹងរិតតែខ្លាំងឡើង ៗ ទៅវិញ ។ ព្រះមហាក្សត្រទ្រង់សង្រែងសង្រៃយ៉ាងនេះ អស់រវាង ដប់ឆ្នាំ ។ ថ្ងៃមួយ នៅពេលដែលព្រះអង្គ នឹងសេចក្តីមរណៈនៅឃ្លាត ពីគ្នាតែពីជ្នាប់ ស្រាប់តែលេចព្រះនាងសេហេរិស្តាទីមក ហើយព្រះនាងមានបន្ទូលនឹងព្រះអង្គថា ៖

-ព្រះមហាក្សត្រ ! ខ្ញុំម្ចាស់មកបញ្ចប់នូវសេចក្តីទុក្ខរបស់ព្រះអង្គ ហើយជួយព្រះអង្គឲ្យបានមានព្រះជន្មឡើងវិញ ។ កិច្ចបញ្ញត្តិរបស់យើង តម្រូវឲ្យខ្ញុំម្ចាស់ព្រាត់ពីព្រះអង្គដប់ឆ្នាំ ដើម្បីជាទណ្ឌកម្មដល់ការប្រព្រឹត្ត លើស ហើយបើគង់រង់ដប់ឆ្នាំនោះ ព្រះអង្គនៅតែមានព្រះទ័យស្មោះ ស្ម័គ្រនឹងខ្ញុំម្ចាស់ ទើបខ្ញុំម្ចាស់ត្រឡប់មកជួបនឹងព្រះអង្គបាន ។ ហេតុ ដូច្នេះហើយបានជាខ្ញុំម្ចាស់ស្មានថា ពុំបានជួបព្រះភ័ក្ត្រព្រះអង្គទៀតទេ ព្រោះធម្មតាមនុស្សលោកពុំអាចនឹងអត់ធន់យូរឆ្នាំបាន មិនយូរប៉ុន្មានទ្រង់ នឹងភ្លេចខ្ញុំម្ចាស់ ។ ប៉ុន្តែខ្ញុំម្ចាស់ស្មានខុស ព្រោះព្រះអង្គនៅតែស្មោះ ត្រង់នឹងខ្ញុំម្ចាស់ជាដរាប ឥឡូវនេះខ្ញុំម្ចាស់ត្រឡប់មកវិញហើយ ។ ដើម្បី នឹងបំពេញអំណរព្រះអង្គខ្ញុំម្ចាស់នាំទាំងកូនពីរមកថ្វាយព្រះអង្គផង ។

នៅពេលនោះ ព្រះមហាក្សត្រស្រាប់តែទ្រង់ទតឃើញព្រះរាជបុត្រ ទាំងពីរព្រះអង្គនៅជិតព្រះអង្គ ធំហើយល្អចំណាប់... ព្រះអង្គម្ចាស់ក្សត្រា នឹងព្រះនាង បាល់-គីស សំដែងមនោសញ្ចេតនាស្រទន់ទៅរកព្រះបិតា ដែលទ្រង់ពុំបានទាំងស្គាល់ជាក់ផង ។ ព្រះមហាក្សត្រលុះទ្រង់យល់

ឃើញដូច្នោះហើយ ទ្រង់ព្រះករុណាទ្រង់ដោយរំជួលព្រះហឫទ័យពេក ៗ ប៉ុន្មានថ្ងៃក្រោយមក សុខភាពរបស់ព្រះអង្គក៏ចេះតែស្រស់ស្រាយមួយថ្ងៃបន្តិចៗ ។

ក្សត្រទាំង ៤ ព្រះអង្គ សោយរាជសម្បត្តិប្រកបដោយសុភមង្គលដ៏ប្រសើរ ។ ក្រោយព្រះបាទរុសភ័ន្ធសាជនីព្រះនាងសេហោរ័ស្តានីទ្រង់សុគតទៅ ព្រះអង្គម្ចាស់សេហោរ័ស្តង់ទ្រង់ឡើងគ្រងរាជ្យនៅប្រទេសចិន ឯព្រះនាងបាល់គីសទ្រង់ទៅសោយរាជ្យឯកោះសេហោរ័ស្តង់ ទាល់តែព្រះនាងបានមហាហោរាសាលូម៉ុនជាព្រះស្វាមី ។

ចប់

---

# សុភាសិតកជនីតិ

ពាក្យកាព្យ

## អ្នកឧកញ៉ាមហាវិប្ល័យ ពៅ

រៀបរៀង

(ត-ចប់)

---

សោតសឹងអំណរអរស្រេបស្រុះ ស្រីប្រុសសាទរទាំងផែនដី
ដោយសែនទាំងបែងពេចន៍វង្ស សឹងមានមេត្រីគ្រប់ប្រាណ ។
នេះដូចប្រជាជនជាតិជាក់ បានឃើញព្រះកត្រមហាក្សត្រក្សាន្ត
មានចិត្តត្រេកអរពន់ប្រមាណ ដូចបានឃើញវង់ព្រះច័ន្ទស្មោះ ។
យថាសព្វាភិភូតាធិ អាទិវាទោ ពាក្យសប្បុរស
ពោលថាផែនដីឥតបន្ទោះ ទ្រសត្វទាំងអស់ឲ្យអាស្រ័យ ។
ទោះល្អអាក្រក់មិនរើសមុខ តែងទ្រទ្រង់ទុកនៅសព្វថ្ងៃ
ពប់រកស៊ើគ្នាដោយនិស្ស័យ ឧបមេយ្យប្រៀបនេះដូចក្សត្រា ។
គ្រប់គ្រងអាណាប្រជារាស្ត្រ នៅទាសកម្មករខ្ញុំពជការ
ខាងក្នុងខាងក្រៅពងសីមា មេត្តាពប់ស៊ើដូច្នោះឯង ។
បដុំណ្ណោបតុមាសំ ដូរក្បៀនខ្ញុំប្រាកដស្តែង
វស្សានបួនខែមិនហួតហែង តិណ្ណតាំងតែងតាមកំណត់ ។
នេះដូចព្រះចៅចមផែនដី ប្រណីយោធាមិនឲ្យអត់
ព្រះទានធនធានមានប្រាកដ សន្ទតតាមរូបគុណវិជ្ជា ។

ទាំងគ្រឿងបរិភោគផងទាំងឡាយ   ថែកចាយសាយសព្វពលយោធា
សឹងមានបរិអរគ្រប់គ្នា   ដោយបុណ្យសម្ភារព្រះបារមី ។

បព្ចុគន្ធបដិតេបៈ   ខត្តិយៈ ប្រសើរសុខសិរី

គួរទ្រង់ប្រព្រឹត្តគតិគប្បី   សេចក្តីទសពិធដប់ប្រការ ។
មួយគឺបរិច្ចាគព្រះរាជទ្រព្យ   គួរគាប់ជាទានតាមប្រាថ្នា
មួយទ្រង់និច្ចសីលសមាចារ   ជ្រះថ្លាបរិសុទ្ធជាប្រក្រតី ។
មួយដប់លៀងខ្ញុំរាជការ   មេត្តាសន្តោសប្រោសប្រណី
មួយមានសន្តានល្អគប្បី   ព្រះទ័យស្លូតត្រង់ទ្រង់សុចរិត ។
មួយមានព្រះទ័យទ្រង់លំទោន   អត់ធុនសន្តោសដោយក្រមក្រិត្យ
មួយមានព្រះទ័យតាំងជាប់សុទ្ធ   ថេរបិតដោយនូវក្តីមេត្តា ។
មួយទ្រង់នូវសីលឧបោសថ   លំឧតរិតប្រុងរក្សា
មួយមានព្រះទ័យទ្រង់ករុណា   មិនហិង្សាបៀតបៀនសត្វទាំងឡាយ ។
មួយទ្រង់ខន្តីក្តីអំណត់   សង្កត់ក្តីក្រោធឱ្យរសាយ
មួយមានរាជកិច្ចទ្រង់ខ្វល់ខ្វាយ   តាមតំរាយបុរាណក្សត្រា ។
ទសពិធដប់នេះជាក្រិត្យក្រម   ក្សត្រឧត្តមគួរខំថែរក្សា
ប្រព្រឹត្តប្រតិបត្តិគ្រប់ប្រការ   ហោះមហាកិត្តិយសខ្ពស់ថែមមាន ។
ហើយទ្រង់ប្រកបដោយឧស្សាហ៍   មនសិការធម្មសាត្រជាប្រធាន
ព្រមទាំងរាជនីតិគិតរិះផ្សាន   មិនបំពានឱ្យឃ្លាតពីព្រះទ័យ ។
ប្រកបព្រមហេតុបួនប្រការ   មួយទ្រង់ពិចារណាដោយប្រពៃ

សេចក្ដីគាប់ខុសផ្ទុះវៀងវៃ　ជ្រាបន័យទំនងដំណើរក្សត្រ ។
ជាធ្វើអំពើប្រយោជន៍ផល　ប្ដូរធ្វើកន្លល់ឲ្យវិនាស
ប្រយោជន៍ហោចហើនមិនទុកាស　ប្រាសជៀសប្រយោជន៍ពាក់ព្រះអង្គ ។
មួយទ្រង់ឧបត្ថម្ភព្រមមនុស្ស　ដែលលុះសីលសត្យសុចរិតត្រង់
ធ្វើវត្តប្រតិបត្តិចិត្តផិតផ្ចង់　គួរទ្រង់ស្រោចស្រង់ដោយត្រូវការ ។
មួយទ្រង់ប្រមូលព្រះរាជទ្រព្យ　រំពាប់គាប់គួរទុករក្សា
តាមដោយយុត្តិធម៌ថ្លៃថ្លា　សម្មាសុចរិតពិតប្រពៃ ។
មួយទ្រង់រក្សាព្រះនគរ　មិនឲ្យរើករមានមោះមៃ
ក្សេមក្សាន្តសាន្តសុខឥតទុក្ខភ័យ　ដោយន័យយុត្តិធម៌ទសពិធ ។
មួយបិតកុងកិច្ចរាជវេណី　វិធីគួរទ្រង់តាមរាជនីតិ
សំដែងជាស្ដេចគួររិះគិត　ប្រព្រឹត្តឲ្យព្រមសុវត្ថិ ។
គឺពេលព្រលប់យប់សន្ធ្យា　រាជាក្រសាលត្បូងជន្ទ្រ
ហួសយាមបឋមគួរចក្រី　ស្ដាប់អាថ៌សេចក្ដីរឿងបុរាណ ។
ហើយព្រះសណ្ដាប់ច្បាប់វេណី　វិធីយុត្តិគ្រប់ស្ថាន
ដើម្បីជ្រាបកិច្ចធម៌កល្យាណ　លំអានក្ដីល្អលោកពណ៌នា ។
លុះដល់បច្ឆិមយាមចូលបន្ទំ　មនោរម្យក្សាន្តព្រះទយា
ផ្ទំស្កល់លុះដល់ពេលវេលា　រាជាតើនចាកបន្ទំទី ។
បែរអង្គទោះត្រង់បូព៌ទិសា　ទ្រង់ស្រប់កន្ទ្រាដោយវារី
ស្រេចទ្រង់គ្រឿងគ្រប់រឿងរូជី　បរលីចេញទតខំរាជការ ។
គឺពួកអមាត្យរាជបណ្ឌិត　ព្រាហ្មណ៍ព្រឹទ្ធហោរាចារ្យ

ព្រមព្រះរាជវង្សនុវង្សា មន្ត្រីសេនាគ្រប់ក្រសួង ៗ
ទើបស្តេចសីហនាទយាងយាត្រា កាន់សាលអាយ៉ាសាលាហ្លួង
សំរាប់វិនិច្ឆ័យក្តីទាំងពួង ផ្ចង់ផ្ចួងហឫទ័យទ្រង់សណ្តាប់ ៗ
អស់ទាំងតុលាការប្រឹក្សាក្តី យុត្តិគប្បីខុសច្បាប់
ឬមួយវៀចវេរវេរក្រឡាប់ ទ្រង់ប្រាប់ហាមប្រាមតាមអាជ្ញា ៗ
ហើយតាំងព្រះទ័យដោយសុចរិត ប្រព្រឹត្តយុត្តិសមាចារ
យកព្រះធម្មសាស្ត្រជានេត្រា ទតអាថ៌សេចក្តីយល់ពាក់ជ្រៅ ៗ
យកសតិសម្បជញ្ញៈ ជាហត្ថៈខាងស្តាំចាំជាប់នៅ
ទ្រង់ព្រះខ័នកែវក្លីសស្នៅ ពោលហៅវិចារណបញ្ញា ៗ
នឹងទ្រង់វិនិច្ឆ័យសេចក្តីពស្តា ឲ្យចៀសវៀសចាកគរហា
ដំរិះត្រិះរិះពិចារណា ចរិយាយុត្តិធម៌ប្រពៃ ៗ

កាលិនោសុបិយាសុរា សេរគាអមាត្យណាមួយនៃ
មានវង្សត្រកូលឥតមោះមៃ វៀងវៃក្លៀវក្លាការទាំងឡាយ ៗ
ហើយបានត្រេកត្រាប់ស្តាប់ត្រងរង កន្លងដំណើរគ្រប់បរិយាយ
ស្ទាញស្ទាត់បាឋបទអភិប្រាយ ខ្វល់ខ្វាយអាចចាំទូរពជទឹត ៗ
ជាទីសំឡាញ់នៃជនជាតិ មារយាទជាមនុស្សតែងរិះគិត
គួរទ្រង់យកប្រើគាល់ជាប់ជិត ជំនិតជិតអង្គព្រះភក្រ ៗ

សុត្តវាសីលវាសុចោ បាហៅ បាឋនេះលោកស្រដី
សំដែងថ្លែងថាជាមន្ត្រី មានអង្គប្រាំបីជាប្រធាន ៗ

មួយគឺបានស្តាប់ត្រាប់មកច្រើន ចំរើនជំរះបេះរះធ្យាន
មួយគឺប្រកបដោយសីលទាន មួយគឺសោតមានចិត្តក្លៀវក្លា ។
មួយមានព្យាយាមច្រើនអនេក អតិរេកប្រកបដោយឧស្សាហ៍
មួយគឺគិតចំធ្វើរាជការ ប្រាជ្ញាឲ្យរួចហើយឲ្យឆាប់ ។
មួយមានកំឡាំងខ្លាំងប្រាកដ មួយអត់មិនលោភខុសក្រៅច្បាប់
មួយមានរូបទ្រង់អង្គចំណាប់ ជនជាតិចង់តាប់ចិត្តស្នេហា ។
បុរសប្រកបអង្គប្រាំបី ប្រាកដសេចក្តីដូចេះណា
ទើបនឹងសមគួរជាមាត្យា សញ្ញាសន្មតជាមន្ត្រី ។

អពុទ្ធំ ពោធយិ អត្ថំ វាបំ បទនេះតែសេចក្តី ។
សំដែងថាអម្ចាស់ផែនដី គប្បីឲ្យជ្រាបប្រជារាស្ត្រ
ណាមួយមិនដឹងប្រយោជន៍ផល កិច្ចកលការងារជាឧកាស
ទ្រង់ប្រៀនប្រដៅឥតរង្កៀស ឲ្យឈ្លាសឆ្លាតដឹងគ្រប់ប្រការ ។
ហើយកាត់សន្ទិះរាស្ត្រសង្ស័យ ឧបមេយ្យពន្យល់ឲ្យក្តីថ្លា
ទ្រង់តែងសំដែងគុណក្សត្រា ដល់រាជបរិវារនឹងព្រះអង្គ ។

បាបំ ខត្តិយំ និវារយ្យ ព្យញ្ជនៈបាឋនេះលោកថ្លែងត្រង់
ថាខ្ញុំរាជការគួរផ្ចិតផ្ចង់ តាំងចិត្តតម្រង់តម្រែកគិត ។
ដោយហេតុប្រាំមួយក្នុងសន្តាន ស្មានទីមួយគួរពិនិត្យ
គប្បីទូលទាស់ព្រះបពិត្រ កាលទ្រង់ប្រព្រឹត្តមិនគប្បី ។
មួយឲ្យប្រកបក្តីចំរើន ប្រយោជន៍ដ៏ច្រើនក្នុងផែនដី

មួយជួយបិទបាំងការអប្រិយ    ដែលព្រះចក្រីធ្វើមិនល្អ ។
មួយគឺសំដែងគុណអម្ចាស់    ឲ្យច្បាស់ប្រាកដដោយស្មោះសរ
មួយកាលអម្ចាស់មានក្រីក្រ    កំដរទ្រាំទ្រមិនចោលម្ចាស់ ។
មួយកាលអម្ចាស់លើសិរសា    មានការខិតខាតកម្រណាស់
អាចជួយសង្គ្រោះចំពោះច្បាស់    ក្រឡាស់គិតកែតាមកំឡាំង ។
លក្ខណៈប្រាំមួយនេះជាខាត    អមាត្យគួរមានជាទីតាំង
ពល់ខ្លួនគួនគួរជាពាសំ    សញ្ញាមានសព្វគ្រប់រូបា ។
កោធំសោកំភយំលោភំ    វាក្យំ បទនេះសំដែងថា
ជាស្តេចគប្បីតាំងប្តេជ្ញា    កន្លងហេតុការណ៍ប្រាំមួយពិត ។
មួយគឺកាលទ្រង់ព្រះពិរោធ    ក្រេវក្រោធសោតសឹងមិនពិនិត្យ
មួយគឺសោយសោកអម៉ោកគិត    មួយគឺភ័យភិតទឹកខ្លាចក្រែង ។
មួយគឺលោភក្រៅគន្លង    កន្លងទំនងព្រះសំដែង
ប្រការមួយទៀតលោកថាថ្លែង    គឺអែងវិនាសត្រកូលស្មោះ ។
មួយគឺទ្រង់ខ្លាចវិនាសទ្រព្យ    រិះពប់ខ្លាចខ្លួនគួនខ្លាចអស់
មិនប្រុងទ្រង់ប្រើដោយសប្បុរស    តាមរបស់ដែលគួរជាពុជការ ។
ហេតុប្រាំមួយនេះគួរមហាក្សត្រ    លះកាត់ណាតចេញកុំកង្វា
ទើបធ្វើជាស្តេចអគ្គឥស្សរ    កន្ទឹមមហាស្តេចឆ័ត្រប្រាកដបាន ។
ពលំសមេធសាធេយ្យៈ    ភារៈកំណត់បទបុរាណ
សំដែងចែងទុកជាលំអាន    ដើម្បីក្សត្រក្សាន្តបមដែនដី ។

ទឹងទ្រង់ទរមានប្រដៅមនុស្ស ឲ្យលុះអំណាចខ្លាចបារមី
នោះឲ្យប្រកបដោយសេចក្តី គប្បីដោយន័យដូច្នេះណា ។
បើមនុស្សមានរិទ្ធិខ្លាំងពូកែ មានតែខ្ញុនាទមើលកល់ការ
ដោយឲ្យព្រមព្រៀងទើបរកា មិនក្លាទឹងខ្លាចអំណាចបាន ។
ខ្ញុំនាមមនុស្សខ្លាចនោះឲ្យបែក ចំណែកបក្សពួកជាប្រមាណ
ទើបមិនរដច់ចុចថប់ខាន ទឹងក្រៀវក្លាហានមិនក្លឹកភ័យ ។

ខ្ញុំនាមមនុស្សលោកដោយឲ្យទ្រព្យ របស់គួរគាប់ផងទីទៃ
ទើបទឹងមានចិត្តស្និទ្ធប្រពៃ ឥតមានមោះមៃក្តីប្រូស្សា ។
បើមនុស្សទិដ្ឋិប្រដៅក្រ ខ្ញុំនាទខានល្អមិនប្រាថ្នា
ប្រដៅឲ្យជាក់ព្រះអាជ្ញា ទើបរកាពពង់ខ្លាចបារមី ។

## កោសោភាជាគ្រួមួល វាក្យ តាំងតែងតាមបាលី

ប្រៀបប្រាយអធិប្បាយជាសេចក្តី ដើម្បីប្រាបដល់អង្គក្សត្រា ។
ឯអង្គឥស្សរពេរពេរត្ន សន្ទតប្រៀបដូចដើមរុក្ខា
ពជវង្សានុវង្សមិត្តមាត្យា ឧបមាដូចមែកឈើទាំងឡាយ ។

នាយឃ្លាំងលោកទុកដូចឫសឈើ ហេតុធ្វើគំនិតគិតខ្វល់ខ្វាយ
រក្សាពជទ្រព្យមិនខ្ចាត់ខ្ចាយ មិនឲ្យអន្តរាយវិនាសបង់ ។
ក្សត្រាបើប្រាសវិនាសទ្រព្យ សម្បត្តិគួរគាប់ពីព្រះអង្គ
ដូចកលវិបាកបក្សីហង្ស ប្រាសបង់តាកស្លាបដូច្នោះឯង ។
ដូច្នេះគួរព្រះមហាក្សត្រ ប្រតិបត្តិព្យាយាមខំខ្នះខ្នែង

រកទ្រព្យដោយធម៌ប្រាកដស្ដែង　　តាក់តែងតាំងទុកការអន្តរាយ ។

និប្ផាវិលុភតិក្ខាតិ　　អាទិវាទោ ពាក្យបរិយាយ

សំដែងថាស្ដេចផងទាំងឡាយ　　គួរទ្រង់ខ្វល់ខ្វាយរិះរក្សា ។

ព្រះរាជអាណាខែត្រដែននគរ　　ឲ្យសុខសាទរគ្រប់ប្រការ

រូបចាកសត្រូវចិត្តក្លៀវក្លា　　មិនហ៊ានប្រាថ្នាមករុករាន ។

ហើយរូបចាកមនុស្សប្រើប្រការ　　កំណាត់ច្នេះថាជាប្រធាន

មួយរូបចាកមនុស្សស្និទ្ធស្នាលហ៊ាន　　ឥតមានរអែងក្រែងមិនគួរ ។

មិនឲ្យរូបចាកមនុស្សមានទ្រព្យ　　មួនមាំលើសលុបគួតអាងតួ

មួយរូបពីមហាចោរជួរ　　មៀមួរមែនមានតែទុច្ចរិត ។

មួយទៀតគប្បីទ្រង់រក្សា　　ទាំងខាព្រះឃ្លាំងឲ្យថេរថិត

សម្បត្តិសម្បូណ៌ដ៏វិចិត្រ　　ឲ្យស្និទ្ធប្រពៃគ្រប់ប្រការ ។

ទើបបានប្រាកដប្រកបឈ្មោះ　　បំពោះពេញពិតជារក្សា

ព្រះរាជអាណាខែត្រដែនសីមា　　ឲ្យវិត្ថារថេរថិតឥតមោះមៃ ។

ឥទំសុត្តអនិយាតោ　　វាទោ បាឋបទកំណត់ន័យ

គម្ពីរាជនីតិពិតប្រពៃ　　បណ្ឌិតគិតតែតែងទុកមក ។

ថាបើជាក្សត្រអង្គឯណា　　មនសិការត្រេកត្រាប់ស្ដាប់កាន់យក

ទុកក្នុងព្រះទ័យរៃរិះរក　　លៃលករៀបរាប់ឲ្យខ្ជាប់ខ្ជួន ។

នឹងជ្រាបហេតុកលដែលកំសត់　　សត្រូវឲ្យបាត់ខ្ចាត់មែនមួន

ខូបខ្វាបមិនអាចមកគុំគួន　　ថែជូនរាបទាបទាំងភាព ។

លុះដល់អវសានកាលបំផុត ទីវង្គតលេតព្រះជន្មា
ទឹងបានសោយសុខក្នុងសួគ៌ា វេឡ្យនាបំពេនបុណ្យបារមី ៗ
ព្រោះព្រះពជាទ្រង់ប្រព្រឹត្ត ទសពិធរាជធម៌ល្អគប្បី
សុខទាំងបរលោកទាំងលោកិយ ប្រាកដសេចក្តីដូច្នេះឯង ៗ

កាសិតរាជនីតិ៍នេះអ្នកឧកញ៉ា មហាវិនិច្ឆ័យ គៀ តាត់វែង
តាមក្បួនព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតតែង សំដែងជាច្បាប់ប្រាប់កិប្រាយ ។
មួយឈ្មោះអនន្តញាណព្រាហ្មណ៍ មួយនាមសុកៈព្រាហ្មណ៍ចាំបរិយាយ
ជាចមកជគ្រូតែងខ្វល់ខ្វាយ អធិប្បាយរឿងនេះកាលសាសនា ៗ
កន្លងទៅហើយហួសប្រាកដ កំណត់បានប្រាំរយព្រះវស្សា
ថ្វាយអង្គចមពង្សព្រះក្សត្រា អភយគាមណីក្សត្រឧត្តម ៗ
តែក្បួនបុរាណជាពាក្យពាយ និយាយសារសព្វប្រាប់ក្រិត្យក្រម
ទើបខ្ញុំរិះគិតលិខិតផ្សំ ឲ្យបំជាប់ដូនជាកាព្យ ៗ
ប្រយោជន៍ដើម្បីជាសណ្តាប់ ជនជាតិត្រង់ត្រាប់ច្បាប់ពណ៌នា
ជាក្បួនគួនគួរចាំគ្រប់ឃ្លា វណ្ណនាកាសិតចប់ម៉្លេះហោង ៗ

ចប់

# ពេជ្រព្រះរាជា

លោក ស៊ិន-ហាំង ប្រែរៀបរៀង

លោក យូរ-អ៊ិន ពិនិត្យកែសម្រួល

(តមក)

---

មាណពមានសេចក្ដីត្រេកអរពន់ពេក កើតបីតិចំពោះបុណ្យដែលកើតឡើងពីការជួយសត្វមានជីវិតជាចំនួនច្រើន ដែលកំពុងមានទឹកភ្នែកហូរ, ទើបថ្វាយបង្គំព្រះរាជា ហើយក្រោកទៅចាប់ដៃអមាត្យបាលិតនាំដើរទៅឯកន្លែងមេគោស ស្រាយចំណងដែលចងរឹតទាំងខាងមុខនិងខាងក្រោយបណ្ដោយឲ្យដើរទៅតាមសេរី, កូនគោរត់តាមមេរបស់វា ស្រែកពេញហ៊ូៗ បណ្ដើរៗទៅ សភាពដូច្នេះ បណ្ដាលឲ្យមាណពនិងអមាត្យបាលិតមិនអាចអត់ទ្រាំនូវការភ្ញាក់ផ្អើលញាប់ញ័រក្នុងចិត្តបានឡើយ ។

បុគ្គលអ្នកមានធម៌នៅក្នុងខ្លួន រមែងជួបប្រទះនូវសេចក្ដីសុខសេចក្ដីចំរើន ជាទីសរសើររបស់មនុស្សទាំងឡាយ ដូចមាណពកម្លោះនេះជាដើម ។ មាណពបានយកជីវិតរបស់ខ្លួនទៅរងគ្រោះជួសជីវិតសត្វជាចំនួនច្រើន ដោយការធានារក្សាព្រះរោគព្រះអង្គម្ចាស់ក្សត្រដោយឱសថ ១ មុខ, មាណពស្គាល់គុណានុភាពរបស់ថ្នាំ ១ មុខនេះ អំពីពួកអ្នកដើរព្រៃដែលណែនាំឲ្យមានទុកសម្រាប់ការពារខ្លួន, ឱសថនោះគឺជាប្រទាល ១ បែបកើតមានក្នុងព្រៃ តិចមានអ្នកណានឹងស្គាល់, ប្រទាល ១ មុខនេះឯងជាថ្នាំកែរោគបានច្រើនបែប; អ្នកដែលនៅក្នុងព្រៃច្រើនប្រើ

ប្រទាលនេះសម្រាប់តែរោគគ្រប់យ៉ាង ។ កាលបើមាណពនាំប្រទាល ១ មុខនេះមកហើយ ក៏យកមកស្លោរជាមួយនឹងកេសរផ្កាឈើ រួចបញ្ជូនទៅថ្វាយព្រះអង្គម្ចាស់ក្សត្រី, តាំងអំពីថ្ងៃនោះមក ថ្នាំរបស់មាណពក៏ឲ្យផល គឺព្រះអង្គម្ចាស់ក្សត្រីសោយឱសថនេះទៅបានកំចាត់រោគដែលប្រឈួននោះ, តាំងអំពីថ្ងៃដំបូងដែលបានសោយថ្នាំនេះ ដូចបានសោយអាហារទិព្វដ៏វិសេស ធ្វើឲ្យមានព្រះកាយពលចង់សោយព្រះក្រយា·ស្ងោយ, ត្រឹមតែ ៦ រាត្រីកន្លងផុតទៅ ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះអាការប្រក្រតីដូចដើមវិញ ។

ពួកអ្នកស្រុកដែលកើតរោគរប័ក្យ បានទទួលថ្នាំរបស់មាណព ១ មុខនេះគ្រប់គ្នា, ថ្នាំពិសេសអស្ចារ្យនេះ ដែលអ្នកស្រុកមានទុក្ខវេទនាបានបរិភោគទៅហើយ អាចធ្វើឲ្យវិនាសបាត់រោគក្នុងវេលាដ៏រហ័ស, មិនយូរប៉ុន្មាន អ្នកស្រុកស្ទើរតែភ្លេចនូវរោគដ៏អាក្រក់ដែលគួរស្រៀវខ្លាចនោះ, ការវិប្បយោគពេលពលដែលធ្លាប់មានក្នុងស្រុកទូទៅ ក៏បានប្រាសចេញអស់ មានតែសម្មេងអ៊ូអែដែលធ្លាប់មានមកក្នុងនគរវេសាលីដូចពីដើមឡើងវិញ ។

អ្នកស្រុកនាំគ្នាសរសើរកិត្តិគុណរបស់មាណព ស្ទើរតែពុំដាច់ពីមាត់ ហើយទុកមាណពនោះដូចជាទេវតា ១ អង្គ ។ ការសរសើរបែបនេះមិនមែនតែពួកអ្នកស្រុកប៉ុណ្ណោះទេ ព្រះរាជានិងព្រះរាជធីតាក៏ទ្រង់សរ·សើរដូច្នោះដែរ, សេចក្តីទុក្ខរបស់ព្រះរាជាដ៏ធ្ងន់ក្នុងគ្រានេះ ក៏ផុតរលត់អស់ពីព្រះទ័យ ។

ទឹងថ្ងែងពីមាណពនឹងអមាត្យបាលិតវិញ, ព្រះកដាបានចាត់ចែងឲ្យជនទាំង ២ នាក់នេះនៅស្នាក់ក្នុងបរិវេណព្រះបរមរាជវាំង ឲ្យមានទាហានចាំយាមល្បាតយ៉ាងម៉ឺងម៉ាត់ ដើម្បីការពារមិនឲ្យលបរត់ចេញបាន, តែលុះដល់មាណពរក្សាព្រះអង្គម្ចាស់ក្សត្រីនឹងរោគរប័ក្សាដែលកើតមានដល់អ្នកស្រុកឲ្យស្ងប់រម្ងាប់ហើយ ព្រះកដាទើបបន្ធូរនូវការតឹងតែងឲ្យមាណពនឹងអមាត្យមានសេរីភាពឡើងវិញ ។

ក្នុងវេលាល្ងាចនៃថ្ងៃទី ៦ មាណពនឹងអមាត្យអង្គុយសន្ទនាគ្នានៅក្រោមម្លប់ចាមចុរី ជិតទីស្នាក់របស់ខ្លួន ។ មាណពអង្គុយស្តាប់ផង ត្រេកអរចំពោះសេចក្តីសម្រេចនូវវត្ថុបំណងដ៏ធំរបស់ខ្លួនផង ទើបពោលតបនូវសេចក្តីមួយវគ្គចំពោះអមាត្យថា ៖

“ ចាត់ជាវាសនាល្អរបស់ខ្ញុំ ដែលខ្ញុំបានមកជួបនឹងលោកជាអមាត្យធំ របស់ព្រះបាទធម្មបតី ជាព្រះកដានៃនគរពារាណសី ដោយមិនបាននឹកយល់សប្តិជាមុនសោះ ” ។

អមាត្យបាលិតបានស្តាប់មាណពពោលលើកតំកើងដូច្នោះ ក៏ពោលតែដោះសាថា ៖

“ កុំថាដូច្នោះឡើយ មាណព ! ការណ៍នេះចាត់ជាវាសនាល្អរបស់ខ្ញុំដូចគ្នានឹងលោកដែរ ខ្ញុំបានបេះដឹងឡើងដោយសារលោក ចាត់ថា លោកជាអ្នកមានគុណដល់ខ្ញុំច្រើនប្រការ ” ។ ពាក្យរបស់អមាត្យបាលិតនេះនិយាយផ្សំទៅតាមសេចក្តីដឹងខ្លួន និងសេចក្តីពេញចិត្តយ៉ាង

ក្រៃលែងចំពោះមាណព អមាត្យទើបកើតមានគំនិតចង់ដឹកអន្ទងមាណព ឲ្យទៅគាល់ព្រះបាទធម្មបតី ក៏ពោលថា:

" មាណព ខ្ញុំជាមនុស្សចាស់ជាងលោកក៏ពិត តែខ្ញុំធាប់ជឿគេងាយ ៗ ចំពោះពាក្យដែលគេនិយាយនូវសេចក្ដីមិនមានខ្លឹមសារ ទាល់តែជីវិតខ្ញុំកន្លងមកដល់វ័យប៉ុណ្ណេះ បើប្រសិនជាខ្ញុំមិនបានជួបនឹងលោកទេ ខ្ញុំក៏មិនអាចដឹងបានថា ខ្ញុំនឹងត្រូវធ្វើដំណើរជីវិតបែបណា ក្នុងវ័យខាងចុងតទៅទៀយ " ។

សំដីរបស់អមាត្យបាលិត បរិបូណ៌ទៅដោយសេចក្ដីពិតគ្រប់ប្រការ ព្រោះចាប់តាំងពីមកស្នាក់នៅជាមួយនឹងមាណព បានសាកសួរសេចក្ដីផ្សេង ៗ ដែលជាប់ទាក់ទងនឹងព្រះសម្មាសម្ពុទ្ធជាម្ចាស់ ហើយមាណពក៏អាចពន្យល់ឲ្យចូលចិត្តបាន ។ មាណពកាលដឹងនូវគោលសេចក្ដីឯណាដែលជ្រាលជ្រៅនឹងពក់ ៗ អំពីភិក្ខុសង្ឃទាំងឡាយ មាណពក៏យកសេចក្ដីនោះមកប្រាប់អមាត្យ ដើម្បីឲ្យអមាត្យបានយល់ច្បាស់លាស់ឡើង, ចំណែកអមាត្យបាលិតមានដឹងរឿងរ៉ាវនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះខ្លះដែរ ដោយចំពោះតែត្រង់ដែលព្រះសម្មាសម្ពុទ្ធទ្រង់រំលត់ខន្ធចូលកាន់បរិនិព្វាន ។

អមាត្យបាលិតកាលសន្ទនាមកល្មមសមគួរហើយ ក៏មានការចង់ដឹងដល់ត្រកូលដំពិតប្រាកដរបស់មាណព ព្រោះបានសង្កេតឃើញថាជាអ្នកមានសេចក្ដីចេះដឹងនឹងមានសមត្ថភាពគ្រប់គ្រាន់ ទាំងសរីរៈពង់កាយ

ក៏គួរដល់នូវភាពជាអ្នកល្អ មានទម្រង់នៃការសិក្សាមកយ៉ាងខ្ពង់ខ្ពស់ ទើបសួរនូវរឿងរ៉ាវនេះឡើងថា:

" អើមាណព ! ខ្ញុំនៅស្នាក់រួមជាមួយនឹងលោកនាំឲ្យខ្ញុំមានសេចក្ដីសុខស្រួល ព្រោះលោកមានអធ្យាស្រ័យល្អមករកខ្ញុំ ឥឡូវនេះ ខ្ញុំចង់ដឹងនូវទីកន្លែងស្រុកទេសដ៏ពិតប្រាកដរបស់លោក ព្រោះខ្ញុំមិនទាន់បានដឹងថាលោកមានពូជពង្សវង្សត្រកូលយ៉ាងណា នឹងស្រុកកំណើតនៅទីណាឡើយ បើលោកមិនមានបំណងទំនឹងបិទបាំងទេ សូមមេត្តាប្រាប់ខ្ញុំឲ្យបានដឹងផង " ។

កាលអមាត្យបាលិតសួរដល់រឿងរ៉ាវរបស់មាណព។ ក៏ប្រែទឹកមុខឆ្លើយតបតាំងទឹកមុខស្ងួតថា :

" ខ្ញុំមិនរង្កៀសទេ ចំពោះការរៀបរាប់ប្រាប់នូវសេចក្ដីប្រព្រឹត្តទៅនៃខ្លួនខ្ញុំឲ្យលោកបានជ្រាប តែបើលោកជ្រាបហើយក៏មិនមានប្រយោជន៍អ្វីដល់លោក, នៃលោក ! ជីវិតខ្ញុំខុសប្លែកអំពីបងនឹងប្អូនខ្ញុំ ទុកជាមនុស្សអភ័ព្វពន់ពេក, ត្រកូលរបស់ខ្ញុំក៏មិនមែនទាលក្រប៉ុន្មានទេ បិតារបស់ខ្ញុំជាសេដ្ឋីមហាសាលឈ្មោះជោតិកៈ មាតាឈ្មោះចន្ទាវតី, ជប្អូនឡើយបិតារបស់ខ្ញុំជាជាងមាសម្នាក់ ដែលមានស្នាដៃដ៏ជំនាញក្នុងនគរកជគ្រឹះ លុះកាលលោកជរាហើយ ក៏បានបញ្ឈប់មុខរបរនេះចេញតាំងមិនបានប្រកបការលក់ដូរអ្វីដទៃទៀតទេ ព្រោះទ្រព្យសម្បត្តិដែលមានមកពីមុន នឹងយកមកបរិភោគប្រើប្រាស់តាយរាយដរាបដល់អស់ជីវិតក៏មិនអស់ផង ។ ចុងឆ្នាំដែលកន្លងមកនេះ ព្រះរាជាមានព្រះរាជបំណង

ឲ្យបិតាខ្ញុំធ្វើម្កុដថ្វាយ  ព្រោះទ្រង់ជ្រាបថា បិតាខ្ញុំមានស្នាដៃជាជាងមាស ដ៏ជំនាញ  ដោយហេតុនេះបិតាខ្ញុំមិនអាចទទឹងទាស់ព្រះរាជបំណងបាន ឡើយ, កាលបើព្រះរាជាប្រគល់មាសនឹងពេជ្រឲ្យបិតាខ្ញុំ ខ្ញុំក៏មិនបាននឹក ដល់ដើមហេតុ ដែលត្រឡប់នាំឲ្យមានរឿងមានសេចក្ដីទុក្ខធំដល់រូបខ្ញុំទេ; សេចក្ដីទុក្ខធំដែលកើតឡើងក្នុងគ្រានោះ នៅជាប់តាមខ្ញុំដរាបដល់សព្វថ្ងៃ នេះ" និយាយចប់ មាណពក៏ដកដង្ហើមធំ មានទឹកមុខប្រែខុសប្រក្រតី ។

អមាត្យបាលិតស្ដាប់ហើយទើបតបថា:

"ចុះមានហេតុការណ៍យ៉ាងណាកើតឡើងដល់លោក? ខ្ញុំមិនចង់ឮ ទេថាភ័យកើតឡើងដល់បិតាមាតារបស់លោក, ហើយខ្ញុំស្មានថាមិនមែន ដូច្នោះទេដឹង!" ។

"មែនលោក! ខ្ញុំមិនកុហកលោកទេ មនុស្សក្នុងស្រុកខ្ញុំ មិនមាន នរណាចង្អៀតចង្អល់ចិត្តក្នុងរឿងនេះស្មើនឹងខ្ញុំឡើយ, ព្រះរាជានោះ កាល ទ្រង់ប្រគល់ម្កុដមាសឲ្យបិតាខ្ញុំ  បិតាខ្ញុំក៏បានធ្វើឡើងដោយផ្ចិតផ្ចង់ក្នុង វេលាត្រឹមតែ ២ ខែប៉ុណ្ណោះក៏ហើយស្រេច  ទើបប្រើមនុស្សឲ្យទៅណាត់ ពេលវេលានឹងអមាត្យធំ ឲ្យមកទទួលយកម្កុដទៅថ្វាយព្រះរាជា, អមាត្យ នោះជាមនុស្សស្មោះត្រង់  ជាទីទុកព្រះទ័យរបស់ព្រះរាជាជាងនាម៉ឺន ទាំងឡាយ,  សូម្បីលោកជាមនុស្សស្និទ្ធស្នាលរបស់ព្រះរាជាមកប៉ុណ្ណា ក៏ដោយ  ទ្រព្យរបស់លោកក៏មានត្រឹមតែបរិភោគគ្រប់គ្រាន់ប៉ុណ្ណោះ មិនដល់ទៅមានស្ដុកស្ដម្ភដូចជាសេដ្ឋីឡើយ  ។ ការទទួលបំរើព្រះរាជា ក្នុងការគ្រប់គ្រងតំណាងព្រះនេត្រព្រះកាណ៌ ដែលជាប់ទាក់ទងនឹងប្រជា

ពស្ត្រ ប្រព្រឹត្តទៅយ៉ាងស្មោះត្រង់ ទើបជាទីរាប់អានរបស់ប្រជាជនទូទៅទាំងនគរ, គេនាំគ្នាសន្មតឈ្មោះសម្រាប់ហៅ "នន្ទិអមាត្យ" ។

លោកនន្ទិ កាលបានជ្រាបថាបិតាខ្ញុំធ្វើម្ហូបស្រេចហើយ ក៏ប្រុងប្រៀបខ្លួនឯងមកទទួល តែដូនជាមិនស្រួលសប្បាយខ្លួនក៏ឲ្យបុត្រប្រុសមកទទួលជំនួស បិតាខ្ញុំបានប្រគល់ម្ហូបឲ្យបុត្រប្រុសរបស់លោកនន្ទិហើយ លុះតមកទៀតចំនួនពីរថ្ងៃ ហេតុអាក្រក់ក៏បានកើតឡើង, លោកនន្ទិមករកបិតាខ្ញុំហើយសួរបិតាខ្ញុំថា បានប្រគល់ទាំងពេជ្រទាំងម្ហូបទៅផងឬទេ? ខណៈនោះបិតាខ្ញុំក៏ពុងឈរទទួលលោកនន្ទិ មិនទាន់នាំលោកនន្ទិចូលមកក្នុងបន្ទប់ទទួលភ្ញៀវផងទេ ក៏នឹកធ្ងល់មួយស្របក់ ដោយលោកមិននឹកស្មានថា លោកនន្ទិនឹងមកសួរដូច្នេះឡើយ ស្ទើរតែនឹងក្រោធខឹងចំពោះលោកនន្ទិដែលសំដែងអាការមិនល្អមករកទៅហើយ តែបិតាខ្ញុំប្រញាប់ប្រញាល់នាំលោកនន្ទិចូលមកក្នុងបន្ទប់ទទួលភ្ញៀវ ហើយឈប់សម្រាកមួយស្របក់ ទើបបិតាខ្ញុំនាំយកសំបុត្រដែលលោកនន្ទិ ប្រគល់ជាឯកប្ចូនឲ្យបុត្រប្រុសមកទទួលយកម្ហូបពេជ្រទៅ ព្រមទាំងសំបុត្ររបស់លោកសរសេរទុកជាសំគាល់យ៉ាងត្រឹមត្រូវថា ម្ហូបនោះប្រដាប់ពេជ្រមានខ្នាតទីងទម្ងន់ប៉ុន្មាន? + ម្ហូបមាសមានទម្ងន់ប៉ុន្មាន? ដែលបុត្ររបស់លោកនន្ទិ បានចុះហត្ថលេខាទុកត្រឹមត្រូវហើយ ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ២៤

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជការចាស់បើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

គួនអ៊ូក៏សួរហោហ្វថា ហេតុម្តេចបានជាអ្នកមកនៅទីនេះ? ។ ហោហ្វឆ្លើយថា ពីដើមខ្ញុំក៏បានធ្វើជានាហ្មឺននៅក្នុងក្រុង លុះខ្ញុំជរាហើយក៏សូមលាចេញពីរាជការ មកធ្វើស្រែចម្ការរកទទួលទាននៅតំបន់ស្រុកនេះ, កូនខ្ញុំឈ្មោះហោប៉ាន់ជាទាហានអង់សេកចៅហ្វាយស្រុកអៀនយ៉ុង ជាផ្លូវដែលអ្នកនឹងទៅស្រុកគីជីវនេះ ខ្ញុំនឹងផ្ញើសំបុត្រ ១ ឲ្យអ្នកយកទៅឲ្យហោប៉ាន់ផង ។ គួនអ៊ូក៏ទទួលព្រម. លុះពេលព្រឹកហោហ្វរៀបលៀងគួនអ៊ូនិងបងថ្លៃគួនអ៊ូទាំង ២ ឲ្យបរិភោគហើយក៏ប្រគល់សំបុត្រឲ្យគួនអ៊ូ ។ ក៏គំនាប់លាហោហ្វចេញទៅផ្លូវទិសឯជើង ។

ឯខុងស៊ីវជានាយឃុំទាហាន ៥០០ នៅរក្សាគយ តាំងឡេងគួន បានចាត់ឲ្យទាហានដើរល្បាត ៗ បំរើសេះក៏នាំសេចក្តីទៅប្តឹងខុងស៊ីវថា ឥឡូវ

គួនអ៊ីនាំគ្រប់គ្រឿងពីមកជិតនឹងដល់គយហើយ ។ ខុនស៊ីវដឹងដូច្នោះ ក៏នាំទាហានចេញទៅទទួលគួនអ៊ី ៗ ក៏ចុះពីលើសេះគំនាប់នាយគយ ។ ខុនស៊ីវសួរថា អ្នកមកនេះនឹងទៅណា ? គួនអ៊ីប្រាប់ថា ខ្ញុំមកនេះបានលាមហាឧបរាជនឹងទៅរកគ្រឿងពីឯស្រុកគីជីវ ។ ខុនស៊ីវតបថា អូនសៀវចៅហ្វាយស្រុកគីជីវនោះ ជាសត្រូវនឹងមហាឧបរាជ; ដែលអ្នកនឹងទៅស្រុកគីជីវនោះ បើមានសំបុត្រមហាឧបរាជបើកគយឲ្យមកយើង យើងនឹងបើកឲ្យទៅបាន ។ គួនអ៊ីឆ្លើយថា កាលខ្ញុំមកនោះជាការប្រញាប់គ្មានសំបុត្រគយមកទេ ។ ខុនស៊ីវថា បើគ្មានសំបុត្របើកគយទេ សូមលោកបង្អង់នៅទីនេះសិន ចាំខ្ញុំនឹងឲ្យចំរើចូលទៅប្តឹងមហាឧបរាជ បើមានសំបុត្រប្រាប់មកឲ្យបើក សឹមខ្ញុំបើកឲ្យទៅ ។ គួនអ៊ីថា ខ្ញុំមានការប្រញាប់ បើអ្នកឲ្យខ្ញុំឈប់បង្អង់ នោះនឹងមិនយូរការទៅឬ? ខុនស៊ីវថា ច្បាប់សម្រាប់គយដូច្នេះ ខ្ញុំនឹងបើកឲ្យទៅមិនបានទេ ។ គួនអ៊ីថា ដែលអ្នកនិយាយដូច្នេះនឹងឃាត់ខ្ញុំជាប្រាកដឬ? ។ ខុនស៊ីវថា បើអ្នកមានការទៅប្រញាប់ ត្រូវទុកគ្រប់គ្រឿងឲ្យនៅជាបញ្ចាំ ខ្លួនអ្នកនឹងទៅក៏ទៅចុះ ។

គួនអ៊ីខឹងណាស់ ក្រោកជារលើកឡើងទឹងកាប់ខុនស៊ីវ ហើយថា បើមិនឲ្យយើងទៅ យើងនឹងទំលាយទៅឥឡូវនេះ ។ ខុនស៊ីវគេចទាន់ ក៏នាំទាហានរត់ចូលទៅក្នុងគយហើយលើកគ្នាចេញមក សុទ្ធតែពាក់ក្រើសកាន់គ្រឿងអាវុធគ្រប់ដៃ ខុនស៊ីវស្រែកឲ្យគួនអ៊ីថា ខ្លួនខ្លាំងពូកែនឹងអាចហានកាត់ទំលាយគយចេញទៅបាន ក៏ចូរទៅលមើលចុះ ។ គួនអ៊ី ក៏រឹតតែខឹងឲ្យទាហានបររថបង្ហៃថយចៀសទៅម្ខាង ហើយ

គួនអ៊ូក៏បរសេះកាន់ដាវចូលតយុទ្ធនឹងខុនស៊ុវបាន ១ ស្របក់ គួនអ៊ូយកដាវកាប់ខុនស៊ុវធ្លាក់ពីលើសេះស្លាប់ ទាហានទាំងពួងឃើញខុនស៊ុវស្លាប់ដូច្នោះ ក៏ភ័យតក់ស្លុតរត់ខ្ចាត់ខ្ចាយចេញទៅ ។

គួនអ៊ូស្រែកប្រកាសប្រាប់ទាហានទាំងពួងថា អ្នកទាំងអស់គ្នាកុំភ័យគិតបារម្ភខ្លាចអ្វីឡើយ យើងមិនធ្វើអន្តរាយដល់អ្នកទាំងឡាយទេ ដែលយើងសម្លាប់ខុនស៊ុវនោះ ព្រោះខុនស៊ុវឃាត់ខាំងយើង ហើយប្រមាថមើលងាយយើងផង អ្នកទាំងឡាយចូរនាំយកសេចក្តីទាំងនេះទៅប្តឹងមហាឧបរាជ ដោយពិតត្រង់ផងចុះ ។ ទាហានទាំងនោះបានឮ ហើយក៏នាំគ្នាចូលមកគំនាប់គួនអ៊ូ ។

ឯបំរើសេះបានឃើញហេតុដូច្នោះ ក៏ស្ទូតរូតនាំរឿងនោះទៅប្តឹងហាន់ហ៊ុកចៅហ្វាយស្រុកឡុកអៀង ។ ហាន់ហ៊ុកបានដឹងសេចក្តីក៏ប្រឹក្សានឹងទាហានទាំងពួងថា គួនអ៊ូគ្មានសំបុត្របើកគយពីមហាឧបរាជឲ្យមកសោះ លុះខុនស៊ុវឃាត់ឃាំង គួនអ៊ូក៏សម្លាប់ចេញហើយ បើដូច្នេះ អ្នកទាំងអស់គ្នានឹងគិតប្រការម្តេច? បេងថាន់ឆ្លើយថា ដែលគួនអ៊ូមកនេះមិនមានសំបុត្របើកផ្លូវគយ ខ្ញុំយល់ឃើញថា ប្រាកដជារត់មកពីមហាឧបរាជ បើយើងនឹងបើកលែងឲ្យទៅ ទោសក៏នឹងមានដល់យើង ។

ហាន់ហ៊ុកឆ្លើយថា គួនអ៊ូនេះមានថ្វីដៃខ្លាំងពូកែណាស់ ងាន់លៀងប៊ុនធីវដែលជាសេនាឯកអ៊ួនសៀវល្បីល្បាញជាអ្នកខ្លាំងពូកែ គួនអ៊ូក៏សម្លាប់ចេញបាន បើយើងនឹងតប្រាំងចាប់យកខ្លួនគួនត្រានេះ មុខជាទល់កំឡាំងគួនអ៊ូមិនបានទេ បើដូច្នេះត្រូវតែគិតកលឧបាយ ទើបចាប់

ខ្លួនគួនម៊ូបាន ។ ចេងថាន់ឆ្លើយថា លោកគិតនេះត្រូវណាស់ ខ្ញុំនឹងសុំ យកអាសាលើកទាហានចេញទៅច្បាំងនឹងគួនអ៊ូ ហើយធ្វើជាថយរត់ ឲ្យលោកនាំយកទាហានទៅបង្កប់ បើកាលណាឃើញគួនអ៊ូដេញខ្ញុំមក ឲ្យលោកយិតធ្នូបាញ់ឲ្យត្រូវ បើគួនអ៊ូធ្លាក់ពីលើសេះឲ្យលោកស្ទុះទៅចាប់យកខ្លួនបញ្ជូនទៅស្រុកក្រុង សេចក្ដីគាប់ប្រសើរក៏គង់នឹងមានដល់លោក ។ ហាន់ហុកឃើញត្រូវផងក៏កេណ្ឌទាហានត្រៀមបំរុងទុក ។ ទទួលបំរើសេះមកប្រាប់ហាន់ហុកថា ឥឡូវគួនអ៊ូលើកមកដល់ជិតស្រុកឡុកអៀងហើយ ។ ហាន់ហុកក៏ពាក់គ្រឹសកាន់ធ្នូឡើងសេះនាំទាហាន ១ ពាន់លើកចេញទៅដល់ទ្វារស្រុក ទទួលក្រឡេកឃើញគួនអ៊ូ ហាន់ហុកក៏លើកទាហាន ៥០០ អែបបង្កប់ប្របទ្វារ ។ ចេងថាន់ក៏បរសេះនាំទាហាន ៥០០ ចេញទៅធ្វើជាមិនដឹង ហើយសួរគួនអ៊ូថា អ្នកឯងឈ្មោះអ្វី? មកពីណាទៅណា? គួនអ៊ូឆ្លើយថា យើងឈ្មោះគួនអ៊ូជានាហ្មឺនទីហាន់ស៊ីវគេងហោ ដែលមកនេះនឹងសុំផ្លូវស្រុកឡុកអៀង ទៅផ្លូវទិសឯជើង ។ ចេងថាន់ឆ្លើយថា អ្នកជានាហ្មឺនចេញមកពីស្រុកក្រុង បើមានធុរៈនឹងចេញទៅស្រុកឯជើងនោះ គួរតែឲ្យមានសំបុត្រពិនិត្យបើកឲ្យពីមហាឧបរាជទើបទៅបាន ។ គួនអ៊ូថា យើងមកនេះជាការរហ័សប្រញាប់ប្រញាល់ពេកណាស់ មិនបានសុំសំបុត្រចុតហ្មាយអ្វីទេ ។ ចេងថាន់ថា ទីស្រុកឡុកអៀងជាដើមផ្លូវនឹងទៅស្រុកខាងទិសឯជើង មហា-ឧបរាជប្រើហាន់ហុកមកឈរក្សាស្រុកនេះ បើខ្លួនអ្នកជានាហ្មឺនមានការនឹងចេញទៅ ត្រូវតែមានសំបុត្របើកគយ បើគ្មានហើយយើងយល់

ឃើញថា អ្នកមកនេះដោយវេះរត់ជាប្រាកដ ៗ គួនអ៊ូឮដូច្នោះក៏ខឹងណាស់ ថា ខ្ញុំស៊ីនាយគយតាំងឡើងគួនឃាត់ទាំងយើងដូច្នេះ យើងក៏សម្លាប់ចេញហើយ ហេតុម្តេចក៏ខ្លួនបង់មកឃាត់ទាំងយើង? ខ្លួនមិនស្រឡាញ់ជីវិតទេឬ? ចេងថាន់ឮដូច្នោះក៏ខឹងណាស់ បរសេះកាំដាវចូលតយុទ្ធនឹងគួនអ៊ូ ៗ ក៏ឲ្យទាហានញាក់ៗរថចៀសចេញទៅ ហើយក៏បរសេះចូលប្រយុទ្ធគ្នានឹងចេងថាន់បាន ៣ ក្បួន ចេងថាន់ធ្វើជាថយរត់ទៅក្រោយ គួនអ៊ូក៏ដេញបណ្តោយ ដោយកំឡាំងជើងសេះសិកថៅលឿនរហ័សជិតដល់ទ្វារស្រុក គួនអ៊ូយកដាវកាប់ចេងថាន់ត្រូវដាច់ពាក់កណ្តាលខ្លួន ហើយញាក់សេះវេះត្រឡប់មកវិញ ៗ ហាន់ហុកដែលជាពួកបង្កប់ប្របមាត់ទ្វារ ក៏លើកធ្នូឡើងបាញ់តម្រង់ដោយកំឡាំងដៃពេញត្រូវជាប់នឹងស្មាគួនអ៊ូខាងឆ្វេង គួនអ៊ូក៏យំណាស់យកដៃកន្ត្រាក់ដកព្រួញចោលទៅ ឈាមក៏ហូរដោកពេញទាំងខ្លួន ឈឺពេកពិតជាខ្លាំងណាស់ ក្រឡេកមើលទៅឃើញហាន់ហុកនៅលើខ្នងសេះអែបប្របមាត់ទ្វារ គួនអ៊ូក៏មិនបានកោតញញើតឬគិតឈឺក្នុងខ្លួន ក៏បំផាយសេះស្ទុះទៅដល់ទឹមនឹងហាន់ហុក យកដាវកាប់ដាច់ខ្លួនហាន់ហុកធ្លាក់ពីលើសេះស្លាប់ ហើយក៏ដេញកាប់ទាហានហាន់ហុកស្លាប់ពិការជាច្រើន រូបគួនអ៊ូក៏បំផាយសេះត្រឡប់ទៅតាមបងថ្លៃ ហើយមិនហ៊ានបង្អង់ឈប់ក្នុងស្រុកឡុកអៀងព្រោះមិនទុកចិត្ត ទើបយកព្រែមករុំព័ទ្ធមុខរបួសហើយក៏នាំបងថ្លៃទាំង ២ បររថស្រូតចេញទៅតាមផ្លូវតយតីស៊ុយគួន ៗ

ពំរើសេះក៏នាំយកពតិមានដែលគួនអ៊ូសម្លាប់ចៅហ្វាយស្រុក ទាំង

នាយគយគ្រប់អន្លើ ទៅស្ដីបឹងពៀនហ៊ីនាយគយគឺស៊ុយគួនថា ឥឡូវគួនអ៊ូមកជិតដល់ទីនេះហើយ ៗ ពៀនហ៊ីនោះចំណានស្ទាត់ខាងពោលកូនយុប លុះដឹងសេចក្ដីហើយក៏ត្រិះរិះគិតថា ធ្វើម្ដេចយើងនឹងចាប់ខ្លួនគួនអ៊ូបាន" លុះគិតទៅគិតមកក៏នឹកឃើញថា វត្តចិនកុកជីដែលនៅមុខគយនោះជាទីចំណាច់ស្រួលណាស់ យើងនឹងរៀបចំឲ្យទាហានទៅពួនបង្កប់ទុកប្រហែល ១០០ ប្លាយ ហើយបបួលគួនអ៊ូចូលទៅបរិភោគអាហាររួចនឹងពោលតែងស្រាជាសំគាល់ឲ្យទាហានទាំងពួងស្ទុះចូលព្រមគ្នា ចាប់ខ្លួនគួនអ៊ូមុខជានឹងបានដោយស្រួល ៗ លុះពេលព្រឹកពៀនហ៊ីក៏នាំទាហានទៅពួនបង្កប់ទុកក្នុងវត្ត ហើយបង្គាប់ទុកតាមគំនិតដែលគិតនោះរួចពៀនហ៊ីក៏ចេញទៅទទួលគួនអ៊ូ ៗ ឃើញពៀនហ៊ីនាយគយនឹងទាហានទាំងពួង គ្មានអាវុធកាន់នៅដៃចេញទៅទទួលដោយល្អក៏អស់សេចក្ដីសង្ស័យ ទើបចុះពីខ្នងសេះគំនាប់ពៀនហ៊ី ៗ ក៏ជំរាបថា ខ្ញុំបាទជានាយគយនៅទីនេះ បណ្ដាមនុស្សទាំងពួងក៏ឮរន្ទឺល្បីឈ្មោះថាលោកខ្លាំងពូកែណាស់ មានទាំងសេចក្ដីសត្យកតញ្ញូល្អជាទីបំផុត ឥឡូវខ្ញុំបាទឮថា លោកនឹងទៅរកឡៅពីជាបង ខ្ញុំបាទក៏មានអំណរផង ទើបនាំបណ្ដាព្រស្ដូកគយមកចាំទទួលលោក ៗ

គួនអ៊ូបានស្ដាប់ ក៏នាំយករឿងរ៉ាវដែលខុងស៊ុរ, បេងថាន, ហានហុក, ឃាត់ខាំងខ្លួននោះឲ្យពៀនហ៊ីស្ដាប់គ្រប់ប្រការ ៗ ពៀនហ៊ីក៏ក្លែងនិយាយថា ដែលលោកសម្លាប់អ្នកទាំង ៣ នាក់នោះចេញ ក៏គួរដល់ទោសហើយ បើខ្ញុំបាទបានចូលទៅដល់មហាឧបរាជ ខ្ញុំបាទ

នឹងសុំជួយបាយបៀងស្មើ តាមដំណើរជូនតាមសុភាព វេលានេះសូមឲ្យលោកឡើងសេះទៅកាន់ទីឋានរបស់ខ្ញុំចុះ ។ គួនអ៊ូក៏មានសេចក្តីត្រេកអរណាស់ លុះឡើងសេះនាំទាហានបររថតាមពៀនហ៊ុទៅដល់មុខវត្ត ។ ពៀនហ៊ុក៏អញ្ជើញគួនអ៊ូឲ្យចូលទៅក្នុងវត្តទិនកុកជី, ឯវត្តនោះជាដំណែលរបស់ព្រះចៅចេងគេសទ្រង់កសាងទុកពីបុរាណ ធ្លាប់ស្តេចមកនមស្សការព្រះជារឿយ ៗ លោកសង្ឃទាំងពួងឃើញគួនអ៊ូចូលទៅ ក៏វាយគោះគងស្គរទទួលគំនាប់ ឯលោកចិនកៅចេងជាមេវត្តកំណើតនៅស្រុកជាមួយនឹងគួនអ៊ូធ្លាប់ស្គាល់គ្នាមកពីដើម លុះឮដំណឹងថា ពៀនហ៊ុគិតនឹងធ្វើអន្តរាយគួនអ៊ូដូច្នោះ លោកចិនកៅចេងក៏ចេញទៅទទួល ប្រាថ្នានឹងខ្សឹបប្រាប់សេចក្តីឲ្យគួនអ៊ូដឹងខ្លួន ហើយលោកនោះក៏សាកសួរគួនអ៊ូថា អ្នកស្គាល់អាត្មាឬទេ? គួនអ៊ូថា ខ្ញុំចាំមិនបានទេ ។ លោកចិនកៅចេងថា អ្នកចេញមកពីស្រុកកំណើតប៉ុន្មានឆ្នាំហើយ? គួនអ៊ូថា ខ្ញុំចេញពីស្រុកមកបាន ២០ ឆ្នាំហើយ ។ លោកចិនកៅចេងថា ភូមិអ្នកនឹងភូមិអាត្មាភាពនៅត្រង់មាត់ទន្លេត្រើយម្ខាងម្នាក់ ។

ពៀនហ៊ុឃើញលោកគ្រូចិនកៅចេងនិយាយសាកសួរគួនអ៊ូថាជាពួកម៉ាកស្រុកទេសជាមួយគ្នាដូច្នោះ ពៀនហ៊ុខ្លាចបែកការដែលគិតទុកនោះនឹងខ្ចរខ្ចាយឡើង ក៏ស្រែកគំហកឲ្យលោកគ្រូចិនកៅចេងថា យើងអញ្ជើញគួនអ៊ូនឹងបរិភោគអាហារក្នុងវត្តនេះ ហេតុម្តេចលោកមកនាំនិយាយឲ្យយូរការ ។

(មានត)

# រឿងបល្ល័ង្កទិព្យ សាមសិបពីររឿង

រឿងព្រេងតំណាល

## លោកសមិត មូត្យជមៈ តែង

## លោក រ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

## និទាននៃរូបទេពនិម្មិតទី ២២

*រូបទេពនិម្មិតទី ២២ បានក្រាបបង្គំទូលព្រះបាទភោជៈថា បពិត្រព្រះបាទភោជៈ សូមទ្រង់លះបង់នៃការធ្វើមុទ្ទាភិសេកទៅលើបល្ល័ង្កទិព្យនេះ ព្រោះទ្រង់មិនអាចតាំងព្រះអង្គជាបុព្វការីបុគ្គល ដូចព្រះបាទវិក្រមាទិត្យបានឡើយ ។ សូមទ្រង់ព្រះសណ្ដាប់ តើដោយហេតុអ្វីបានជាព្រះបាទវិក្រមាទិត្យ ទ្រង់ព្រះនាមថាបុព្វការីបុគ្គល ដូចតទៅនេះ៖*

*ព្រះបាទវិក្រមាទិត្យ កាលទ្រង់ព្រះជន្មាយុ ១៦ ឆ្នាំ ទ្រង់មានមហិទ្ធិរិទ្ធិផ្ចាញ់មហាក្សត្រិយ៍ជាច្រើននៅភូមិភាគសំខាន់ៗ ឲ្យនៅក្រោមបង្គាប់បញ្ជាព្រះអង្គ, ទ្រង់ជាពន្លឺនៃមហាក្សត្រិយ៍ទាំងអស់ ទ្រង់បានត្រងព្រះមកុដពេជ្យមានដាំត្បូងភ្លឺព្រាលរន្ទាល, ទ្រង់មានស្នាមគំនូសជាផ្កាឈូកត្រង់ព្រះបាទាជាព្រះរូបលក្ខណៈ, ទ្រង់សោយរាជសម្បត្តិ ជាស្ដេចចក្រពត្រាធិរាជ ។*

*ពេលម៉ោងព្រះព្រហ្ម (គឺម៉ោងជាបឋម), ទ្រង់តើនពីក្រឡាព្រះបន្ទំដោយមានភ្លេងស័ព្ទសូរពីរោះអស្ចារ្យ និងសំឡេងផ្អែមល្ហែមសរសើរព្រះអង្គជាអនេកប្បការ ។ ក្រោយដែលទ្រង់សំបូងសម្រួង*

ដល់គុណព្រះនាកយណ៍, ទ្រង់ព្រះតម្រិះដល់សមាធិចិត្ត ហៅថា ចរណារវិន្ទ (Caranaravinda) រួចទ្រង់ប្រព្រឹត្តប្រតិបត្តិតាមព្រះរាជករណីយកិច្ចគ្រប់យ៉ាង ហើយថ្វាយបង្គំអាទិទេព, ទ្រង់ស្តេចយាងទៅកាន់ រោងស្នាន ដើម្បីទឹងហាត់អាវុធគ្រប់បែប ៗ តមកទ្រង់ព្រះរាជកុងកណ្ឌ, ស្តេចយាងធ្វើព្រះរាជអំណោយទួរព្រាក់ទាំងពាន់សុវណ៌ (Suvarnas) លំដាប់តមកទៀត ទ្រង់ស្តេចយាងចូលទៅកាន់ទីជំនុំគណៈរដ្ឋមន្ត្រី មាន រដ្ឋមន្ត្រីជាព្រះរាជទីប្រឹក្សា រដ្ឋមន្ត្រីអ្នកប្រតិបត្តិតាមព្រះរាជឧង្ការ នឹងពួកបណ្ឌិតជាច្រើន ៗ នៅទីនោះទ្រង់សម្រេចរឿងក្ដីក្នុងព្រះរាជអាណាចក្រ ទៅតាមច្បាប់ក្រមព្រហ្មទណ្ឌ (ច្បាប់ទណ្ឌនីតិ) នឹងច្បាប់នយោបាយ (រាជនីតិ) ៗ ដល់ពេលថ្ងៃត្រង់, ក្រោយដែលបានប្រព្រឹត្តប្រតិបត្តិព្រះរាជករណីយកិច្ចតាមច្បាប់វេទរួច, ទ្រង់ព្រះរាជទានឲ្យព្រះរាជអំណោយដល់ពួកជនអាពាធ, ពួកជនទុគ៌ត ៗ ល ៗ គ្រប់យ៉ាង ហើយត្រាស់បង្គាប់ឲ្យស្លៀងគោជនាហារបួនបែប គឺ អាហារដែលទំពា, អាហារដែលជញ្ជក់, អាហារដែលលិទ្ធ, អាហារដែលក្រេបព្រឹក មានឧជារស ៦ យ៉ាង គឺ ស្រួល ល្វីង ប្រៃ ខ្ចាំង ហើរ ជូរចំពោះព្រះរាជវង្សានុវង្ស នឹងរាជមិត្តរបស់ព្រះអង្គ ៗ លំដាប់តមក, ក្រោយដែលទ្រង់សោយព្រះស្រិសទ្ធិក (ម្ហូប) លាយដោយគ្រឿងក្រអូបផ្សេងៗ, មានខ្លាហារ ក្ញាំពូ ៗ ល ៗ រួចទ្រង់ទាត់ព្រះបាទនឹងគ្រឿងក្រអូបមានក្រពេះចូងច័ន្ទន៍ជាដើម ទ្រង់ក្លងមាល័យជាច្រើន, ទ្រង់លាព្រះរាជវង្សានុវង្សនឹងរាជមិត្តរបស់ព្រះអង្គហើយ ផ្ទុំមួយស្របក់នៅលើ

ព្រះមញ្ចុះ (ក្រែ) ៗ ក្រោយមក, ទ្រង់ព្រះសវនានូវពួកបក្សបក្សី
ដែលចេះពោលពាក្យ គឺសេក, សារិកា, ទ្រង់ក្រសាលសប្បាយ
ព្រះរាជហឫទ័យនឹងស្រីស្នំក្រមការ ដែលមានរូបនោមល្អស្រស់ឆើតផង
គេ ៗ ដល់ពេលរសៀល ទ្រង់ព្រះសណ្តាប់នូវភ្លេងការ, ភ្លេងបុរាណ
ៗ ល ៗ ទ្រង់យាងទៅធ្វើព្រះរាជទស្សនាការនៅកងទ័ព ព្រះរាជទ្រព្យ.
ព្រះសំហារិម: ដោយមានលោកអធិការដែលត្រួតត្រាមុខងារនីមួយ ៗ
អមព្រះអង្គផង ៗ ដល់ពេលល្ងាច ទ្រង់បានប្រតិបត្តិតាមពិធីវេទ ៗ
ក្រោយដែលទ្រង់ធ្វើរាជសន្និបាតនឹងពួកបណ្ឌិត, ប្រព្រឹត្តព្រះរាជ-
ករណីយកិច្ចតាមបទបញ្ញត្តិនៃសាស្ត្រ, ទ្រង់ស្តេចយាងទៅជួបនឹងពួក
បុគ្គលដែលចូលចិត្តខាងល្បែងរបាំ ហើយទ្រង់កំសាន្តទតពួកកាំ, ទ្រង់ព្រះ
សណ្តាប់នូវចម្រៀងនឹងភ្លេងតូរ្យតន្ត្រី, ទ្រង់រួមមេថុនសំវាសនឹងស្រីតាម
គួរការ, រួចទ្រង់ផ្ទុំរហូតដល់បច្ចូសសម័យសុខកាយសប្បាយព្រះរាជ-
ហឫទ័យ ៗ នេះជាព្រះរាជករណីយកិច្ចដែលទ្រង់បានព្រះរាជកំណត់ធ្វើ
រាល់ថ្ងៃ ៗ

មានមួយថ្ងៃ, នៅពេលជិតព្រលប់ ព្រះរាជាទ្រង់រៀបនឹងយាង
ចូលទៅកាន់ក្រឡាព្រះបន្ទំ, ទ្រង់មានព្រះរាជពិភាល់ (ចៃដន្យ)
ក្នុងព្រះរាជហឫទ័យដែលជាសន្ទុស្សន៍នៃសេចក្តីលំបាកក្នុងប្រទេស ៗ
ដល់ពេលអរុណរះ ទ្រង់ក៏មានព្រះបន្ទូលទៅកាន់ពួកបណ្ឌិតអំពីហេតុ
ខាងលើ ៗ ពួកបណ្ឌិតបានក្រាបបង្គំទូលមហារាជថា "បពិត្រព្រះ
សម្មតិទេព, ទូលព្រះបង្គំទាំងឡាយយល់ថាព្រះរាជពិភាល់ ក្នុងព្រះ

រាជហ្ឫទ័យនោះ ជាហេតុឲ្យកើតសេចក្ដីលំបាកក្នុងព្រះរាជអាណាចក្រ របស់ព្រះអង្គដោយពិត" ។ ព្រះមហារាជ លុះទ្រង់ព្រះសណ្ដាប់នូវពាក្យពួកបណ្ឌិតទាំងនោះហើយទ្រង់ព្រះតម្រិះថា "គ្មានបុគ្គលណាជៀសវាងនូវមច្ចុរាជបានឡើយ ។ ភរិយា, បុត្រ, ធីតា, ទ្រព្យសម្បត្តិ និងវត្ថុទាំងឡាយ ដែលសង្ខារតាក់តែងឡើង តែងប្រកបដោយ អនិច្ចំ, ទុក្ខំ, អនត្តា មិនបានឋិតថេរយូរកាលទៅ ប្រៀបដូចពពុះទឹក; ដល់ពេលធ្វើមរណកាល គ្មានវត្ថុណាអាចទៅតាមបុគ្គលបានសោះឡើយ មានតែបទបញ្ញត្តិច្បាប់ដែលគេយកទៅប្រើនៅបរលោក ។ ព្រោះហេតុនេះ ក្រោយដែលទ្រង់បានពិចារណាយល់ឃើញថា: សង្ខារទាំងឡាយមានតម្លៃតិចតួចស្តួចស្តើងណាស់ ទើបសម្រេចក្នុងព្រះរាជហ្ឫទ័យថា: បុគ្គលសប្បុរសត្រូវតែសន្សំនូវកុសល ហើយលះបង់ទ្រព្យសម្បត្តិទៅឲ្យអ្នកក្រីក្រលំបាក" ។

ព្រះបាទវិក្រមាទិត្យ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ទ្រង់ត្រាស់បង្គាប់ឲ្យបើកទ្វារព្រះបន្ទាយនៃប្រាសាទទាំងអស់ក្នុងព្រះបរមរាជវាំង ហើយទ្រង់ដាក់ឲ្យប្រកាសផ្សាយថា "បើអ្នកណាមានបំណងចង់បានភោគទ្រព្យអ្វី ឲ្យចូលមកទីនេះ យកតាមចិត្តប្រាថ្នាចុះ" ។ ក្នុងពេលនោះ ក្រោយដែលទ្រង់បានព្រះរាជប្រកាសរួចហើយ, ពួកប្រជារាស្ត្រអ្នកក្រីក្រលំបាក ក៏នាំគ្នាចូលទៅក្នុងព្រះបរមរាជវាំង ទទួលយកនូវភោគទ្រព្យតាមបំណងរៀងខ្លួន ។

រូបទេពនិម្មិតទី ២២ ទូលបន្ថែមទៀតថា "បពិត្រមហារាជភោជ: !

នេះហើយជាមហាសប្បុរសនៃព្រះបាទវិក្រមាទិត្យ ព្រោះហេតុនេះបានជាព្រះអង្គទ្រង់គង់នៅលើបល្ល័ង្កទិព្យនេះបាន ។ សម័យបច្ចុប្បន្ននេះគ្មានមហារាជអង្គណាមានព្រះរាជសទ្ធា ដូចព្រះបាទវិក្រមាទិត្យសោះឡើយ ។

គ្រាពេលនេះ, ព្រះបាទភោជៈក៏មិនបានធ្វើមុទ្ធាភិសេក ទ្រង់យាងថយចេញពីបល្ល័ង្កទិព្យនោះទៅ ។

*

* *

## និទាននៃរូបទេពនិម្មិតទី ២៣

មានកាលមួយថ្ងៃ ព្រះបាទភោជៈទ្រង់បានស្តេចចូលទៅជិតបល្ល័ង្កទិព្យនោះ ដើម្បីនឹងធ្វើមុទ្ធាភិសេក ។ រូបទេពនិម្មិត បានឃើញព្រះបាទភោជៈបញ្ចេញព្រះរាជកាយវិការដូច្នោះ ក៏បានទូលថា "បពិត្រព្រះបាទភោជៈ អ្នកណាមួយមានចិត្តអង់អាច, អំណត់, មហាសប្បុរស ដូចព្រះបាទវិក្រមាទិត្យ អ្នកនោះអាចអង្គុយលើបល្ល័ង្កទិព្យនេះបាន ។ ព្រះបាទភោជៈទ្រង់ត្រាស់សួររូបទេពនិម្មិតនោះថា សភាពក្លាហានអង់អាច នឹងព្រះរាជគុណសម្បត្តិនៃព្រះបាទវិក្រមាទិត្យនោះប៉ុនណា ?

រូបទេពនិម្មិតទូលតបថា:

ព្រះមហារាជវិក្រមាទិត្យ ទ្រង់សោយរាជសម្បត្តិក្នុងនគរអវន្តី ។ នៅក្នុងនគរនោះមានពាណិជម្នាក់ឈ្មោះ ធនបតិ មានប្រាក់ ៣០ កោដិ មានបុត្រ ៤ នាក់ ។ (មានត)

# កំណាត់ជីវប្រវត្តិការណ៍

## ពិធីសម្ពោធសាលាបាលីជាន់ខ្ពស់

## នៅខេត្តសៀមរាប

## របស់ពុទ្ធសាសនបណ្ឌិត្យ

---

នៅថ្ងៃទី ៣០ មីនា ១៩៥៦ ក្នុងវត្តដំណាក់ខេត្តសៀមរាប មានធ្វើពិធីសម្ពោធគ្រឹះស្ថានមួយខ្នងយ៉ាងឧឡារិក ក្រោមអធិបតីភាព នៃលោកទ្រឹញ - ហ៉ញ រដ្ឋលេខាធិការក្រសួងធម្មការ ។

គ្រឹះស្ថានមួយខ្នងនេះ សង់ពីឥដ្ឋនិងថ្ម ប្រកបដោយជាន់ ២ ខ័ណ្ឌ ជាបន្ទប់រៀន ៤ ថ្នាក់, គ្រឹះស្ថាននេះកើតដោយស្នាព្រះហស្តនៃព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យមេគណខេត្តសៀមរាប និងពួកពុទ្ធបរិស័ទជើងវត្តដែលមានសទ្ធាក្នុងព្រះពុទ្ធសាសនា ។

ក្នុងឱកាសពិធីសម្ពោធនេះ គេបានសង្កេតឃើញពុទ្ធបរិស័ទជាច្រើនដែលអញ្ជើញទៅរួបរួម មានឯកឧត្តមឈួន - ម្ជុលពេជ្រ ព្រះរាជប្រតិភូប្រចាំខេត្តសៀមរាប, លោកតាន់ - គិមតិក ចាងហ្វាងសាលាដំបូងខេត្តសៀមរាបនិងលោកដទៃទៀត ដែលយើងសូមអភ័យទោសដោយមិនបានកត់នាមទាំងអស់ក្នុងទីនេះ ។

ក្នុងទីសន្និបាតនោះ ព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យ បានថ្លែងសុន្ទរកថា រៀបរាប់អំពីប្រវត្តិនៃវត្តដំណាក់យ៉ាងក្បោះក្បាយ

នាំឲ្យពុទ្ធបរិស័ទដែលនៅស្តាប់ទាំងប៉ុន្មានរំភើបក្នុងចិត្តយ៉ាងក្រៃលែង ។

បន្ទាប់មក លោកទ្រិញ-ញ៉ាញ រដ្ឋលេធិការក្រសួងធម្មការ **បាន** ឡើងលើវេទិការថ្លែងសុន្ទរកថា តបនឹងព្រះតេជព្រះគុណព្រះសុមង្គល-សីលាចារ្យមេគណវិញ ។

មុននឹងសំដែងសុន្ទរកថា លោករដ្ឋលេខាធិការក្រសួងធម្មការបាន មានប្រសាសន៍ ទូលព្រះសង្ឃនិងជំរាបពុទ្ធបរិស័ទអំពីសេចក្តីសោមនស្ស រីករាយយ៉ាងក្រៃលែង នៃសម្តេចព្រះឧបយុវរាជ ព្រមទាំងព្រះរាជរដ្ឋា-ភិបាល ចំពោះការស្ថាបនានូវសាលានេះ ។

លុះចប់ប្រសាសន៍ដ៏ខ្លីនេះហើយ ទើបថ្លែងសុន្ទរកថាក្នុងនាមនៃ ព្រះរាជរដ្ឋាភិបាលទទួលយកសាលានេះ ជាសម្បត្តិរបស់រដ្ឋតទៅ ។

រីសុន្ទរកថានៃព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យ និងលោក រដ្ឋលេខាធិការក្រសួងធម្មការ យើងនឹងស្រង់យកមកចុះ ដូចតទៅនេះ៖

## សុន្ទរកថា

## នៃព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យមេគណ

សូមក្រាបថ្វាយបង្គំ សម្តេច !

សូមថ្វាយបង្គំ ព្រះមហាថេរានុត្ថេរៈ !

លោករដ្ឋមន្ត្រីក្រសួងធម្មការ !

ឯកឧត្តមព្រះរាជប្រតិភូ !

លោកអ្នកសប្បុរសទាំងឡាយ !

ខ្ញុំព្រះករុណា អាត្មាភាព មានសេចក្ដីត្រេកអរនឹងថ្វាថ្លែងពុំបាន ចំពោះសម្ដេច, ព្រះតេជព្រះគុណ ដែលបានឆ្លៀតឱកាសដ៏ប្រសើរនិមន្ត មកជាអធិបតីសិរីសួស្ដីក្នុងពិធីបុណ្យសម្ពោធសាលានេះ ។

សូមសម្ដេច, ព្រះតេជព្រះគុណ, ឯកឧត្ដម, លោកសប្បុរសទាំងឡាយមេត្តាប្រោសប្រទានឱកាស ខ្ញុំព្រះករុណា អាត្មាភាពនឹងប្រគេនសេចក្ដី ជូនសេចក្ដីអំពីការកសាងសាលានេះ ដូចតទៅ៖

អស់កាលយូរឆ្នាំមកហើយ តាំងតែអំពីកាលដែលព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ព្រះមេត្តាប្រោសតែងតាំងខ្ញុំព្រះករុណា អាត្មាភាព ឲ្យទទួលនាទីជាមេគណខេត្តសៀមរាបមក ខ្ញុំព្រះករុណា អាត្មាភាព តែងតែមានចិត្តបារម្ភជានិច្ចក្នុងកិច្ចការរបស់ខ្លួន ព្រោះខេត្តនេះខ្សត់ខ្សោយទ្រព្យសម្បត្តិចំណេះវិជ្ជាជាងខេត្តដ៏ទៃៗ ក្នុងព្រះរាជអាណាចក្រ ហើយខំពាររកមធ្យោបាយតំកិតំកើងព្រះពុទ្ធសាសនា ដើម្បីតបស្នងគុណព្រះតេជព្រះគុណ ព្រះបរមពោធិសម្ភារបារមី ដែលទ្រង់តែងតែទុកព្រះរាជហឫទ័យចំពោះមកលើរូបខ្ញុំព្រះករុណា អាត្មាភាពថានឹងអាចជួយសម្រាលព្រះរាជកិច្ចដ៏ធ្ងន់នោះបានខ្លះ ។

ដោយអានុភាពនៃព្រះរាជក្រម និងព្រះរាជក្រឹត្យដែលបង្កើតឲ្យមានសាលាបាលីរងនិងសាលាធម្មវិន័យឡើង ភិក្ខុសាមណេរក្នុងខេត្តនេះច្រើនរូបបានទទួលការចេះដឹង ខ្លះបានចូលទៅបន្ដវិជ្ជានាក្រុងភ្នំពេញ ខ្លះនៅសល់ខាន លទ្ធផលនេះគួរសង្ឃឹមទុកចិត្តថា ពុទ្ធសាសនាក្នុងខេត្តនេះមុខជានឹងចំរើនទៅអនាគតពុំខាន ។ តែការសិក្សាមិនមានខប

ខែត្រកាលបើប្រទេសជាតិកាន់តែចំរើនឡើងហើយ ការសិក្សាជាន់ខ្ពស់នៃសិក្ខាកាមកុលបុត្រ ក៏រឹងរឹតតែមានសេចក្ដីត្រូវការជាចាំបាច់កាន់តែច្រើនឡើងណាស់ដែរ ភិក្ខុសាមណេរដែលបានទទួលការសិក្សាឃើញថាសមគួរមកហើយអំពីអតីតសម័យ បែរទៅជាឃើញថានៅទន់ខ្ចីសេចក្ដីទៅវិញ ភិក្ខុសាមណេរខ្លះ ដែលមានវិជ្ជាល្មមនឹងទៅបន្តវិជ្ជាជាន់ខ្ពស់នាក្រុងភ្នំពេញបានក៏មានច្រើនរូប តែញាតិញោមក្រីក្រ មិនមានមធ្យោបាយទំនុកកៃខៃបន្តវិជ្ជាកូនចៅឲ្យរៀនបាន ក៏នៅតែក្រិនក្ដិបក្ដៀបការបេះដូងដូចផ្កាណាទុំផលក្នុងរដូវប្រាំង មិនមានវិជ្ជាជាពន្លឺក្នុងខ្លួនធួនល្មមក្នុងការប្រតិបត្តិព្រះពុទ្ធសាសនាយកផលប្រយោជន៍ខ្លួន ឬប្រយោជន៍ជួយទូន្មានប្រៀនប្រដៅប្រជាជន ឲ្យមានចក្ខុមើលឃើញផ្លូវដើរទៅតាមគន្លងធម៌ដ៏ប្រពៃ បានឡើងឋានៈជាពលរដ្ឋល្អរបស់ប្រទេសជាតិ ប្រជារាស្ត្រល្អរបស់ព្រះមហាក្សត្រិយ៍ ឲ្យបានសមតាមព្រះរាជបំណងប៉ងប្រាថ្នាថានឹងនាំប្រទេសជាតិទៅកាន់សេចក្ដីរុងរឿងដូចសម័យព្រេងនាយ ។

ខ្ញុំព្រះករុណា អាត្មាភាពយល់ឃើញថា ក្នុងសម័យព្រេងនាយខែត្រសៀមរាបនេះជាទីក្រុងធំមួយ បរិបូណ៌ដោយប្រាង្គប្រាសាទរាជឋានខ្ពង់ខ្ពស់ត្រដឹមស្កឹមស្កៃ មានកំពូលដោយដុងផុតចុងព្រឹក្សា ទៅទល់នភាល័យប្រទេស ជាទីគោចរនៃអ្នកទេសចរបរទេសគ្រប់ជាតិដែលមកពីគ្រប់ជ្រុងពិភពលោក គួរតែមានវិជ្ជាឋានការសិក្សាជាន់ខ្ពស់មួយឲ្យសមកិត្តិយសជាព្រះមហានគរបរមបុរាណ ។ ដោយសេចក្ដីយល់ដូច្នេះហើយ បានជាព្រះរាជរដ្ឋាភិបាលក្នុងអតីតកាល បាន

បង្កើតសាលាបាលីជាន់ខ្ពស់ឡើងក្នុងខេត្រសៀមរាបនេះមុនដំបូង កាលពីគ្រិស្តសករាជ ១៩១២ យកព្រះរាជតំណាក់ ព្រះករុណាជាអម្ចាស់ជីវិតកាលនោះ នៅមុខនាគចំមុខប្រាសាទអង្គរវត្តជាគ្រឹះស្ថាន ហើយនិមន្តព្រះតេជព្រះគុណ ព្រះពុទ្ធវង្សប្រ៊ី មកធ្វើជាធំហ្មាន ។ តែវិជ្ជាសាលានេះមានអាយុខ្លីពេក បានត្រឹមតែ ៣ ឆ្នាំ គឺពីគ្រិស្តសករាជ ១៩១២ ទៅ ១៩១៤ ក៏រាជរដ្ឋាភិបាលលើកយកទៅតាំងនៅនាក្រុងភ្នំពេញវិញ រហូតមកដល់សព្វថ្ងៃនេះ ព្រោះទីនេះក្រីក្រមិនមានអាហារភោជនគ្រប់គ្រាន់នឹងចិញ្ចឹមភិក្ខុសាមណេរអ្នករៀនសូត្របាន ខ្ញុំព្រះករុណា អាត្មាភាពនេះជាសិស្សមួយរូបរៀនក្នុងសាលានោះដែររៀនបានត្រឹមតែ ៣ ឆ្នាំ ក៏ខកខានបានរៀនតាំងពីកាលនោះរហូតមកនឹកស្តាយជាទីបំផុត នឹងតាមទៅរៀនឯក្រុងភ្នំពេញ ញាតិញោមក៏ក្រមិនមានមធ្យោបាយជួយបាន ។

សេចក្តីខ្លី ៗ ដូចខ្ញុំព្រះករុណា អាត្មាភាពក្រាបបង្គំទូល ថ្វាយព្រះពរមកនេះ ផ្សំនឹងយោបល់ស្របគ្នារបស់លោករដ្ឋមន្ត្រីក្រសួងធម្មការច្រើនរូបកាលរាជរដ្ឋាភិបាលមុន ៗ មក នាំឲ្យខ្ញុំព្រះករុណា អាត្មាភាពសម្រេចចិត្តជាចាំបាច់ថា ត្រូវតែកសាងគ្រឹះស្ថានបង្កើតការសិក្សាជាន់ខ្ពស់ក្នុងខេត្រនេះឡើងវិញ ដើម្បីបន្តសាលាបាលីជាន់ខ្ពស់អំពីកាលនោះឲ្យមានឡើងវិញផង ដើម្បីបំពេញសេចក្តីត្រូវការនៃភិក្ខុសាមណេរជាសិក្ខាកាមបុគ្គលក្នុងខេត្រនេះ ដែលក្រីក្រទៅរៀនទីឆ្ងាយពុំបាន

ឲ្យបានមានវិជ្ជាជាន់ខ្ពស់ឡើង សមនឹងកេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់ព្រះមហានគរ សម័យព្រេងនាយនៅក្បែរនេះផង ។

លុះមូលគំនិតហើយ ខ្ញុំព្រះករុណា អាត្មាភាពរួបរួមនឹងគណៈកម្មការវត្ត ចាត់ការរៀបចំកសាងគ្រឹះស្ថាននេះឡើង ក្នុងគ្រិស្តសករាជ ១៩៥៣ មកដល់គ្រិស្តសករាជ ១៩៥៦ នេះទើបស្រេច ។ សាលាបាលីនេះទទឹង ១០ ម៉ែត្រ បណ្តោយ ២០ ម៉ែត្រ សង់ដោយឥដ្ឋមានពីរជាន់ ដំបូលឈើ ប្រក់ក្បឿង, សាលាបាលីនេះ អាចធ្វើជាកន្លែងសិក្សាបាន ៤ ថ្នាក់ ។ កន្លែងកណ្តាលទាំងលើក្រោម អាចធ្វើជាការិយាល័យបាន ។ សាលានេះមានលោកសប្បុរសជាច្រើននាក់ មានសទ្ធាជួយជាកំឡាំងទ្រព្យផង កំឡាំងកាយផង បព្វជិតក៏មាន គ្រហស្ថក៏មាន នៅជើងវត្តនេះផង ក្នុងខែត្រសៀមរាបទាំងមូលផង, ខែត្រដទៃទៀតផង រួបរួមគ្នាកសាងឡើង អស់ទឹកប្រាក់ចំនួន ៣៧២.៩៦៤ រៀល ។

ខ្ញុំព្រះករុណា អាត្មាភាពមានសេចក្តីត្រេកអរក្រៃលែង ព្រោះបានសម្រេចដូចបំណងហើយ ។

វេលានេះ, សម្តេចព្រះតេជព្រះគុណព្រះពោធិវង្ស លោករដ្ឋលេខាធិការ ឯកឧត្តមព្រះរាជប្រតិភូ និមន្តមក អញ្ជើញមកជួបជុំក្នុងថ្ងៃនេះ កំណត់ទុកថាជានក្ខត្តឫក្សមានសិរីសួស្តី ខ្ញុំព្រះករុណា អាត្មាភាព សូមលើកគ្រឹះស្ថាននេះ ជូនចំពោះព្រះរាជរដ្ឋាភិបាល ដែលមានសម្តេចព្រះឧបយុវរាជជាប្រមុខ, សូមព្រះរាជរដ្ឋាភិបាលទទួលគ្រឹះស្ថាននេះទុកជា

សម្បត្តិរដ្ឋ ហើយចាត់ការបង្កើតជាពុទ្ធិកវិទ្យាល័យពុទ្ធសាសនាក្នុងខេត្រសៀមរាប ឲ្យត្រាតែបានសម្រេច ដើម្បីអនុគ្រោះដល់កុលបុត្រជាសិក្ខាកាមបានក្រេបរសព្រះធម៌ថ្លៃ កើតចក្ខុមើលឃើញធម៌ ប្រយោជន៍ លុបលាងបំបាត់មិច្ឆាទិដ្ឋិ ហើយសាបព្រោះសម្មាទិដ្ឋិឲ្យមើលឃើញផ្លូវដើរទៅរកសេចក្ដីសុខពិត ជាកំពូលសេចក្ដីប្រាថ្នានៃសត្វលោក ទុកជាព្រះកិត្តិយសដ៏ខ្ពង់ខ្ពស់នៃព្រះមហាក្សត្រ និង សម្ដេចព្រះមហាក្សត្រិយានី ព្រមទាំងសម្ដេចព្រះឧបយុវរាជ តទៅរហូតកល្បាវសាន ។

ពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថក្នុងខេត្រសៀមរាបនេះ មានសេចក្ដីត្រេកអរជាទីបំផុត ប្រសិនបើគ្រឹះស្ថាននេះកើតបានជាពុទ្ធិកវិទ្យាល័យ ដោយព្រះបរមរាជូបត្ថម្ភដូចបំណងហើយ និងបានភិក្ខុសាមណេរជាគ្រូទៅនៅសិក្សារៀនសូត្រក្រោមម្លប់ព្រះបរមពោធិសម្ភារបុណ្យបារមីនៃព្រះករុណាជាអម្ចាស់ជីវិតជាសុខក្សេមក្សាន្តតរៀងទៅ ។

ក្នុងទីបំផុតនេះ, ខ្ញុំព្រះករុណា អាត្មភាព សូមលើកយកផលនៃការកសាងនេះ

— ថ្វាយចំពោះព្រះករុណា និងសម្ដេចព្រះមហាក្សត្រិយានី សូមទ្រង់បានប្រកបដោយសុខសួស្ដីក្នុងសិរីរាជសម្បត្តិតរៀងទៅ ។

— ប្រគេនសម្ដេច និងព្រះតេជព្រះគុណព្រះពោធិវង្ស សូមមានព្រះជន្មាយុយឺនយូរ ព្រមទាំងសេចក្ដីសុខសាន្តអស់កាលជាអង្វែងទៅ ។

— ថ្វាយចំពោះសម្ដេចព្រះឧបយុវរាជ, សូមសម្ដេចទ្រង់បានប្រកប

ដោយព្រះពរ គឺ អាយុ វណ្ណៈ សុខៈ ពលៈ នឹងប្រតិភាណគ្រប់ទិវារាត្រីតរៀងទៅ ។

– សូមជូនលោករដ្ឋលេខាធិការក្រសួងធម្មការ នឹងឯកឧត្ដមព្រះរាជប្រតិភូ ព្រមទាំងអស់លោកអ្នកទាំងឡាយ ឲ្យបានប្រកបដោយសេចក្ដីសុខចំរើនគ្រប់ប្រការតរៀងទៅ ។

*
* *

## សុន្ទរកថា

## នៃលោករដ្ឋលេខាធិការក្រសួងធម្មការ

សូមថ្វាយបង្គំសម្ដេច !

ព្រះតេជព្រះគុណគ្រប់ព្រះអង្គ !

សូមជំរាបឯកឧត្ដមព្រះរាជប្រតិភូ !

សូមជំរាបលោកអ្នកសប្បុរសទាំងឡាយ !

ក្នុងនាមនៃព្រះរាជរដ្ឋាភិបាល, ខ្ញុំព្រះករុណា, ខ្ញុំសូមថ្លែងនូវឧបការគុណ ដ៏ជ្រាលជ្រៅចំពោះព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យ ដែលមានឧត្ដមគតិដ៏ប្រសើរ បានដឹកនាំពុទ្ធបរិស័ទឲ្យជួយកសាងគ្រឹះស្ថានមួយខ្នង សម្រាប់ជាពុទ្ធិកវិទ្យាល័យចំពោះព្រះពុទ្ធសាសនា ទុកជាសម្បត្តិរបស់រដ្ឋ, ឧត្ដមគតិនេះអាចទុកជាគំរូមួយ កើតមានឡើងក្នុងវេលាដែលប្រទេសកម្ពុជា កំពុងឋិតនៅក្នុងស្ថានការណ៍ហិរញ្ញវត្ថុដ៏បង្អៀតក្រៃលែង អាចនឹងរាប់បានថាជាមហាពលីមួយយ៉ាងថ្លៃថ្លារបស់

ព្រះតេជព្រះគុណ និងពុទ្ធបរិស័ទចំពោះមាតុភូមិនិងពុទ្ធសាសនា ។ ពលិកម្មមានសភាពប្រាកដដូចនេះ មិនសូវកើតមានញឹកញយទេ កាលបើកើតមានម្តង ៗ អាចធ្វើទឹកចិត្តព្រះសង្ឃ និងពុទ្ធបរិស័ទទាំងឡាយឲ្យរំភើបយ៉ាងក្រៃលែង មិនត្រឹមតែប៉ុណ្ណោះទេ ពលិកម្មជាគំរូនេះ ទុកជាជំនួយមួយសម្រាប់ប្រទេសយើង ព្រោះអាចជួយសម្រាលបានខ្លះ នូវបន្ទុកដ៏ធ្ងន់នៃថវិកាជាតិ ហើយជាមធ្យោបាយមួយដ៏ប្រសើរ សម្រាប់តំកំតំកើងព្រះពុទ្ធសាសនាឲ្យមានរស្មីរុងរឿងក្នុងសាកលលោក ។

ចំពោះការសិក្សាវិជ្ជាផ្នែកពុទ្ធសាសនា ព្រះរាជរដ្ឋាភិបាលពុំបានព្រងើយកន្តើយសោះ ក្នុងបច្ចុប្បន្ននេះ ខ្ញុំព្រះករុខ្ញុំកំពុងរៀបចំកិច្ចការសិក្សាវិជ្ជាជាន់ខ្ពស់ខាងពុទ្ធសាសនារួបរួមជាមួយព្រះតេជព្រះគុណ ព្រះពោធិវង្សជាតាងហ្លួងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ហើយនឹងពង្រីកការសិក្សានេះ ឲ្យបានធំទូលាយដល់ទៅទីប្រជុំខេត្តនានា ក្នុងព្រះរាជ-អាណាចក្រ ឲ្យបានសមដូចបំណងព្រះតេជព្រះគុណ និងពុទ្ធបរិស័ទក្នុងទីនេះ សូមព្រះតេជព្រះគុណសង្ឃឹមទុកក្នុងព្រះទ័យចុះថា នឹងបានសម្រេចដូចសេចក្តីប្រាថ្នា ក្នុងអនាគតដ៏ខ្លីនេះ ។

ក្នុងនាមនៃប្រជាជាតិ ដែលមានសម្តេចព្រះឧបយុវរាជទ្រង់ជាប្រមុខ និងក្នុងនាមនៃព្រះសង្ឃ ដែលមានសម្តេចព្រះមហាសុមេធាធិបតីនិមន្តមកគង់ជាប្រធាន ខ្ញុំព្រះករុណា ខ្ញុំបាទទទួលគ្រឹះស្ថានមួយខ្នងនេះដោយសោមនស្សរីករាយយ៉ាងក្រៃលែង ហើយនឹងរៀបចាត់ចែងបង្កើតឲ្យមានការសិក្សាជាន់ខ្ពស់ឡើង ក្នុងខេត្តសៀមរាបនេះ ក្នុងកាលវេលាដ៏សមគួរ

ដើម្បីឲ្យស្របតាមព្រះរាជបំណងសម្ដេចដែលទ្រង់តែងតែមានព្រះហឫទ័យជួន ក្នុងការពង្រីកព្រះពុទ្ធសាសនា ឲ្យបានរីកទូលាយត្រឡុងត្រឡាយឡើង សមជាសាសនារបស់ប្រទេសឯករាជ្យផង ដើម្បីឆ្លើយតបនឹងសេចក្ដីត្រូវការព្រះតេជព្រះគុណ ព្រមទាំងពុទ្ធបរិស័ទក្នុងទីនេះផង ។

ព្រះតេជព្រះគុណ !

មុននឹងបញ្ចប់, ក្នុងនាមនៃប្រជាជាតិ ដែលមានសម្ដេចព្រះឧប-យុវរាជជាប្រមុខ និងក្នុងនាមនៃព្រះសង្ឃ ដែលមានសម្ដេចព្រះមហាសុមេធាធិបតីជាប្រធាន ខ្ញុំព្រះករុណា ខ្ញុំ សូមព្រះតេជព្រះគុណ និងពុទ្ធបរិស័ទទាំងឡាយ មេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅនឹងកក្ដីភាពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំព្រះករុណា ខ្ញុំ ។

សូមអញ្ជើញគុណព្រះរតនត្រ័យជួយអភិបាលថែរក្សា ព្រះតេជព្រះគុណនឹងពុទ្ធបរិស័ទទាំងឡាយ ឲ្យបានឋិតនៅក្នុងសេចក្ដីសុខចំរើនគ្រប់ប្រការ ចាប់តាំងពីពេលនេះរហូតតទៅ ។

---

# ពិធីបុណ្យទក្ខិណានុប្បទាន

របស់លោក ឯង-ប៉ឹង ធ្វើនៅភូមិតាលស់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង

## ព្រះអាចារ្យ នូ-កិញ

វត្តសុវណ្ណភូមិ ឃុំតាលស់ ស្រុកមោងឫស្សី រៀបរៀង

---

នៅថ្ងៃទី ១៦ មេសា ១៩៨៦ ក្នុងអាគារស្ថាននៃឧបាសិកា នូ-ទួន ក្នុងភូមិតាលស់ ឃុំតាលស់ ស្រុកមោងឫស្សី (បាត់ដំបង) មានធ្វើពិធីបុណ្យទក្ខិណានុប្បទានយ៉ាងឧឡារិក ដើម្បីឧទ្ទិសកុសលជូនដល់បុព្វបុរសគឺព្រះតេជព្រះគុណ ហ៊ុល-តាយ, ឧបាសក ឯង និងឧបាសិកា ជូ ដែលអស់ព្រះជន្ម និងជន្មាយុទៅហើយ ក្រោមការចាត់ចែងនៃលោកឯង-ប៉ឹង និងក្រុមគ្រួសាររបស់លោក ។

ដោយការតាក់តែងរបស់លោក ឯង-ប៉ឹង លើផែនពសុធាជុំវិញនៃអាគារស្ថាននោះ មានពន្លឺភ្លើងអគ្គិសនីភ្លឺចែងចាំង ទាំងមានគ្រឿងបក្រសម្រាប់ពង្រីកសំឡេងលាន់ឮគឹកកងរំពង ដែលឮពីចម្ងាយ អាចទាញអារម្មណ៍ឲ្យដឹងថាជាពិធីបុណ្យបានផង, អាចទាញមនុស្សដែលមានចិត្តមច្ឆរិយ ឲ្យអាក់ខានលះបង់ធនធានមិនបានផង ។

ក្នុងឱកាសនោះ យើងសង្កេតឃើញតាំងពីម៉ោង ១៦, ១៨ នាទី មានការអញ្ជើញមកនៃពុទ្ធបរិស័ទទាំងប្រុស-ស្រី ជាញាតិសាលោហិត ច្រើនមីរដេរដាសដែលខានជួបគ្នាយូរខែថ្ងៃហើយ សុទ្ធតែមានមុខស្រស់ស្រាយរីករាយរកគ្នា ។

- ដោយសេចក្ដីសាមគ្គីនៃអស់លោក-អ្នកជាសប្បុរសទាំងឡាយ ពិធីបុណ្យនេះ ក៏បានកើតឡើងដោយសុភមង្គលយ៉ាងក្រៃលែង ។

ព្រះករុណា ព្រះអង្គ !

អស់លោក-អ្នកសប្បុរសទាំងឡាយ !

យើងខ្ញុំ សូមឱកាសថ្លែងសន្ទាមួយដំខ្វី ដូចតទៅនេះ៖

កាលព្រះសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់ធរមាននៅឡើយ ទ្រង់សំដែងថា " សត្វលោកទាំងអស់សុទ្ធតែប្រកបដោយសេចក្ដីព្រាត់ប្រាសចាកមាតាបិតា គ្រូអាចារ្យបុត្រភរិយា និងញាតិសាលោហិតទាំងឡាយជាធម្មតា មិនថាមនុស្ស សត្វ ឬទេវតាទេ ខុសគ្នាតែត្រង់មុនក្រោយ ឆាប់ច្រើនតិចប៉ុណ្ណោះ និងគេចឲ្យផុតពីការព្រាត់ប្រាសនិពសគ្នាពុំបាន " ។ តាមការចេះចាំបន្តបន្ទាប់ខាងផ្លូវពុទ្ធសាសនានៃយើងខ្ញុំថា សត្វលោកខ្លះគ្រាន់តែដឹងថា ការព្រាត់ប្រាសនិពសមានប្រាកដមែន, ប៉ុន្តែពុំអាចដឹងថានឹងមានមកនៅកាលបរិច្ឆេទណាម៉ោងណាឡើយ, ព្រោះជួនកាលអ្នកកើតមុនព្រាត់ប្រាសចាកបិយជនទាំងឡាយ មានមាតាបិតាជាដើមមុនក៏សឹងមាន, ជួនកាលអ្នកកើតក្រោយក៏ត្រឡប់ជាបានទទួលការព្រាត់ប្រាសចាកញាតិទាំងឡាយមុនអ្នកកើតមុនទៅវិញក៏សឹងមាន ។

រីការព្រាត់ប្រាសនិពសចាកមាតាបិតាគ្រូអាចារ្យជាដើម ដែលកំពុងមានសេចក្ដីស្នេហាប្រកាន់ជាប់ស្អិតនោះ ជាហេតុនាំឲ្យសត្វលោកកើតសេចក្ដីសោកសង្រេងសង្រែងខ្សឹកខ្សួលយ៉ាងមហិមា ។

ការព្រាត់ប្រាសរបស់សត្វលោកមានច្រើនជាអនេក, តែបើពោល

ថែងដោយបំប្រួញមាន ២ ប្រការ គឺ ព្រាត់ប្រាសដោយធ្វើកាលកិរិយា ចែកស្ថានទៅកាន់បរលោក ១, ព្រាត់ប្រាសដោយមានជីវិតរស់នៅ តែទៅនៅផ្សេងអាស្រយដ្ឋានដូចជាជនបំពួកខ្លះ មានមាតាបិតាគ្រូអាចារ្យជាដើម នៅស្រុកនេះភូមិនេះ ខ្លួនឯងទៅនៅស្រុកឯណោះភូមិឯណោះជាដើម ១ ។

ការព្រាត់ប្រាសទាំងពីរដូចសំដែងមកខាងលើនេះ បើប៉ះទៅលើរូបជនណា ជននោះមុខជាមិនខានបាននូវសេចក្ដីទុក្ខខ្សឹកខ្សួលឡើយ ។

ព្រះករុណាគ្រប់ព្រះអង្គ !

អស់លោក-អ្នកសប្បុរសទាំងឡាយ !

កាលយើងខ្ញុំនឹកដល់សេចក្ដីព្រាត់ប្រាស់ដូច្នោះ ក៏កើតសេចក្ដីអណោចអធម្មក្នុងចិត្ត នឹកធុញទ្រាន់ចំពោះសេចក្ដីព្រាត់ប្រាសនោះក្រៃពេក ទើបលះបង់នូវប្រយោជន៍ផ្ទាល់ខ្លួន ស៊ូបរិច្ចាគធនធានបន្តិចបន្តួច មកបំពេញបុញ្ញកិរិយាវត្ថុក្នុងទីនេះ ដើម្បីជាកំណាប់បុណ្យ នឹងជាស្បៀងក្នុងកាលព្រាត់ប្រាសដែលចៀសពុំរួចនោះ ។

ម្យ៉ាងទៀត យើងខ្ញុំនឹកមកដល់បុព្វបុរសគឺ ព្រះតេជព្រះគុណព្រះសព នឹងមាតាបិតា លោកទាំង ៣ នេះ សុទ្ធតែមានគុណអនេកអនន្តលើរូបយើងខ្ញុំ, កាលដែលលោកទាំងនោះកំពុងមានព្រះជន្មនឹងមានជន្មាយុនៅឡើយ យើងខ្ញុំបានប្រកបកាតព្វកិច្ចជាកុសលតបខ្លះដែរ តែមិនទាន់អស់ចិត្ត ដ្បិតយើងខ្ញុំចង់បំពេញកតវេទិធម៌ ដែលជាកាតព្វកិច្ចជាកុសលតបគុណលោក ឲ្យបានដរាបដល់អស់ជីវិតសង្ខារនៃយើងខ្ញុំ តែលោកទាំងនោះទៅជាអស់ព្រះជន្ម នឹងជន្មាយុទៅ, មិនតែប៉ុណ្ណោះ

សូម្បីឪពុកធំ, ម្តាយធំ, ឪពុកមា ម្តាយមីង, សាមីភរិយា ទាំងញាតិឯទៀត ដែលគួរគោរពរបស់យើងខ្ញុំដែរ ក៏ធ្វើមរណកាលទៅទៀត ។

ព្រះករុណា គ្រប់ព្រះអង្គ !

អស់លោក-អ្នកសប្បុរសទាំងឡាយ !

ដោយកតញ្ញុតាធម៌កើតមានក្នុងចិត្ត ទើបយើងខ្ញុំនាំគ្នាបំពេញករណីយកិច្ចជាកុសល ដើម្បីឧទ្ទិសជូនដល់បុព្វបុរសខាងលើនេះផង ។ ហេតុនេះ យើងខ្ញុំសូមឧទ្ទិសកុសលនេះជូនដល់បុព្វបុរសដូចតទៅនេះ៖

ព្រះតេជព្រះគុណព្រះសព !

លោកឪពុកលោកម្តាយ !

យើងខ្ញុំជាសិស្ស ជាបុត្រាបុត្រី និងជាបុត្រប្រសា សូមលើកកុសលនេះ ប្រគេនដល់ព្រះតេជព្រះគុណ និងជូនដល់លោកឪពុកម្តាយ សូមលោកទទួលយកនូវកុសលនេះទុកជាដូចជារបស់នៃខ្លួនចុះ កាលបើបានទទួលហើយ សូមឲ្យបានសម្រេចនូវឥដ្ឋមនុញ្ញផលកុំបីខានឡើយ ។

ក្នុងទីបំផុត យើងខ្ញុំសូមឧទ្ទិសកុសលនេះថ្វាយចំពោះព្រះករុណា ជាម្ចាស់ជីវិតលើត្បូង, សម្តេចព្រះមហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជនរោត្តម-សីហនុ, និងព្រះរាជវង្សានុវង្ស, ទាំងសូមឧទ្ទិសកុសលនេះជូនដល់ព្រះរាជរដ្ឋាភិបាល សូមកុសលនេះជួយឧបត្ថម្ភទ្រង់និងព្រះរាជរដ្ឋាភិបាលឲ្យបានប្រកបតែនិងសេចក្តីសុខសេចក្តីចំរើនយូរអង្វែងទៅ ។

ម្យ៉ាងទៀត យើងខ្ញុំសូមចែកភាគផលនៃបុណ្យនេះ ជូនដល់អស់លោក-អ្នកដែលបានអញ្ជើញមកក្នុងទីនេះក្តី ដែលមិនបានមកគ្រាន់តែ

ពេញចិត្តជ្រះថ្លាក្នុងកុសលនេះក្តី សូមអស់លោក - អ្នកទទួលអនុមោទនា ដោយសទ្ធាសញ្ញាថា សាធុ ព្រមៗគ្នា; កាលបើបានទទួលអនុមោទនាហើយ សូមឲ្យអស់លោក - អ្នកបានសម្រេចនូវភោគផលស្មើៗគ្នា ទាំងសូមឲ្យកុសលនេះជួយបីបាច់រក្សា នូវអស់លោក - អ្នកឲ្យបាន សេចក្តីសុខចំរើនតាំងពីបច្ចុប្បន្ននេះរហូតដល់ព្រះនិព្វាន កុំបីឃៀងឃ្លាតឡើយ ។

---

ពិធីសម្ពោធដួងមង្គលពេទ្យព្រះសង្ឃ

ពុទ្ធសាសនបណ្ឌិត្យ

( តមកពីសៀវភៅលេខ ៤ )

---

## សុន្ទរកថាឯកឧត្តម មាស - យ៉ង់

លុះចប់សុន្ទរកថាព្រះអរិយកស្សបអ៊ូចហើយ ឯកឧត្តម មាស - យ៉ង់ រដ្ឋលេខាធិការក្រសួងសាធារណសុខាភិបាល បានថ្លែងបន្តមកទៀត ដែលមានសេចក្តីដូចតទៅនេះ ៖

សូមព្រះតេជះដ៏គល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

មុនដំបូង ទូលព្រះបង្គំជាខ្ញុំសូមព្រះរាជទានថ្លែងអំណរព្រះករុណា-ធិគុណដ៏ជ្រាលជ្រៅដោយគោរព ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់សព្វព្រះរាជហឫទ័យស្តេចយាងមកជាព្រះរាជាធិបតី ចំពោះពិធីបុណ្យសម្ពោធនេះ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានថ្លែងសេចក្តីកោតសរសើរយ៉ាងក្រៃលែង ចំពោះសម្តេចព្រះឧបយុវរាជ ដោយទ្រង់មានព្រះរាជបញ្ញា-ញាណដ៏វិសេសក្នុងការប្រមាណគ្រប់ចំពូកភ្លឺថ្លា និងព្រះរាជឆន្ទៈដ៏ពិតប្រាកដរបស់ព្រះអង្គ ដែលនាំឲ្យគតិនៃក្រុមគិលានសង្គ្រោះ ចំពោះព្រះសង្ឃពុទ្ធសាសនិក បានផុសចេញជារូបរាងជាក់ស្តែងឡើង ។

ខ្ញុំព្រះករុណា សូមឱនកាយដោយគោរព ចំពោះសម្តេចព្រះសង្ឃ

នាយកទាំងពីរគណៈ ព្រមទាំងព្រះថេរានុត្ថេរៈទាំងអស់ ដែលបាននិមន្តមកក្នុងពិធីបុណ្យសម្ពោធនេះ ។

- សម្ដេច
- ទ្រង់
- លោកឧត្ដមស្នងការ
- ឯកឧត្ដមឯកអគ្គរាជទូត
- ឯកឧត្ដម
- លោកស្រី
- អស់លោក

ឱកាសនេះ គឺជាកិត្តិយសមួយដ៏ប្រសើរ ដែលតម្រូវឲ្យទូលព្រះបង្គំជាខ្ញុំ ៗ មានករណីយកិច្ចនឹងថ្លែងសេចក្ដីយ៉ាងខ្លី ចំពោះព្រះភក្ត្រ និងមុខឥស្សរជន ដែលបានស្ដេចយាងអញ្ជើញមកកាន់ទីសន្និបាត ដើម្បីសម្ពោធបើកមន្ទីរព្យាបាលរោគដ៏ល្អឆើតនេះ ។

ថ្ងៃនេះ ទូលព្រះបង្គំជាខ្ញុំជឿប្រាកដថា ជាថ្ងៃដែលជាប់ចារឹកក្នុងប្រវត្តិសាស្ត្រពេទ្យនៃប្រទេសកម្ពុជា ។

មាតុភូមិយើងបានឯករាជ្យពេញលក្ខណៈហើយ ក៏ប៉ុន្តែបើយើងមានសិទ្ធិកាន់តែច្រើនឡើង យើងក៏ត្រូវតែបំពេញករណីយកិច្ចកាន់តែច្រើនដែរ ជាប្រថម គឺករណីយកិច្ចដែលត្រូវលើកតំកើងសុខភាពប្រជាជន ។ ថ្វីបើមានឧបសគ្គគ្រប់មុខយ៉ាងណាក៏ដោយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ ជាទីគោរពហើយជាទីស្នេហា

ព្រមទាំងសម្តេចព្រះឧបយុវរាជជាទីស្វាមីភក្តិនៃយើងទាំងអស់គ្នា ទ្រង់តែងមានព្រះរាជបំណងកាន់ខ្ជាប់ខ្ជួននូវឥរិយាបថនេះ ។

ហេតុដូច្នេះហើយ បានជាកាលពីថ្ងៃទី ៧ មករា គ.ស. ១៩៥៦ នេះ សាលាភូមិន្ទវេជ្ជពេទ្យបានសម្ពោធបើកជាផ្លូវការរួចហើយ ។ កន្លងពីពេលនោះមក ពុំទាន់បានពីរខែផង មានការសម្ពោធបើកគ្រឹះស្ថានយ៉ាងប្រពៃនេះទៀត ដែលអាចទុកជាគំរូដល់មន្ទីរពេទ្យទៅអនាគត ។

សមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃ បានចេញមូលធនមុនដំបូងដើម្បីនឹងសង់គ្រឹះស្ថាននេះ ។ ដោយការដឹកនាំដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះឧបយុវរាជ រាជរដ្ឋាភិបាលក៏បានផ្តល់ជាជំនួយហិរញ្ញវត្ថុដ៏សំខាន់ក្នុងការកសាងគ្រឹះស្ថាននេះដែរ ។ ប្រជាជាតិសប្បុរសអាមេរិកាំង បានជួយឧបត្ថម្ភបង្ហើយការស្ថាបនា នឹងបានផ្តល់នូវគ្រឿងសម្ភារៈបច្ចេកទេសទាំងអស់ ។ ចំណែកខាងប្រទេសបារាំងវិញ ក៏បានយកចិត្តទុកដាក់ជួយជ្រោមជ្រែងក្នុងការនេះដោយមុតមាំដែរ បានជួយគ្រឿងសម្ភារៈខ្លះ ហើយនឹងបម្រុងបញ្ជូនបុគ្គលិកពេទ្យឲ្យមកធ្វើការនៅមន្ទីរនេះ ក្នុងពេលឆាប់ៗ ។

សហប្រតិបត្តិការនេះ ជាភស្តុតាងមួយបញ្ចេញឲ្យឃើញជាក់ច្បាស់នូវមិត្តភាព នៃមហានគរទាំងពីរចំពោះប្រជាជនខ្មែរ ហើយរឹតបំណងកាន់តែជិតស្និទ្ធឡើងនៃការរួបរួមមនុស្សជាតិទៀតផង ។

ស្ពានដៃថ្មីនេះ បូកបញ្ចូលនឹងស្ពានដៃឯទៀតៗជាច្រើន ដែលបានសម្រេចក្រោយពេលដែលប្រជាជនខ្មែរបានឯករាជ្យហើយ បង្ហាញជា

ភស្តុតាងជាក់ស្តែងនៃសាមគ្គីភាពយើង ព្រមទាំងបញ្ជាក់ថែមទៀតថា ប្រទេសយើងបានចូលមកនៅក្នុងសករាជមួយថ្មីហើយ ។

តាមបំណងនៃប្រជាជនខ្មែរ មន្ទីរព្យាបាលរោគនេះទុកសម្រាប់ទទួលតែព្រះសង្ឃដែលមានអាពាធទេ ។

បដិសណ្ឋារកិច្ចនេះ បង្ហាញឲ្យឃើញច្បាស់នូវសេចក្តីគោរពនៃពលរដ្ឋខ្មែរ ចំពោះព្រះសង្ឃពុទ្ធសាសនិក ដែលបានគាំទ្របរិយាសាស្ត្រ និងចិត្តសាស្ត្រ ឲ្យនៅក្នុងឋានៈដ៏ខ្ពង់ខ្ពស់ជានិច្ចក្នុងប្រទេសកម្ពុជា ។

របៀបនេះអាចធ្វើឲ្យព្រះសង្ឃពុទ្ធសាសនិកយើង កាន់ក្រិត្យវិន័យបានដោយទៀងទាត់ ក្នុងពេលដែលកំពុងទទួលនូវការព្យាបាលរោគយ៉ាងទំនើប ។

ទូលព្រះបង្គំជាខ្ញុំ សូមថ្លែងអំណរព្រះគុណនិងគុណដ៏ជ្រាលជ្រៅ ចំពោះលោក - លោកស្រី និងអស់លោកអ្នកទាំងអស់ ដែលបានជួយឧបត្ថម្ភក្នុងការកសាងនេះ ។ សូមឯកឧត្តមតំណាងប្រទេសនានាដែលបានធ្វើអំណោយយ៉ាងប្រសើរ ដល់គ្រឹះស្ថាននេះ ទទួលនូវសក្ខីភាពនៃសេចក្តីកតញ្ញូរបស់ប្រទេសកម្ពុជា ។

ក្នុងឋានៈជារដ្ឋលេខាធិការក្រសួងសាធារណៈសុខាភិបាល និងក្នុងឋានៈជាឯកជន ទូលព្រះបង្គំជាខ្ញុំសូមក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ ព្រមទាំងសម្តេចព្រះឧបយុវរាជជាទីស្នេហា សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទទួលនូវបដិការគុណដ៏ជ្រាលជ្រៅនៃពលរដ្ឋខ្មែរ ។

មិនត្រឹមតែប៉ុណ្ណោះ ដោយស្នាព្រះហស្តមានរស្មីភ្លឺត្រចះនៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ ព្រមទាំងសម្តេចព្រះឧបយុវរាជទ្រង់បានត្រាស់ទទួលទុកជាព្រះបរមរាជារបស់ព្រះអង្គ នូវព្រះបរមរាជានៃព្រះអយ្យកោ ដ៏មានព្រះឥទ្ធិឫទ្ធិដ៏ល្បីល្បាញ ហើយនឹងព្រះមហាវីរក្សត្រ ព្រះជយវរ្ម័នទី ៧ របស់យើងដែលមានចារឹកនៅថ្មតាមន័យដូចតទៅនេះ៖

«ទ្រង់មានព្រះរាជហឫទ័យឈឺចាប់នឹងជម្ងឺរបស់ពលរដ្ឋព្រះអង្គ ជាង
«ព្រះរោគរបស់ព្រះអង្គទៅទៀត ព្រោះថាជម្ងឺសាធារណៈនេះហើយ
«ដែលធ្វើឲ្យព្រះមហាក្សត្រគ្រប់ព្រះអង្គ ទទួលនូវព្រះរាជទុក្ខជាជាង
«ព្រះរាជទុក្ខរបស់ព្រះអង្គទៅទៀត » ។

## សុន្ទរកថាឯកឧត្តម ទ្រីញ-រ៉ាញ

នៅទីអវសាន, ឯកឧត្តមទ្រីញ-រ៉ាញ រដ្ឋលេខាធិការក្រសួងធម្មការបានថ្លែងសុន្ទរកថា រៀបរាប់ចំពោះកិច្ចការដែលត្រូវបំពេញជាសារៈប្រយោជន៍ដល់ប្រទេសជាតិ និងសារៈប្រយោជន៍រៀងរាល់រូប ។ សុន្ទរកថានេះ យើងយកមកផ្សាយជូនទាំងស្រុងដែលមានសេចក្តីដូចតទៅនេះ ៖

សូមព្រះតេជៈដ៏កល់លើត្បូង
សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណា ជាអម្ចាស់ជីវិត
សូមទ្រង់ជ្រាប, ក្រោមល្អងធូលីព្រះបាទ ។

សូមថ្វាយបង្គំព្រះវេទនុតេរ:
សូមក្រាបបង្គំទូលទ្រង់
សូមដំកបសហជីវិន
អស់លោក - អ្នកទាំងឡាយ
សូមទ្រង់ជ្រាប, សូមជ្រាប ។

មន្ទីរព្យាបាលព្រះសង្ឃនេះ សមាគមគិលានសង្គ្រោះបានបែង កសាងឡើងដោយកម្លាំងសទ្ធាពុទ្ធបរិស័ទ ទាំងបព្វជិតទាំងគ្រហស្ថ ក្នុងព្រះរាជអាណាចក្រទាំងមូល ដើម្បីទុកជាសេនាសនៈសម្រាប់ព្យាបាល អាពាធព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ត្រូវតាមគន្លងប្រពៃណី ដែលថា ទាយកទាយិកាជាអ្នកផ្គត់ផ្គង់បច្ច័យ ៤ ចំពោះព្រះសង្ឃ ។ បច្ច័យ ៤ នេះ ជាមធ្យោបាយលៀងជីវិតព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ឲ្យប្រព្រឹត្តទៅ ស្រួលសមដូចជាពាក្យដែលលោកទាំងមូល បបួលគ្នានិយមថា ជីវភាព ខ្ពង់ខ្ពស់ ។ ពិតពេលោកក្នុងបច្ចុប្បន្នកាលនេះ កំពុងខំប្រឹងកសាងការ គ្រប់គ្រងជីវភាពប្រជាជនលោកឲ្យរស់នៅដោយស្រួល ដោយការផ្តល់ ឲ្យមាន ៖

១ – គ្រឿងស្លៀកពាក់
២ – អាហារបរិភោគ
៣ – ទីលំនៅ
៤ ឱសថរោគ

ទាំង ៤ ប្រការនេះ ឲ្យមានបរិបូណ៌យ៉ាងណា ក្នុងពុទ្ធសាសនា ទាយកទាយិកាក៏មានការៈផ្តល់បច្ច័យទាំង ៤ គឺ

១ – ចីវរ

២ – បិណ្ឌបាត

៣ – សេនាសនៈ

៤ – ភេសជ្ជៈ

ទាំង ៤ ប្រការនេះ ប្រគេនព្រះសង្ឃយ៉ាងនោះដែរ ព្រោះមនុស្សលោកដែលទីងរស់នៅបាន កំដោយអាស្រ័យបច្ច័យទាំង ៤ នេះឯង, បើខ្វះខាតបច្ច័យណាមួយហើយ មនុស្សលោករស់នៅមិនបានៈ១, ថែបថា បើមានតែគ្រឿងស្លៀកពាក់ ~ មិនមានអាហារ - ទីលំនៅ - ឱសថកែរោគ មនុស្សនៅមិនបាន, មានតែគ្រឿងស្លៀកពាក់ ទីងអាហារ តែខ្វះខាតទីលំនៅឱសថកែរោគ មនុស្សនៅមិនបានដែរ, មានតែគ្រឿងស្លៀកពាក់-អាហារ - ទីលំនៅ គ្មានឱសថកែរោគ មនុស្សនៅមិនបានទៀត ព្រោះមនុស្សមានរោគជាសត្រូវធំ សម្រាប់បំផ្លាញសេចក្តីសុខ បើមនុស្សមិនមានសុខភាពល្អហើយ, តើមនុស្សធ្វើសេចក្តីចំរើនឲ្យលោកដូចម្តេចបាន ដូចពុទ្ធភាសិតថា: ការមិនមានរោគ ហៅថា មានលាភធំ ។

តែការស្វែងរកទទួលបច្ច័យទាំង ៤ មក ដើម្បីលៀងជីវិតនេះ មិនមែនតែសម្រាប់ឲ្យរស់នៅទេ ឲ្យមានគ្រឿងផ្តល់ជីវិតគ្រប់ទាំង ៤ ល្មមរស់នៅបានស្រួលហើយ ត្រូវបំពេញប្រយោជន៍ ប្រយោជន៍ខ្លួន ទីងប្រយោជន៍មនុស្សលោក ព្រមទាំងបំពេញគុណធម៌ដទៃទៀត មានសីលធម៌ជាដើម

ដើម្បីសេចក្ដីសុខធំរួមទាំងអស់គ្នា គឺកសាងរូបទៅជាអរិយជន ចេះអៀនខ្មាសបាប, អរិយជនមានច្រើនក្នុងប្រទេសណា ប្រទេសនោះហៅថា អរិយប្រទេស ។

មន្ទីរព្យាបាលព្រះសង្ឃនេះ កសាងឡើងសម្រាប់ផ្ដល់បច្ច័យទី ៤ ចំពោះព្រះសង្ឃ ដើម្បីឲ្យព្រះសង្ឃរស់នៅសុខស្រួល មានអនាម័យល្អ បានមានឱកាសរៀនសូត្រ បំពេញសមណធម៌ព្រហ្មចរិយធម៌ និងគុណធម៌ដទៃទៀតច្រើនប្រការ ព្រមទាំងពង្រីកព្រះពុទ្ធសាសនា ឲ្យផ្សាយទៅពេញសាកលលោក ឲ្យពិភពលោកបានទទួលគ្រប់រសជាតិសន្តិភាពពិតតាមពុទ្ធសាសនា ទីងជួយទូន្មានប្រៀនប្រដៅបងប្អូនរួមជាតិយើងឲ្យជាសម្មាទិដ្ឋិ តាំងនៅក្នុងគុណធម៌ខ្ពង់ខ្ពស់ ជាអរិយជន សមជាពលរដ្ឋមានវិន័យដ៏ប្រសើរ ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ទូលព្រះបង្គំ ខ្ញុំបាទ សូមឆ្លៀតយកឱកាសនេះ ថ្លែងសេចក្ដីត្រេកអរជាបំផុត ចំពោះសមាគមគិលានសង្គ្រោះ ទ្រង់ឯកឧត្តម ព្រមទាំងពុទ្ធបរិស័ទទាំងអស់ ដែលរួមគ្នាយ៉ាងម៉ឺងម៉ាត់ ក្នុងការកសាងមន្ទីរព្យាបាលព្រះសង្ឃនេះឡើង, បំបែកឲ្យឃើញថា មានសេចក្ដីយល់ត្រូវតាមនយោបាយព្រះរាជរដ្ឋាភិបាល ដែលមានសម្ដេច ព្រះឧបយុវរាជជាប្រមុខ ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណា ជាម្ចាស់ជីវិតលើត្បូង ព្រមទាំងសម្ដេចព្រះមហាក្សត្រិយានី ដែលតែងតែមានព្រះរាជបំណងជានិច្ចនៅក្នុងព្រះរាជហឫទ័យ ចង់បំបាត់

អាពាធព្រះសង្ឃនឹងបំបាត់រោគាព្យាធិប្រជាជនព្រះអង្គ ព្រោះជម្ងឺប្រជាជន គឺជម្ងឺព្រះអង្គ ។

មិនតែប៉ុណ្ណោះទេ មន្ទីរព្យាបាលព្រះសង្ឃនេះ ជាមេបុណ្យមួយដ៏ធំ សម្រាប់អ្នកប្រាថ្នាបុណ្យកើបយកបុណ្យ, សមដូចព្រះតម្រាស់ព្រះសម្ពុទ្ធថា អ្នកដែលព្យាបាលព្រះសង្ឃឈ្មោះថា ព្យាបាលតថាគត ។ សេចក្ដីនេះ បញ្ជាក់ថា យើងបានបំរើព្រះបរមសម្មាសម្ពុទ្ធគ្រប់ៗគ្នា បានអានិសង្សច្រើនអនេកអនន្ត ត្រូវនឹងពុទ្ធដីកាមួយព្រះឧស្សទៀតថា អ្នកមានប្រាជ្ញ អ្នកឲ្យសេចក្ដីសុខគេ ត្រូវបានសេចក្ដីសុខមកវិញ ។

ទីបំផុត ទូលព្រះបង្គំជាខ្ញុំ-ខ្ញុំព្រះករុណា ទូលព្រះបង្គំ ខ្ញុំបាទ សូមអធិដ្ឋានគុណព្រះរតនត្រ័យ សូមទ្រង់ព្រះមេត្តាប្រោសអភិបាលថែរក្សាព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្ដេចព្រះមហាក្សត្រិយានី សម្ដេចព្រះឧបយុវរាជ ទ្រង់-ឯឧត្ដមអស់លោក ដែលមានកុសលចិត្តជួយកសាងមន្ទីរព្យាបាលព្រះសង្ឃនេះ ដោយកម្លាំងទ្រព្យ កម្លាំងកាយ សូមឲ្យបានសេចក្ដីសុខសួស្ដីសិរីវឌ្ឍន៍ ប្រាសចាករោគទុក្ខភ័យគ្រប់ប្រការ សមតាមសេចក្ដីប្រាថ្នាកុំបីឃ្លាត ។

លុះចប់សុន្ទរកថានៃឯកឧត្ដមទ្រៀញ-ក៏ញ៉េហើយ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានស្ដេចយាងទៅកាត់ខ្សែសំពត់បើកទ្វារមន្ទីរពេទ្យព្រះសង្ឃ មឹងស្ដេចទ្រង់បើកសំពត់ដែលបិទបាំងចារិកផ្ទាំងថ្ម រួចស្ដេចយាងទតគ្រប់ជាន់, គ្រប់បន្ទប់ ដោយមាននាម៉ឺនសព្វមុខមន្ត្រីតាមដង្ហែផង ។

ខាងក្រោយព្រះរាជទេសនានេះ, នៅម៉ោង ១០,៥០ នាទី ព្រះមហាក្សត្រិយ៍ បានស្ដេចយាងត្រឡប់មកកាន់ព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិពារហែអមព្រះអង្គដូចកាលស្ដេចយាងទៅ ។

យើងសូមជំរាបថា ពិធីបុណ្យសម្ពោធមន្ទីរពេទ្យព្រះសង្ឃដែលបានចាប់ផ្ដើមធ្វើតាំងពីពេលព្រឹកថ្ងៃទី ២១ កុម្ភៈនេះ បានបន្តរហូតដល់ម៉ោង ២៤ យប់ ដោយក្នុងពេលរាត្រីនោះ ពុទ្ធបរិស័ទបាននិមន្តសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ សំដែងធម៌ជាធម្មទាន និងបញ្ចាំងកាពយន្តផ្សាយជូនដល់ពុទ្ធបរិស័ទមើលជាការកំសាន្តផង ។

ចប់